00399971

E159/7

០០១/១៨-០៧-២០០៧-អ.វ.ត.ក.អ.ជ.ស.ដ

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 10 / NOV / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Huy

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

<u>ការដាក់តម្កល់ឯកសារលម្អិត</u>

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អ.វ.ត.ក.អ.ជ.ស.ដ |
| កាលបរិច្ឆេទឯកសារ | : | ១០ វិច្ឆិកា ២០០៩ |
| ភាគីដាក់តម្កល់ | : | សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម១ |
| ដាក់តម្កល់ជូន | : | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម | : | អង់គ្លេស |

ចំណាត់ថ្នាក់ឯកសារ

| | | |
|---|---|---|
| ចំណាត់ថ្នាក់ឯកសារស្នើដោយភាគីដាក់តម្កល់ | : | សាធារណៈ |
| ចំណាត់ថ្នាក់ដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ | : | |
| លក្ខន្តិកៈនៃចំណាត់ថ្នាក់ | : | |
| ការពិនិត្យចំណាត់ថ្នាក់បណ្ដោះអាសន្នឡើងវិញ | : | |
| ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ | : | |
| ហត្ថលេខា | : | |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / 11 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១_សារណាសន្និដ្ឋានចុងក្រោយ

00399972

E159/7

០០១/១៨-០៧-២០០៧-អ.វ.ត.ក.អ.ជ.ស.ដ

**ដាក់ជូនដោយៈ**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោកមេធាវី ការីម ខាន (Karim A.A. Khan)

កញ្ញាមេធាវី ទី ស្រ៊ីនណា

លោកមេធាវី អាឡាំង វ៉ែនណឺ (Alain Werner)

កញ្ញាមេធាវី ប្រ៊ីអាន់ មិកហ្គូនីហ្គល

(Brianne McGonigle)

**ដាក់ជូនទៅៈ**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម ស៊ីលវីយ៉ា ខាតរ៉ាយថ៍

(Silvia Cartwright)

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ ម៉ាក់ឡាវែនី

(Jean-Marc Lavergne)

ចៅក្រម ធូ មណី

**ជំនួយដោយៈ**

លោកស្រី ដានីញ៉ែលឡា រូឌី (Daniella Rudy)

លោកស្រី ហ៊ាដឡៃ រ៉ូស (Hadley Rose)

លោកស្រី ខេត ហ្គីបសុន (Kate Gibson)

លោក អាដាំ បន (Adam Bond)

លោក សេបាស្ទាង ហ្គីលីយ៉ូ (Sebastien Gillioz)

លោក សេឌ្រិក ឌឺ រ៉ូមាណេ (Cedric De Romanet)

00399973

E159/7

០០១/១៨-០៧-២០០៧-អ.វ.ត.ក.អ.ជ.ស.ដ

**<u>ចម្លងជូន:</u>**

**ជនជាប់ចោទ:**

លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច

**សហមេធាវីជនជាប់ចោទ:**

លោកមេធាវី ការ សាវុត្ថ

លោកមេធាវី ហ្វ្រង់ស្វ័រ រូ (Francois Roux)

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក យ៉ែត ចរិយា

លោក វីល្យែម ស្មីត (William Smith)

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោកមេធាវី គីម ម៉េងឃី

កញ្ញាមេធាវី ម៉ុច សុវណ្ណារី

លោកស្រីមេធាវី ម៉ាទីន ចេកឃ្វីន

(Martine Jacquin)

លោកមេធាវី ហ្វីលីព ខេននិន

(Philippe Canonne)

លោកមេធាវី គង់ ពិសី

លោកមេធាវី ហុង គីមសួន

លោកមេធាវី យ៉ុង ផានិត

កញ្ញាមេធាវី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

(Silke Studzinsky)

លោកមេធាវី ភ្យែ អូលីវីរស៊ឺ

(Pierre-Oliver Sur)

00399974

E159/7

០០១/១៨-០៧-២០០៧-អ.វ.ត.ក.អ.ជ.ស.ជ

លោក ពេជ្រ សម្បត្តិ

លោក អានីស អះមេដ (Anees Ahmed)

លោក វាំងសង់ ដឺវ៉ាយដឺ (Vincent de Wilde)

## មាតិកា


I. សេចក្តីផ្តើម ........................................ ១

II. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........................................ ៣

ក. សេចក្តីផ្តើម ........................................ ៣

ខ. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ........................................ ៥

គ. ការអនុវត្តនៅក្នុងតុលាការអន្តរជាតិនានា ........................................ ៩

ឃ. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ........................................ ១១

ង. តុលាការក្នុងស្រុក ........................................ ១២

ច. សេចក្តីសន្និដ្ឋាន ........................................ ១២

III. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........................................ ១៤

ក. សេចក្តីផ្តើម ........................................ ១៤

ខ. វិធាន២៣ ........................................ ១៤

គ. បទដ្ឋានត្រួតពិនិត្យនៅសាលាជំនុំជម្រះក្តីផ្សេងៗ ........................................ ១៧

ឃ. ឋានៈតាមនីតិវិធី និង ពាក្យបណ្តឹងអំពីព្យសនកម្ម ........................................ ២០

IV. មូលដ្ឋានអង្គហេតុនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........................................ ២៣

00399975

E159/7



ក. ពាក្យបណ្ដឹងធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីជាបុគ្គល........................................២៣

V. ពិរុទ្ធភាពរបស់ជនជាប់ចោទ........................................៤១

ក. សេចក្ដីផ្ដើម........................................៤១

ខ.ឌុច មានស្វ័យ័ភាពដ៏ធំទូលាយកក្នុងនាមជាប្រធានមន្ទីរស-២១........................................៤២

១. ឌុចមានអំណាចក្នុងការការពារមនុស្ស........................................ ៤៤

គ. ឌុច ប្រើប្រាស់មុខតំណែងរបស់ខ្លួនដើម្បីបង្កនូវវិធីសាស្ត្រមិនចាំបាច់ និង ឃោរឃៅមកលើអ្នកទោសនៅមន្ទីរស-២១........................................ ៤៦

១. ឌុច ព្យាយាមលាក់កំបាំងជាលក្ខណៈប្រព័ន្ធអំពីកម្រិតនៃការទទួលខុសត្រូវនៅមន្ទីរស-១..........៤៦

២. ឌុច រៀបចំមន្ទីរ ស-២១ ដើម្បីបញ្ចូលប្រព័ន្ធមួយដែលដាក់ទោសជាអតិបរិមា នូវការឈឺចាប់ដែលមិនចាំបាច់និងភាពព្រៃផ្សៃ ........................................៤៨

៣. ឌុច លើកទឹកចិត្តឱ្យបុគ្គលិករបស់ខ្លួននៅមន្ទីរ ស-២១ ឱ្យធ្វើជាសាហាវតាមដែលអាចធ្វើទៅបាន......
........................................៥៤

៤. ឌុច ចាត់ទុកអ្នកទោសដូចជាសត្វធាតុ........................................៥៦

ឃ. ឌុច បានបន្ថែមទៅលើភាពជ្រុលនិយមរបស់ថ្នាក់លើ ដោយបង្កើតឱ្យមានចម្លើយសារភាពដ៏មានប្រសិទ្ធភាពដើម្បីបង្កើតម៉ាស៊ីនសួរចម្លើយ ........................................៥៨

១.គោលបំណងនៃការសួរចម្លើយ........................................៦០

២. ចំណាររបស់ឌុច និង បញ្ជីរឈ្មោះបង្កើតនៅពេលសួរចម្លើយ តែងឯបានធ្វើឱ្យភាពមិនទុកចិត្តរបស់ថ្នាក់ដឹកនាំខាងលើកាន់តែកើនឡើង........................................៦២

៣. ការកើនឡើងនូវភាពមិនទុកចិត្តបង្កើតឡើងដោយ ឌុច បាននាំដល់ការចាប់ខ្លួន និង សម្លាប់ "ខ្មាំងនិងជនក្បត់" កាន់តែច្រើននៅមន្ទីរស-២១ ........ ៦៥

ង. ឌុច ជាកម្មាភិបាលខ្មែរក្រហមដែលព្រម ធ្វើអ្វីទាំងអស់ដើម្បីថែរក្សាអំណាចនៅ ស-២១ ........ ៦៨

១.មិនមែនការងារតម្រូវឱ្យ ឌុចត្រូវតែធ្វើនោះទេ ប៉ុន្តែ ឌុចជាអ្នកបង្កើតការងារនោះ ........ ៧០

២. ឌុច ជាមនុស្សជឿងុបហួសហេតុទៅលើមនោគមន៍វិជ្ជាខ្មែរក្រហម ........ ៧១

៣. ឌុច ស្រឡាញ់ការងារជាប្រធានស-២១ និង អំណាចនេះ ........ ៧៣

៤. ឌុច នឹងធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីថែរក្សាអំណាច និង បុព្វសិទ្ធិ........ ៧៦

VI. សំណងជំងឺចិត្ត ........ ៧៩

ក. ការទាមទារជាក់លាក់សម្រាប់សំណងជំងឺចិត្ត ........ ៧៩

ខ. កាតព្វកិច្ចរបស់រដ្ឋនៅក្រោមច្បាប់អន្តរជាតិ ........ ៨៣

VII. សេចក្តីសន្និដ្ឋាន ........ ៨៨

## I. សេចក្តីផ្តើម

១. ដោយយោងទៅតាម "សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណងជំងឺចិត្ត និង អំពីការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ជាលាយលក្ខណ៍អក្សរ" អង្គជំនុំជម្រះនៃសាលាដំបូងបានកោះហៅភាគីឱ្យដាក់សេចក្តីសន្និដ្ឋានបញ្ចប់ជាលាយលក្ខណ៍អក្សរ ដើម្បីត្រៀមសម្រាប់សវនាការសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល។[១] ជាកិច្ចបន្តអណត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការ "គាំទ្រព្រះរាជអជ្ញា" ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង២៣(១)(ក) និងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ដើមបណ្តឹរដ្ឋប្បវេណីក្រុមទី១(CPG-1) សូមដាក់ជូនដោយក្តីគោរពនូវសារណាសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់។[២]

២. បន្ទាប់ពីរង់ចាំបញ្ចេញសម្លេងឱ្យគេឮអស់រយៈពេលជាង៣០ឆ្នាំ នៅទីបំផុត ជនរងគ្រោះនៅទួលស្លែងមានឱកាសបានមើលឃើញការធ្វើសន្និដ្ឋាន បង្ហាញភស្តុតាងនៅក្នុងសវនាការអ.វ.ត.កលើមេដឹកនាំខ្មែរក្រហមមួយរូបឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច។ សវនាការនេះមានលក្ខណៈពិសេសជាច្រើន។ ការដែលធ្វើឱ្យកត់សំគាល់បំផុតនោះ គឺដោយសារសវនាការនេះជាការជំនុំជម្រះក្តីអន្តរជាតិលើកតំបូងដែលជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១(CPG-1) បានខិតខំបំពេញកិច្ចការនេះយ៉ាងយកចិត្តទុកដាក់ ជួយអង្គជំនុំជម្រះសាលាដំបូងសម្រេចគោលដៅក្នុងការស្វែងរកការពិត និង ធានាឱ្យបានថាមានយុត្តិធម៌។[៣]

៣. សារណាសន្និដ្ឋានចុងក្រោយនេះមាន៦ផ្នែក។ ផ្នែកទី២ បកស្រាយពីតួនាទីរបស់ដើមបណ្តឹងនៅក្នុងកិច្ចនីតិវិធី។ ដើម្បីវាយតម្លៃពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ផ្នែកទី២នេះមានបញ្ចូលការប្រៀបធៀបគ្នារវាងថ្នាក់អន្តរជាតិ និង ថ្នាក់ជាតិ។ ផ្នែកទី៣ផ្តល់នូវការវិភាគតាមផ្លូវច្បាប់ពីបទដ្ឋានត្រួតពិនិត្យមើលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ផ្នែកទី៤បកស្រាយពីអង្គហេតុជាមូលដ្ឋានរបស់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១។ ផ្នែកទី៥និយាយពីភស្តុតាងនៅក្នុងសវនាការដែលដើមបណ្តឹងរដ្ឋប្បវេណីយល់ដោយក្តីគោរពថា បានបង្ហាញពីពិរុទ្ធភាពរបស់ចុងចោទនៅក្នុងបទដ្ឋាន

---

[១] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណងជម្ងឺចិត្ត និង ស្តីអំពីការដាក់សារណាជាលាយលក្ខអក្សរបញ្ចប់, ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០៩, E159, វាក្យខណ្ឌ ២។

[២] សូមមើល footnote ខាងលើ, សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណងជម្ងឺចិត្ត និង ស្តីអំពីការដាក់សារណាជាលាយលក្ខអក្សរបញ្ចប់, ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០៩, E159, វាក្យខណ្ឌ ៦។

[៣] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជាលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ២០០៣, បុព្វកថា [បន្ទាប់ពីនេះហៅថា "កិច្ចព្រមព្រៀង"]។

ព្រហ្មទណ្ឌមិនមានមន្ទិលសង្ស័យ ។ ជាចុងក្រោយ ផ្នែក៦នឹងមាននិយាយអំពីសំណងជម្ងឺចិត្តជាក់លាក់ស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ។

៤. ក្នុងការពិនិត្យមើលផ្នែកទាំងនេះ វាមានសារៈសំខាន់ដែលត្រូវចាំថា ដោយសារតែទង្វើរបស់ចុង-ចោទនេះ ការឈឺចាប់និងរបួសផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននៅតែកើតមាននៅឡើយ ។[៤] សំនួរនៅតែមាននៅឡើយទាក់ទងទៅនឹងការឈឺចាប់របស់សាច់ញាតិជនរងគ្រោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១(CPG-1) សុំអះអាងដោយក្តីគោរពថា សាលក្រមណាមួយសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវតែឆ្លុះបញ្ចាំងពីការពិតដោយសារថា សាលក្រមនោះទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ និងការឈឺចាប់របស់ជនរងគ្រោះ ។

៥. សារណាសន្និដ្ឋានចុងក្រោយដាក់ជូនដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១នឹងបង្ហាញថា ភស្តុតាងមិនមានបន្សល់នូវភាពសង្ស័យអ្វីទៀតទេ អំពីតួនាទីពិតប្រាកដរបស់ជនជាប់ចោទ ពេលធ្វើជាប្រធាន ស-២១ ។ ជាងនេះទៅទៀត ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី ការរំពឹងទុករបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមែនគ្មានទីបញ្ចប់ ឬ មិនសមទៅតាមការពិតជាក់ស្តែងនោះទេ ។[៥] ដើមបណ្តឹងរដ្ឋប្បវេណីតំណាងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មានគោលដៅសមហេតុផល ។ ពួកគាត់ចង់ឱ្យមានការទទួលខុសត្រូវ និងសំណងជម្ងឺចិត្ត ។ ក្នុងនេះរួមមានទាំងសិទ្ធិទទួលបានការពិត និងសិទ្ធិទទួលបានសំណងជម្ងឺចិត្ត ។ សារណាសន្និដ្ឋានបញ្ចប់នេះត្រូវបានដាក់ជូនដោយក្តីគោរព ដើម្បីស្វែងរកគោលដៅដូចបានបញ្ជាក់ខាងលើ ។

---

[៤] សូមមើល ឧទាហរណ៍ ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ទំព័រទី៨៤ ។ សូមមើល ប្រតិចារឹក ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ទំព័រ៥១-៥៨ ។

[៥] សូមមើល ឧទាហរណ៍ ប្រតិចារឹក ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ ៦៥-៦៨ ។

## II. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី

### ក. សេចក្តីផ្តើម

៦. ប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ បានបង្ហាញឱ្យឃើញនូវទំនោរជាទូទៅរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បង្កើនតួនាទីរបស់ជនរងគ្រោះនៃអំពើឃោរឃៅទ្រង់ទ្រាយធំ នៅក្នុងសវនាការរបស់តុលាការអាដហុក និងតុលាការអន្តរជាតិនានា។[៦] ការបង្កើតអ.វ.ត.កសម្គាល់ឱ្យឃើញពីការវិវឌ្ឍចុងក្រោយបង្អស់នៅក្នុងវិស័យនេះ ដោយផ្តល់ជូនជនរងគ្រោះនូវឱកាសក្នុងការចូលរួមជាភាគីនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងឡាយ ដែលមានឋានៈស្មើគ្នាជាមួយអយ្យការ និងក្រុមការពារក្តី។[៧] អ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុងទទួលស្គាល់ពីតួនាទីដ៏មានសារសំខាន់របស់ជនរងគ្រោះ ក្នុងការអនុវត្តយ៉ាងពេញលេញនៃអាណត្តិអ.វ.ត.ក[៨] ទាំងក្នុង"ការស្វែងរកយុត្តិធម៌"តាមរយៈការជួយជីកកកាយរកការពិត និង ក្នុងការកម្ពស់"ការផ្សះផ្សាជាតិ"[៩] ដោយសារតែជាប់ពាក់ព័ន្ធនឹងការចូលរួមជាបុគ្គលផ្ទាល់របស់ជនរងគ្រោះទាំងអស់នោះនៅក្នុងសវនាការ។[១០]

---

[៦] *សូមមើល* Timothy K. Kuhner, *ស្ថានភាពរបស់ជនរងគ្រោះនៅក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*, 6 Or. Rev. Int'l L. 95 (2004), ត្រង់ទំព័រ១៣៤ ("ទិដ្ឋភាពដែលគួរឱ្យកត់សម្គាល់មួយទាក់ទិននឹងការវិវត្តក្នុងការគិតអំពីច្បាប់ព្រហ្មទណ្ឌរយៈកាលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ គឺការកើនឡើងក្នុងការសង្កត់ធ្ងន់ទៅលើជនរងគ្រោះ"), *សូមមើលផងដែរ* Carsten Stahn et al., *ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីមុនការជំនុំជម្រះសេចក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ*. 4 J Int'l Crim. Just. 219 (2006), ត្រង់ទំព័រ ២២៦ (ចែងថា ការចូលពាក់ពន្ធ័របស់ជនរងគ្រោះនៅក្នុងដំណើការនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ "អាចត្រូវបានមើលឃើញថាជាអនុសាសន៍នៃទំនោរទូលំទូលាយជាងក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌ ដែលជាទូទៅផ្តល់ឱ្យជនរងគ្រោះអាចស្វែងរកយុត្តិធម៌បាន")។

[៧] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤), ត្រង់វិធាន ២៣(៦)(ខ)។

[៨] កិច្ចព្រមព្រៀង, បុព្វកថា។

[៩] ការទទួលតែស្ថានភាពរបស់ជនរងគ្រោះដែលរួមចំណែកដល់ការព្យាបាលរបួសរបស់ខ្លួន និងដល់ការព្យាបាលរបួសជាតិទាំងមូល។ Eduardo Vetere and Irene Melup, *ជនរងគ្រោះនៃឧក្រិដ្ឋកម្ម: ការចូលរួមចំណែករបស់អង្គការសហប្រជាជាតិដល់ការទប់ស្កាត់ឧក្រិដ្ឋកម្ម និងកម្មវិធីយុត្តិធម៌ព្រហ្មទណ្ឌ*, នៅក្នុងការឆ្លើយតបជាអន្តរជាតិទៅនឹងវិបត្តិផ្លូវចិត្ត, eds. Yael Danieli, Nigel S. Rodley & Lars Weiseth, Baywood Publishing Company, Inc: New York (1996), ត្រង់ទំព័រ៥២. ៥៥។

[១០] *សូមមើល ឧទាហរណ៍* Irvin Waller, *ជនរងគ្រោះនៃឧក្រិដ្ឋកម្ម: យុត្តិធម៌, ការគាំទ្រ និងសុវត្ថិភាព សាធារណៈ* នៅក្នុងការឆ្លើយតបជាអន្តរជាតិទៅនឹងវិបត្តិផ្លូវចិត្ត, eds. Yael Danieli, Nigel S. Rodley & Lars Weisaeth, Baywood

៧. ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺមិនមែនជារឿងថ្មី ប្លែកនោះទេ។ តុលាការទាំងកម្រិតជាតិ និងអន្តរជាតិបានទទួលស្គាល់ជាយូរយាមកហើយនូវការរួមចំណែកជាពិសេស ដែលជនរងគ្រោះអាចផ្តល់ជូននៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ក្នុងកម្រិតជាតិ ប្រទេសដែលអនុវត្តច្បាប់ស៊ីវិលឡ រួមមានប្រទេសបារាំង និងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យជនរងគ្រោះស្នើសុំព្រះរាជអាជ្ញាឱ្យផ្តួចផ្តើមដំណើរការនីតិវិធីព្រហ្មទណ្ឌ[១១] ឱ្យបង្ហាញភ័ស្តុតាងនៅក្នុងសំណុំរឿង[១២] ឱ្យចោទសួរសាក្សី ព្រមទាំងឱ្យធ្វើសេចក្តីថ្លែងការណ៍ជនរងគ្រោះនៅចំពោះមុខតុលាការ។[១៣] ក្នុងកម្រិតអន្តរជាតិ តុលាការបានកត់សម្គាល់នូវការកើនឡើងសិទ្ធិផ្តល់ជូនដល់ជនរងគ្រោះ នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី ។[១៤]

---

Publishing Company, Inc: New York (1996), ត្រង់ទំព័រ៨១ ( "ជនរងគ្រោះគឺជាប្រភពព័ត៌មានដ៏សំខាន់អំពីឧក្រិដ្ឋកម្ម និងឧក្រិដ្ឋជន"។), Gabriela Echeverria, *ការធ្វើឱ្យទៅជាច្បាប់នូវសិទ្ធិរបស់ជនរងគ្រោះនៅក្នុងច្បាប់អន្តរជាតិ: ការដោះស្រាយនិងការជួសជុលសំណងជំងឺចិត្ត, នៅក្នុង*ការដោះស្រាយឡើងវិញនូវភាពអយុត្តិធម៌ តាមរយៈដំណើរការទាមទារទ្រង់ទ្រាយធំ. ed. តុលាការអចិន្ត្រៃយ៍នៃការសម្រេចដោយអាជ្ញាកណ្តាល, Oxford University Press, Oxford (2006) ត្រង់ទំព័រ ២៩៦ (ការចូលរួមរបស់ជនរងគ្រោះក្នុងរឿងព្រហ្មទណ្ឌតាមរយៈការទាមទារសំណងជំងឺចិត្ត "មិនគ្រាន់តែផ្តល់ឱ្យមានការដោះស្រាយសម្រាប់ជនរងគ្រោះប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបម្រើដល់ផលប្រយោជន៍សហគមន៍ទៀតផង ដោយធ្វើការផ្តន្ទាទោសជនដែដល់ និងទប់ស្កាត់នូវការរំលោភបំពានក្នុងពេលអនាគត ដោយអ្នកព្រឹត្តដដែលៗ ឬដោយអ្នកដទៃផ្សេងទៀត។ វាបម្រើដល់នីតិរដ្ឋនៅគ្រប់មជ្ឈដ្ឋាននៃសង្គម និងជាធាតុផ្សំនៃយុត្តិធម៌ដ៏សំខាន់"។), Heidy Rombouts, *អង្គការជនរងគ្រោះនិងនយោបាយនៃសំណងជំងឺចិត្ត: ករណីសិក្សាលើប្រទេសរ្វាន់ដា.* Antwerp Intersentia Press, (2004) ត្រង់ទំព័រ ៣.៤ (យុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញកំពុងតែមានប្រជាប្រិយភាពជាជម្រើស ជំនួសយុត្តិធម៌ដែលមានលក្ខណៈផ្តន្ទាទោស ដែលគិតទុកថា ភាគីទាំងអស់ក្នុងជម្លោះរួមគ្នាដោះស្រាយជម្លោះនោះ"។

[១១] ក្រមនីតិវិធីព្រហ្មទណ្ឌ, ដាក់បញ្ចូលដោយច្បាប់លេខ ២០០០-៥១៦ ចុះថ្ងៃទី ១៥ មិថុនា ២០០០ មាត្រា ១ ព្រឹត្តបត្រផ្លូវការចុះថ្ងៃទី ១៦ មិថុនា ២០០០, មាត្រា១។

[១២] *សូមមើល* ក្រមព្រហ្មទណ្ឌបារាំង, មាត្រា ៣៣២។

[១៣] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ (ប្រទេសហូល្លង់) មាត្រា ៣០២(១), ៣៣៦(១)។

[១៤] *សូមមើល* លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, វិធានភ័ស្តុតាង និងនីតិវិធីនៃតុលាការពិសេសសម្រាប់ លីបាណន់, គោលការណ៍មូលដ្ឋាន និងការណែនាំស្តីអំពីសិទ្ធិទទួលបានការដោះស្រាយ និងសំណងជំងឺចិត្តដល់ជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្ស និងមនុស្សធម៌អន្តរជាតិ. Comm'n on Hum. Rts. Res 2005/30 U.N. Doc. E/2005/23 (Apr. 22, 2005), មាត្រា៧, វាក្យខណ្ឌ១១(ខ) - (គ)។

E159/7

៨. តាមរយៈនេះ វិធានផ្ទៃក្នុងរបស់អ.វ.ត.ក ចែងឱ្យជនរងគ្រោះចូលរួមដំណើការនីតិវិធីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងក្លាយទៅជាភាគីនៅក្នុងដំណើរការនេះទៀតផង។ បន្ថែមលើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការគាំទ្រអយ្យការ វិធានផ្ទៃក្នុងក៏ទទួលស្គាល់ការចូលរួមចំណែកជាពិសេសដែលដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ជូនចំពោះដំណើរការកាត់ទោស ការស្វែងរកការពិត និងការស្វែងរកយុត្តិធម៌។ ទោះបីជាយ៉ាងនេះក្តី សេចក្តីសម្រេចថ្មីៗមួយចំនួនដោយតុលាការដែលចង់ "គូសបញ្ជាក់" ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានច្បាស់លាស់នៅក្នុងដំណើការទាំងនេះ បានជះឥទ្ធិពលឱ្យមានការថយចុះនូវសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សេចក្តីសម្រេចទាំងនេះគឺផ្ទុយទៅនឹងភាសា កម្មវត្ថុ និងគោលបំណងនៃវិធានផ្ទៃក្នុងរបស់តុលាការខ្លួនឯង ហើយទន្ទឹមនោះបានកាត់បន្ថយនូវលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមចំណែកជួយសម្រេចគោលបំណងទាំងនោះ។ ជាចុងក្រោយ ការបន្តដាក់កម្រិតតួនាទីរបស់ជនរងគ្រោះនឹងកាត់បន្ថយអណាត្តិដ៏សំខាន់របស់អ.វ.ត.ក និងភាពស្របច្បាប់របស់ខ្លួនពីសំណាក់ប្រជាជនកម្ពុជាទាំងមូល។ នៅពេលនេះ អង្គជំនុំជម្រះត្រូវតែធ្វើឱ្យមាំឡើងវិញនូវគោលដៅដើមរបស់អ្នករៀបចំបង្កើតស្ថាប័នមួយនេះ និង បញ្ជាក់សាជាថ្មីឡើងវិញនូវគោលនយោបាយទូលាយសមរម្យចំពោះការចូលរួមរបស់ជនរងគ្រោះនៅក្នុងការបោះជំហានទៅមុខ។

## ខ. វិធានផ្ទៃក្នុងរបស់អ.វ.ត.ក

៩. វិធានផ្ទៃក្នុង ២៣ ផ្តល់ សិទ្ធិចូលរួមយ៉ាងទូលំទូលាយដោយដើមបណ្តឹងរដ្ឋប្បវេណី ដោយចែងថាគោលបំណងនៃបណ្តឹងរដ្ឋប្បវេណីគឺដើម្បី *"ចូលរួមដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់"*។[១៥] នៅពេលដែលពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ *"ជនរងគ្រោះក្លាយជាភាគីក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌ"*។[១៦] ដំណោះស្រាយដែលបានដាក់បញ្ចូលនេះស្តែងឱ្យឃើញនៅក្នុងវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណី "ចូលរួម" តាមវិធីច្រើនបែប នៅគ្រប់ដំណាក់កាលនីតិវិធីទាំងអស់។

---

[១៥] វិធាន (វិសោធនកម្មលើកទី៤) , វិធាន ២៣(១)(ក) (ការសង្កត់សម្លេងត្រង់ចំណុចនេះ)។

[១៦] សូមមើល footnote ខាងលើ, វិធាន ២៣(៦) (ការសង្កត់សម្លេងត្រង់ចំហុចនេះ)។

១០. ជាការចាប់ផ្តើម វិធាន៩១(១) កំណត់ចេញគោលការណ៍ដ៏ទូលាយដែលថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានស្តាប់: ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យផ្តល់ចម្លើយដល់អង្គជំនុំជម្រះ[១៧] និងអាចចោទសួរទៅកាន់សាក្សី និងជនជាប់ចោទ តាមរយៈមេធាវីរបស់ខ្លួន។[១៨] ដើមបណ្តឹងរដ្ឋប្បវេណីក៏មានសិទ្ធិស្នើសុំឱ្យមានការស៊ើបអង្កេតបន្ថែម បន្ទាប់សហចៅក្រមស៊ើបអង្កេតបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន[១៩] ទទួលការជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះភ្លាមៗបន្ទាប់ពីការចេញដីកានេះ[២០] ដាក់សារណាផ្សេងៗ[២១] រួមទាំងបញ្ជីឈ្មោះសាក្សីដែលអញ្ជើញមកផ្តល់សក្ខីកម្ម[២២] បញ្ជីភ័ស្តុតាងដែលចង់ដាក់[២៣] ព្រមទាំងបញ្ហាច្បាប់មួយចំនួនដែលខ្លួនចង់លើកឡើង។[២៤]

១១. ហេតុដូច្នេះ វិធានផ្ទៃក្នុងផ្តល់លទ្ធភាពឱ្យដើមបណ្តឹងរដ្ឋប្បវេណី "គាំទ្រដល់ការចោទប្រកាន់" ដោយអនុញ្ញាតឱ្យចូលរួមចំណែកជីកកកាយរកការពិត ដោយសួរសំណួរតាមការយល់ឃើញពិសេស និងដោយផ្តល់ខ្លឹមសារស៊ីជម្រៅផ្នែកច្បាប់ និង អង្គហេតុក្នុងនាមភាគីឯករាជ្យនៃដំណើរការនីតិវិធី។[២៥] ទោះបីជាយ៉ាងណាក៏ដោយ អត្ថន័យពិតប្រាកដនៃពាក្យ "ការគាំទ្រដល់ការចោទប្រកាន់" ត្រូវបានជជែកដេញដោលយ៉ាងយូរនៅពេលសវនាការ ដែលក្នុងនោះមេធាវីការពារក្តីតែងតែលើកឡើងជាញឹកញាប់ថាដើមបណ្តឹងរដ្ឋប្បវេណីដើរតួជា "ព្រះរាជអាជ្ញាទី២"[២៦] ដែលបន្ទាប់ពីនោះមកអង្គជំនុំជម្រះបានស្វះស្វែង

---

[១៧] សូមមើល footnote ខាងលើ, វិធាន ២៤(២) ។

[១៨] សូមមើល footnote ខាងលើ, វិធាន ៩១(២) ។

[១៩] សូមមើល footnote ខាងលើ, វិធាន ៦៦(១) ។

[២០] សូមមើល footnote ខាងលើ, វិធាន ៦៧(៥) ។

[២១] សូមមើល footnote ១៥ នៅវាក្យខណ្ឌ ១៥ (para. 15) ។ ចៅក្រមម្នាក់នោះបានថ្លែងថា នៅក្នុងប្រទេសខ្ទេចខ្ទាំដោយសង្គ្រាមដូចជាអ៊ុយហ្គាន់ដា វាគឺ "...មិនត្រឹមត្រូវទេក្នុងការរំពឹងឱ្យជនរងគ្រោះអ្នកដាក់ពាក្យបណ្តឹងផ្តល់នូវភ័ស្តុតាងបង្ហាញអត្តសញ្ញាណដូចអ្នកផ្សេងទៀតរស់នៅតំបន់ដែលមិនជួបប្រទះការលំបាកដូចគ្នានេះ" ។ សូមមើល footnote១៥ នៅវាក្យខណ្ឌ ១៦ ។ សូមមើល footnote ខាងលើ, វិធាន ៧៩(៥) ។

[២២] សូមមើល footnote ខាងលើ, វិធាន ៧៩(៥)(ក) ។

[២៣] សូមមើល footnote ខាងលើ, វិធាន ៧៩(៥)(ខ) ។

[២៤] សូមមើល footnote ខាងលើ, វិធាន ៧៩(៥)(គ) ។

[២៥] សូមមើល footnote ខាងលើ, វិធាន ២៣(១)(ក) ។

[២៦] ប្រតិចារឹក ២២ មិថុនា ២០០៩ ទំព័រ៩១-៩២ ។

បញ្ជាក់អំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី មួយករណីម្តងៗ។[២៧] ជាឧទាហរណ៍ បន្ទាប់ពីការពិភាក្សាដេញដោលយ៉ាងច្រើនជុំវិញសំណួរចោទសួរដោយមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីអាចសួរសំណួរបាន ដរាបណាមិនមែនជាសំណួរច្រំដែល "សំណួរវែងអន្លាយ" ឬក៏ចាកក្រៅប្រធានបទ។[២៨] បើទោះបីជាការសម្រេចទៅតាមមួយករណីម្តងៗជួយបញ្ជាក់ដល់ទំហំនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏វានៅតែបន្តផ្តល់ឱកាសដល់ការជំទាស់ជាច្រើនពីសំណាក់មេធាវីការពារក្តី ដែលនេះបន្តពន្យាពេលសវនាការ និង ការពន្យាដល់ពេលចេញសាលក្រមចុងក្រោយ។[២៩]

១២. នេះជាការយល់ឃើញដោយគោរពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ថា ចរិតលក្ខណៈនៃតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងនាមជា "ការគាំទ្រដល់ការចោទប្រកាន់" ឱ្យដឹងអំពីទំហំពិសេស និងធំទូលាយ ដែលពួកគេត្រូវបានអនុញ្ញាតឱ្យចូលរួម។ ទោះបីជាយ៉ាងនេះក្តី ផលប្រយោជន៍ និងលទ្ធភាពរបស់ព្រះរាជអជ្ញារ និង របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនស្មើគ្នាទាំងស្រុងទេ។ ផលប្រយោជន៍របស់ព្រះរាជអជ្ញារ ជាធម្មតាទាក់ទិននឹងការធានាឱ្យមានការដាក់ទោសដល់ជនជាប់ចោទ។[៣០] ដើមបណ្តឹងរដ្ឋប្បវេណីផ្តោតទៅលើការបារម្ភផ្សេងៗទៀតដូចជា ប្រើប្រាស់ភស្តុតាងដែលពាក់ព័ន្ធនឹងការផ្តល់សំណងជម្ងឺចិត្ត[៣១] វាស់ស្ទង់ភាពស្មោះត្រង់នៃការសុំអភ័យទោសរបស់ជនជាប់ចោទ[៣២] ព្រមទាំងបន្ថែមជាទូទៅ

---

[២៧] សូមមើល footnote ខាងលើ, *ត្រង់ទំព័រ ៩២* ។

[២៨] សូមមើល footnote ខាងលើ។

[២៩] *សូមមើល* ប្រតិចារឹក ២៧ សីហា ២០០៩, ទំព័រ ៧៤។ អង្គជំនុំជម្រះ ដោយគំនិតផ្តួចផ្តើមខ្លួនឯង បានចេញសេចក្តីសម្រេចផ្ទាល់មាត់ បិទទ្វារមិនឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចោទសួរជនជាប់ចោទ ឬ សាក្សីជំនាញទាក់ទិននឹងអត្តចរិតរបស់ជនជាប់ចោទ។

[៣០] *Commentary to the Second Preparatory Commission on Rules of Procedure and Elements of Crimes*, Hum. Rts. Watch, July 1999, *available at* http://www.iccnow.org/documents/HRWComment2ndPrepComJuly99.pdf (និយាយថា "បណ្តឹងរបស់ព្រះរាជអាជ្ញាគ្រប់គ្រងភាគច្រើនដោយបំណងប្រាថ្នាចង់បានឱ្យទទួលជោគជ័យលើការកាត់ឱ្យជាប់ទោស")។

[៣១] *ស្ថានភាពនៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, សំណុំរឿងលេខ* ICC-01/04-101, សេចក្តីសម្រេចលើការដាក់ពាក្យសុំចូលរួមនៅក្នុងដំណើរការនីតិវិធីនៃ VPRS 1, VPRS 2, VPRS 3, VPRS 4, VPRS 5 and VPRS 6, ១៧ មករា ២០០៦. វាក្យខណ្ឌ ៧២ ("ការភ្ជាប់យ៉ាងជិតស្និទ្ធជាមួយផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះ និង ការស៊ើបអង្កេត

នូវការយល់ឃើញផ្ទាល់ខ្លួនទៅលើការបង្ហាញភស្តុតាង។ នេះធ្វើឱ្យអង្គជំនុំជម្រះអាចមានទិដ្ឋភាពពេញលេញជាងមុន ទាក់ទិននឹងព្រឹត្តិការណ៍ចោទ ព្រមទាំងបញ្ចូលរឿងរ៉ាវនៃព្រឹត្តិការណ៍មានលក្ខណៈពេញលេញជាងមុនទៅក្នុងសាលក្រម បើទោះបីជាអង្គហេតុជាក់លាក់នីមួយៗអាចផ្តល់ជាភស្តុតាងនៃធាតុផ្សំបទល្មើសចំពោះទំហំតូចចង្អៀតនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ក៏ដោយ។ បើពិនិត្យមើលពីពេលវេលាដែលកន្លងផុតទៅយូរចំពោះព្រឹត្តិការណ៍នេះ និង ការលំបាករកភស្តុតាងដែលតុលាការកំពុងជួបប្រទះ ដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីពិសេសក្នុងការប្រមូលសក្ខីកម្ម ដែលអាចបំភ្លឺដល់ការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ឧទាហរណ៍ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានជួយទាញយកសក្ខីកម្មពីសំណាក់អ្នកជំនាញបណ្ឌិត គ្រេក អេចផែស៊ិន (Dr. Craig Etcheson) ទាក់ទិននឹងតួនាទីជនជាប់ចោទក្នុងសរសេរចំណារដោយផ្ទាល់លើចម្លើយសារភាពរបស់អ្នកទោស ជាដើម។[៣៣]

១៣. ជាងនេះទៅទៀត គោលបំណងរបស់វិធានផ្ទៃក្នុងហាក់បីដូចជាមានលក្ខណៈច្បាស់លាស់ហើយ ដូចជាផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិដ៏ទូលំទូលាយដែលអាចឱ្យខ្លួនចូលរួមស្មើរតែដូចគ្នាទៅនឹងខាងព្រះរាជអាជ្ញារ និងខាងមេធាវីការពារក្តីដែរ។ សេចក្តីសម្រេចថ្មីៗនេះរបស់អង្គជំនុំជម្រះ ដែលបានកម្រិតតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីកាន់តែខ្លាំង គឺប្រឆាំងនឹងស្មារតី និងគោលបំណងពិតប្រាកដនៃវិធាន

គឺរឹតតែសំខាន់នៅក្នុងរបៀបដែលបង្កើតឡើងដោយលក្ខន្តិកៈទីក្រុងរ៉ូម ដោយគិតពីប្រសិទ្ធភាពដែលថា ការស៊ើបអង្កេតបែបនេះអាចមានដីកាក្នុងពេលអនាគតសម្រាប់សំណងជំងឺចិត្ត...)។

[៣២] សូមមើលឧបសម្ពន្ធ "ខ" ចំពោះការពិភាក្សាបន្ថែមអំពីការវាយតម្លៃលើការសុំអភ័យទោសរបស់ជនជាប់ចោទ បើប្រៀបធៀបទៅនឹងគណៈកម្មការស្វែងរកការពិត។

[៣៣] ប្រតិចារឹត ២៨ ឧសភា ២០០៩ ទំព័រ ១៨-១៩ និង ប្រតិចារឹត ៨ មិថុនា ២០០៩ ទំព័រ ៧៨-១០១។ លោករ៉ឺន័រ ប្រមូលបានភស្តុតាងពីលោកបណ្ឌិត អេចផែស៊ិន ទាក់ទិននឹងចំណារ និងសេចក្តីព្រាងនៃបញ្ជីអ្នកទោសដែលមិនទាន់ទទួលបាន និងបន្តផ្ចិតទៅទៀតនៅខណៈដែលកំពុងចោទសួរជនជាប់ចោទដោយផ្អែកលើសក្ខីកម្មរបស់បណ្ឌិត អេចផែស៊ិន។ ភាពអង់អាចដ៏សំខាន់នេះត្រូវបានរៀបចំដោយអ្នកឃ្លាំមើលការកាត់ទោស។ *សូមមើលផងដែរ* របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហម, *ព្រះរាជអាជ្ញា ទល់នឹង កាំង ហ្គេកអ៊ាវ, ហៅ ឌុច*, របាយការណ៍លេខ ៧: ចុងសប្តាហ៍ ១៤ មិថុនា ២០០៩, ត្រង់ទំព័រ ១: "ក្នុងការឆ្លើយតបនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ឌុច បានសារភាពពីតួនាទីផ្ទាល់ខ្លួនក្នុងការឈ្លេចយកចម្លើយ និងចារលើចម្លើយសារភាពរបស់អ្នកទោស"។

00399985

E159/7

ផ្ទៃក្នុង។[៣៤] នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមិនអាចអនុវត្តនូវសិទ្ធិមួយចំនួន ដែលផ្តល់ឱ្យទៅតែព្រះរាជអាជ្ញានិងមេធាវីការពារក្តី វិធានផ្ទៃក្នុងបានចែងច្បាស់លាស់ណាស់នូវសិទ្ធិបែបនេះ។[៣៥] គោលជំហរទូទៅគួរតែរក្សានៅដដែលថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងនៅតែរក្សាបាននូវសិទ្ធិទូលំទូលាយមានចែងនៅក្នុងវិធានផ្ទៃក្នុង ដោយរួមទាំងសិទ្ធិចូលរួមសួរដេញដោលជនជាប់ចោទ និង សាក្សីលើគ្រប់ប្រធានបទ ដោយពុំអនុញ្ញាតឱ្យមានការរារាំងជាលក្ខណៈពស្តុភារដល់ការចូលរួមចំណែកយ៉ាងមានតម្លៃរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើការនីតិវិធីឡើយ។

### គ. ការអនុវត្តនៅតុលាការអន្តរជាតិនានា

១៤. វិធាន២ ចែងថា ប្រសិនបើមានចន្លោះប្រហោងណាមួយកើតមានឡើង អង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្តដោយស្របទៅតាម "មាត្រា១២(១)នៃកិច្ចព្រមព្រៀង និង មាត្រា២០ថ្មី, ២៣ថ្មី, ៣៣ថ្មី ឬមាត្រា៣៧ថ្មី នៃច្បាប់អ.វ.ត.ក ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន២១ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន"។ ច្បាប់អ.វ.ត.ក ចែងថា អង្គជំនុំជម្រះអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។[៣៦]

---

[៣៤] ប្រតិចារឹត ២៧ សីហា ២០០៩ ទំព័រ ៧៤. (ដោយហាមប្រាមមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីសួរជនជាប់ចោទ ឬសាក្សីផ្សេងៗទៀត អំពីអត្តចរិតរបស់ជនជាប់ចោទ), *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីសម្រេចលើសំណើរួមគ្នារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ការសម្រេចលើជំហររបស់មេធាវីដើមបណ្តឹងរដ្ឋវេណី ក្នុងការដាក់សំណើសុំឱ្យមានការវិនិច្ឆ័យទោស និងការណែនាំទាក់ទិននឹងការចោទសួរទៅជនជាប់ចោទ, អ្នកជំនាញ និង សាក្សីដែលផ្តល់សក្ខីកម្មអំពីអត្តចរិត, ១២ តុលា ២០០៩, ឯកសារលេខ E72/3 ។ ប្រតិចារឹត ២៧ សីហា ២០០៩ ទំព័រ ៤១-៤២ (ហាមប្រាមមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីសួរសាក្សី ឬជនជាប់ចោទលើអត្តចរិត ឬធ្វើការស្នើសុំឱ្យមានការវិនិច្ឆ័យ ទោស)។

[៣៥] *សូមមើល* វិធានផ្ទៃក្នុង ៨២(៣) ដែលទាក់ទិននឹងការឃុំខ្លួនបណ្តោះអាសន្ន និងធានាឱ្យនៅក្រៅឃុំ។ វិធានចែងថា អង្គជំនុំជម្រះត្រូវសម្រេច, "បន្ទាប់ពីបានស្តាប់សហព្រះរាជអាជ្ញា ជនជាប់ចោទ និងមេធាវីជនជាប់ចោទ"។ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានបញ្ចូលនៅក្នុងវិធាននេះទេ។ *សូមមើលផងដែរ* វិធានផ្ទៃក្នុង១០៥(១)(គ)ដែលចែងថា "បណ្តឹងឧទ្ធរណ៍អាចត្រូវបានប្តឹងដោយដើមបណ្តឹងរដ្ឋប្បវេណី ... តែពេលដែលសហព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ប៉ុណ្ណោះ"។

[៣៦] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ, ដោយមានការដាក់បញ្ចូលវិសោធនកម្មដែលប្រកាសឱ្យប្រើនៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ (នស.រកម.១០០៤.០០៦), មាត្រា ៣៣ថ្មី។

១៥. តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចអ.វ.ត.កដែរ ចែងឱ្យមានទម្រង់ចូលរួមរបស់ជនរងគ្រោះធំទូលាយ។ ការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ទំនងជាតិចតួចជាងដោយផ្តល់ឱ្យជនរងគ្រោះលទ្ធភាពអាចសម្តែង"ទស្សនៈ និងការព្រួយបារម្ភ"តាមឆន្ទានុសិទ្ធិរបស់តុលាការដរាបណា"ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះត្រូវបានប៉ះពាល់"[៣៧] ព្រមទាំង"មិនរំលោភលើសិទ្ធិចុងចោទក្នុងការទទួលបានការវិនិច្ឆ័យសេចក្តីប្រកបដោយត្រឹមត្រូវនិងមិនលម្អៀង"។ ប៉ុន្តែ ការអនុវត្តជាក់ស្តែងបង្ហាញថា ជនរងគ្រោះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិទទួលបានសិទ្ធិចូលរួមច្រើន។

១៦. ដូចដែលអង្គបុរេជំនុំជម្រះពន្យល់នៅក្នុងរឿងក្តីកាតាំងហ្កា (Katanga) ផលប្រយោជន៍របស់ជនរងគ្រោះ "ហួសពីការសម្រេចត្រឹមតែអ្វីដែលបានកើតឡើង និងពីត្រឹមតែការកំណត់អត្តសញ្ញាណអ្នកទទួលខុសត្រូវ និង អូសបន្លាយដល់ទៅការធានាឱ្យមានការដាក់ទោសទណ្ឌក្នុងកម្រិតណាមួយដល់អ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។"[៣៨] ដើម្បីសម្រួលការចូលរួមរបស់ខ្លួននៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិជនរងគ្រោះត្រូវបានផ្តល់ជូននូវសិទ្ធិជាច្រើនដូចជា សិទ្ធិបង្ហាញភស្តុតាង និងជំទាស់លើភស្តុតាង[៣៩] សិទ្ធិសួរដេញដោលសាក្សី[៤០] សិទ្ធិដាក់សារណាផ្នែកច្បាប់[៤១] សិទ្ធិថ្លែងការណ៍បើកនិងបិទ[៤២] ព្រមទាំងសិទ្ធិចូលរួមក្នុងសវនាការឃុំខ្លួនបណ្តោះអាសន្នជាដើម។[៤៣]

---

[៣៧] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, A/CONF.183/9, ១៧ កក្កដា ១៩៩៨, មាត្រា ៦៨(៣)។

[៣៨] *សូមមើល Prosecutor v. Germain Katanga and Mathieu Ngudjolo Chui,* ICC-01/04-01/07, សេចក្តីលើការកំណត់វិធាននីតិវិធីដែលភ្ជាប់នឹងស្ថានភាពខាងនីតិវិធីរបស់ជនរងគ្រោះនៅដំណាក់មុនការជម្រះអង្គសេចក្តីលើសំណុំរឿង, អង្គបុរេជំនុំជម្រះ ១ (ដែលមានចៅក្រមម្នាក់), ១៣ ឧសភា ២០០៨, វាក្យខណ្ឌ ៣៨ (ការយោងផ្ទៃក្នុងត្រូវបានលប់ចោល)។

[៣៩] *Prosecutor v. Germain Katanga and Mathieu Ngudjolo Chui,* ICC-01/04-01/06-1119, សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ, ១៨ មករា ២០០៨, វាក្យខណ្ឌ ១០៨។

[៤០] សូមមើល footnote ខាងលើ។

[៤១] សូមមើល footnote ខាងលើ, វាក្យខណ្ឌ ១១៧។

[៤២] សូមមើល footnote ខាងលើ។

[៤៣] *The Prosecutor v. Thomas Lubanga Dyilo,* សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និង មេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ", ១៦ ឧសភា ២០០៨, វាក្យខណ្ឌ ៥១។

១៧. ដូចគ្នានេះដែរ វិធានទីតិវិធីរបស់តុលាការពិសេសសម្រាប់ប្រទេសលីបាណន់ ដែលមានមូលដ្ឋានលើក្រមរដ្ឋប្បវេណីបារាំង អនុញ្ញាតឱ្យជនរងគ្រោះមានសិទ្ធិមើលឯកសារ និង សារណាផ្សេងៗនៅក្នុងសំណុំរឿង[៤៤] សួរដេញដោលសាក្សី និងបង្ហាញភស្តុតាង[៤៥] ព្រមទាំងធ្វើសេចក្តីថ្លែងការណ៍ជនរងគ្រោះក្នុងដំណាក់កាលដាក់ទោស។[៤៦] ជនរងគ្រោះអាចចូលរួមនៅក្នុងដំណាក់កាលប្តឹងឧទ្ធរណ៍ថែមទៀត "តាមរបៀបដែលអង្គជំនុំជម្រះឧទ្ធរណ៍យល់ថាសមរម្យ"។[៤៧]

១៨. យុត្តិសាស្ត្រដែលបានកើតមានឡើង និង វិធានទីតិវិធីនិងភស្តុតាងបង្ហុលបង្ហាញថា ការចូលរួមរបស់ជនរងគ្រោះគឺមានភាពជាក់ស្តែងកាន់តែសំខាន់ឡើងៗ នៅក្នុងតុលាការអាដហុក និង តុលាការអន្តរជាតិនានា។ វិធីសាស្ត្រជាទូទៅដែលត្រូវបានអនុម័តយក គឺដោយផ្អែកទៅលើការដែលថា ការចូលរួមរបស់ជនរងគ្រោះនឹង*មិនត្រូវ*មានកម្រិតទេ ដរាបណាមិនប៉ះពាល់ដល់សិទ្ធិសំខាន់ៗរបស់ជនជាប់ចោទចោទ។ វិធានផ្ទៃក្នុងអ.វ.ត.ក បានឆ្លុះបញ្ចាំងនូវគោលជំហរនេះ ដោយផ្តល់ដល់ជនរងគ្រោះនូវសិទ្ធិចូលរួមពេញលេញក្នុងដំណើការទីតិវិធី ដោយកំហិតតែការចូលរួមតិចតួច ដែលមានចែងបញ្ជាក់ច្បាស់លាស់នៅក្នុងវិធាន។

## ឃ. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

១៩. ដោយពុំមានការណែនាំគ្រប់គ្រាន់នៅក្នុងវិធានផ្ទៃក្នុង និងច្បាប់អន្តរជាតិ ទាក់ទិននឹងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការអាចពិចារណាលើច្បាប់កម្ពុជាដោយអនុលោមតាមមាត្រា១២(១)នៃកិច្ចព្រមព្រៀង។ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដូចវិធានផ្ទៃក្នុងរបស់អ.វ.ត.កដែរ[៤៨] គឺផ្តល់ឱ្យជនរងគ្រោះដាក់ភ្ជាប់នូវបណ្តឹងទាមទារសំណងជំងឺចិត្តទៅក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌ និងចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបអង្កេត[៤៩] ឬក៏នៅដំណាក់កាលក្រោយមកទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។[៥០] ដោយយកតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា វិធានផ្ទៃក្នុងអ.វ.ត.កផ្តល់ឱ្យ

---

[៤៤] វិធានទីតិវិធី និងភស្តុតាង, តុលាការពិសេសសម្រាប់ប្រទេសលីបាណន់, វិធាន ៨៧(ក)។

[៤៥] វិធានទីតិវិធី និងភស្តុតាង, តុលាការពិសេសសម្រាប់ប្រទេសលីបាណន់, វិធាន ៨៧(ខ)។

[៤៦] វិធានទីតិវិធី និងភស្តុតាង, តុលាការពិសេសសម្រាប់ប្រទេសលីបាណន់, វិធាន ៨៧(គ)។

[៤៧] វិធានទីតិវិធី និងភស្តុតាង, តុលាការពិសេសសម្រាប់ប្រទេសលីបាណន់, វិធាន ៨៧(ឃ)។

[៤៨] វិធានផ្ទៃក្នុង ២៣(៦)(ក) និង ២៣(១)(ក)។

[៤៩] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា. មាត្រា ១៣៧, ១៣៨។

[៥០] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ២៩១(៣),(៤), ៣១១។

ដើមបណ្ដឹងរដ្ឋប្បវេណីនូវសិទ្ធិស្មើគ្នា ឱ្យបញ្ចេញមតិក្នុងអំឡុងពេលដំណើការនីតិវិធី[៥១] ព្រមទាំងសិទ្ធិធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយនៅដំណាក់កាលបញ្ចប់សវនាការ។[៥២] បន្ថែមពីលើនេះទៀត ក្នុងករណីខ្លះការដកពាក្យបណ្ដឹងទាមទារជម្ងឺចិត្តរបស់ជនរងគ្រោះ អាចនឹងរំលត់ដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងមូលបាន។[៥៣] ដូច្នេះ វិធានផ្ទៃក្នុងត្រូវតែគ្នានឹងការអនុវត្តជាក់ស្ដែងនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលអនុញ្ញាតឱ្យជនរងគ្រោះមានសិទ្ធិចូលរួមយ៉ាងទូលំទូលាយ។

### ខ. តុលាការក្នុងស្រុក

២០. យុត្តាធិការច្បាប់ស៊ីវិលឡជាច្រើនអនុញ្ញាតឱ្យមានទម្រង់ផ្សេងៗគ្នានៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ នៅប្រទេសបារាំង ជាឧទាហរណ៍ ជនរងគ្រោះអាចចូលរួមដាក់ពាក្យបណ្ដឹងទាមទារសំណងជំងឺចិត្តសម្រាប់ការខូចខាតនៅក្នុងរឿងព្រហ្មទណ្ឌ ដែលក្លាយទៅភាគីមួយនៅក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌ ក្នុងគោលបំណងបង្ហាញពីបណ្ដឹងទាមទារសំណងជំងឺចិត្តរបស់ខ្លួន។[៥៤] ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិពិនិត្យមើលកន្លែងស្ថិតក្រោមការស៊ើបអង្កេត ស្ដាប់សាក្សីដូចជនត្រូវ-ចោទដែរ[៥៥] ព្រមទាំងអាចផ្ដល់នូវការអង្កេតលើសក្ខីកម្មផ្ដល់ដោយសាក្សីទៀតផង។[៥៦]

### ឆ. សេចក្ដីសន្និដ្ឋាន

២១. ក្រោយពីមានការស្ងប់ស្ងៀមអស់រយៈពេលជាង៣០ឆ្នាំកន្លងមក ជនរងគ្រោះស-២១អាចចែករំលែករឿងរ៉ាវ និងទិដ្ឋភាពនានា ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើការនីតិវិធីអ.វ.ត.ក។ ដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងបង្រួបបង្រួមជាតិតាមរយៈការផ្ដល់រឿងរ៉ាវរបស់ខ្លួនអំពីព្រឹត្តិការណ៍ដូចបានកើតមានឡើងកាលពី៣០ឆ្នាំកន្លងទៅ ហើយតាមរយៈនេះ បានចាប់ផ្ដើមនិយាយអំពីអំពើឃោរឃៅនេះ។ លើសពីនេះទៅទៀត តាមរយៈមេធាវីរបស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណីអាចលើកពិសេស និងច្បាស់ៗ អំពីអង្គហេតុ[៥៧] និងច្បាប់[៥៨] នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

---

[៥១] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៣២៦។

[៥២] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៣៣៥។

[៥៣] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៨។

[៥៤] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៣។

[៥៥] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៨២(២)។

[៥៦] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១៦៥។

[៥៧] *សូមមើល សេចក្ដីយោងពីខាងដើម*, Footnote ៣៣។

ហើយតាមរយៈនេះ បានចូលរួមចំណែកដ៏ធំធេងដល់ភាពស្របច្បាប់នៃដំណើរការជំនុំជម្រះ។ បើពិនិត្យមើលអំពីការចូលរួមចំណែកដ៏សំខាន់ទាំងនេះ អង្គជំនុំជម្រះមិនត្រូវសរសេរវិធានឡើងវិញ ដើម្បីកាត់បន្ថយការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ បើទោះជាក្នុងគោលបំណងធ្វើឱ្យមានប្រសិទ្ធភាព និងរហ័សជាងមុនក៏ដោយ។ ការបំបិទសម្លេង ឬ កំហិតសម្លេងរបស់ជនរងគ្រោះ ពុំមានការគាំទ្រនៅក្នុងច្បាប់ កម្មវត្ថុ និង គោលបំណងនៃវិធានផ្ទៃក្នុង ឬ នៅក្នុងការអនុវត្តក្នុងស្រុកក៏ដូចជាអន្តរជាតិដែរ។ អាស្រ័យហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សូមធ្វើអះអាងដោយសេចក្តីគោរពថា ដោយយោងទៅលើទំនោរអនុវត្តថ្មីៗនេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែរក្សាឱ្យនៅស្មើគ្នាជាមួយនឹងខាងព្រះរាជអជ្ញារនិងខាងមេធាវីការពារក្តី លើកលែងតែមានការកំហិតផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង។ សារសំខាន់នៃការជំនុំជម្រះក្តីនេះ និង ការចូលរួមជាបន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ តម្រូវឱ្យមានការបញ្ជាក់ច្បាស់លាស់អំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលគួរតែត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ក្នុងបរិបទនៃវិធានផ្ទៃក្នុង និង អណត្តិរបស់តុលាការ។[៩៥]

---

[៩៤] *សូមមើល សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ក្រុម១-សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើថា អង្គជំនុំជម្រះសាលាដំបូងត្រូវសម្របសម្រួលដល់ការបើកចំហលើរបាយការណ៍ UN-OIOS ដល់ភាគី, ១១ ឧសភា ២០០៩, ឯកសារលេខ ០០៣២៧៩១០-១៩-E៦៥។ ដើមបណ្តឹងរដ្ឋវេណីក្រុម១ ដាក់ជូនសំណើនេះទាក់ទងនឹងអំពើពុករលួយដែលជំទាស់នឹងកំណត់សម្គាល់របស់សហព្រះរាជអាជ្ញា។

[៩៥] សំណួរអំពីទំហំនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងមានសារៈសំខាន់ជាពិសេស នៅពេលចាប់ផ្តើមករណី០០២ ដែលជនរងគ្រោះប្រមាណ២ពាន់នាក់បានដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ។ ភាពមិនច្បាស់លាស់ជាបន្តអំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងប្រាកដជាធ្វើប៉ះពាល់ដល់ការប្រព្រឹត្តទៅ និង ពេលវេលាសវនាការ ក៏ដូចជាភាពស្របច្បាប់របស់តុលាការ។

00399990



## III. បទដ្ឋានច្បាប់សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

### ក. សេចក្តីផ្តើម

២២. នៅពេលជនរងគ្រោះដាក់ពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីទទួលបានការត្រួតពិនិត្យដោយអង្គជំនុំជម្រះសាលាដំបូងនៅសវនាការបឋម បេក្ខជនទាំងនេះមិនបានគិតថា ពួកគេនឹងនៅមិនច្បាស់លាស់ថាតើពួកគេនឹងនៅតែជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងដដែលទៀតឬទេ នៅប្រមាណជាពីរសប្តាហ៍ប៉ុណ្ណោះ មុនពេលបញ្ចប់សវនាការជំនុំជម្រះ។ វិធានផ្ទៃក្នុងផ្តល់នូវការណែនាំតិចតួចប៉ុណ្ណោះចំពោះបទដ្ឋានផ្លូវច្បាប់នៅក្នុងការសម្រេចលើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ជាពិសេសគឺវាយឺតពេលណាស់ទៅហើយនៅពេលនេះ។ ការនេះបាននាំឱ្យអង្គជំនុំជម្រះសាលាដំបូង អញ្ជើញឱ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវការវិភាគរបស់ពួកគេអំពីបញ្ហានេះនៅក្នុងសេចក្តីសារណាបញ្ចប់រៀងៗខ្លួន។[៦០] បន្ថែមទៅលើអំណះអំណាងដែលលើកឡើងដោយលោកអាឡាំង វឺន័រ[៦១] ដែលជាសហមេធាវីក្រុម១(CPG-1) CPG-1 សូមដាក់ជូនអង្គជំនុំជម្រះដោយគោរពនូវការវិភាគដូចខាងក្រោមនេះអំពីគោលការណ៍ដែលគ្រប់គ្រងលើការវាយតម្លៃលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខសាលាជំនុំជម្រះក្តីអន្តរជាតិ ដែលនេះអាចផ្តល់ជាការណែនាំខ្លះដល់អង្គជំនុំជម្រះក្នុងសំណុំរឿង០០១។

### ខ. វិធាន២៣

២៣. វិធាន២៣(២) បានចែងថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់អ.វ.ត.ក មានសិទ្ធិអាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី។ ពាក្យបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាននៅពេលដែលព្យសនកម្មខូចខាតជា "រូបរាងកាយ សម្ភារៈ និង ផ្លូវចិត្ត" និងជា "ផលវិបាកដោយផ្ទាល់នៃបទល្មើសជាលក្ខណៈផ្ទាល់ខ្លួន និង កើតមានជាពិតប្រាកដ"។[៦២] ជនរងគ្រោះតម្រូវឱ្យបង្ហាញអំពីព្យសនកម្មទទួល

---

[៦០] *សំណុំរឿងកាំង ហ្គេកអ៊ាវ.* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណាងជម្ងឺចិត្ត និង ស្តីអំពីការដាក់សារណាជាលាយលក្ខអក្សរបញ្ចប់, ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០៩, E159, វាក្យខណ្ឌ ៥។

[៦១] ប្រតិចារឹត ថ្ងៃទី ២៧ ខែសីហា ២០០៩ (សាធារណៈ), ទំព័រ ៩-១៨, ២៤-២៦។

[៦២] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ២៣(២)(ក)(ខ)។

រងគ្រោះ ភ្ជាប់ជាមួយនូវភស្តុតាង និង ផ្តល់នូវស្ថានភាពពិស្តាររបស់ខ្លួនជាជនរងគ្រោះ។[៦៣] ជាងនេះទៅទៀត ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតម្រូវឱ្យមាន "បញ្ជាក់អំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងភ្ជាប់ជាមួយនូវភស្តុតាងបង្ហាញពីព្យសនកម្មទទួលរងគ្រោះ ឬ បង្ហាញពីទោសកំហុសរបស់ជនដៃដល់"។[៦៤]

២៤. វិធាន ២៣ (វិសោធនកម្មលើកទី៣) បានចែងថា សហចៅក្រមស៊ើបអង្កេត[៦៥] ឬ អង្គជំនុំជម្រះសាលាដំបូង[៦៦] អាចប្រកាសថា ពាក្យសុំតាំងខ្លួនធ្វើដើមបណ្តឹងរដ្ឋប្បវេណីមួយ "មិនអាចទទួលយកបាន" ដោយយោងទៅលើសេចក្តីសម្រេចមានបញ្ជាក់ហេតុផល។ ថ្មីៗនេះ វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មដាក់ដំណើរការដាក់ពាក្យឱ្យស្ថិតនៅក្រោមសមត្ថកិច្ចទាំងស្រុងរបស់សហចៅក្រមស៊ើបអង្កេត ដែលអាច "*បដិសេធនឹពាក្យសុំតាំងខ្លួនធ្វើដើមបណ្តឹងរដ្ឋប្បវេណី នៅពេលណាមួយរហូតដល់ពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ*"។[៦៧] ដោយសារវិធានផ្ទៃក្នុងដែលត្រូវបានធ្វើវិសោធនកម្មថ្មីនេះមិនមានឥទ្ធិពលលើស្ថានភាពដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ CPG-1 នឹងកំណត់ការបកស្រាយរបស់ខ្លួនទៅត្រឹមបទដ្ឋានត្រួតពិនិត្យដែលប្រើប្រាស់ដោយអង្គជំនុំជម្រះនៃសាលាដំបូងនៅដំណាក់កាលនេះ។ ទោះ-យ៉ាងណាក៏ដោយ ការវិភាគនេះគួរតែមានកម្លាំងស្មើគ្នាដែរទៅនឹងបទដ្ឋានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតបន្តកិច្ចការរបស់ខ្លួនក្រោមវិធានថ្មីនេះ។

២៥. ទោះយ៉ាងណាក៏ដោយ វិធាន២៣(៣)និង(៤) ដែលត្រូវបានធ្វើវិសោធនីកម្មថ្មីៗនេះក្តី ក៏បានឆ្លុះបញ្ចាំងពីលក្ខណៈដើមនៃការសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្តល់សិទ្ធិសម្រេចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឱ្យទៅចៅក្រមស៊ើប។ ការសម្រេចនៅក្នុងដំណាក់កាលនេះគឺជារឿងធម្មតាប៉ុណ្ណោះ ដោយហេតុថា សិទ្ធិចូលរួមរបស់រូបវន្តបុគ្គលទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីតាំងពីពេលចាប់ផ្តើមសវនាការបុរេជំនុំជម្រះម្លេះ។ តាមរយៈនេះ បើទោះបីជាវិធានផ្ទៃក្នុងដើមគ្រប់គ្រងលើសវនាការជំនុំជម្រះទាំងនេះ ពីដំបូង បានអនុញ្ញាតឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចបែបនោះក៏ដោយ វិធានផ្ទៃក្នុងនេះគួរតែត្រូវបកស្រាយដោយពិនិត្យមើលអំពីកម្មវត្ថុ និង គោល

[៦៣] វិធានផ្ទៃក្នុង ២៣(៥)។

[៦៤] វិធានផ្ទៃក្នុង ២៣(៥)។

[៦៥] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ២៣(៣)។

[៦៦] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ២៣(៤)។

[៦៧] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ២៣(៣) និង (៤) (មានបន្ថែមការសង្កត់សម្លេង)។

បំណងនៃការសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលបានឆ្លុះបញ្ចាំងយ៉ាងប្រសើរនៅក្នុងវិធានផ្ទៃក្នុងវិសោធនកម្មរួច និង ត្រូវបកស្រាយតាមរបៀបមួយដែលផ្តល់ការគោរពដល់ជនរងគ្រោះ ព្រមទាំងមិនដាក់ឱ្យជនរងគ្រោះទាំងនោះ ស្ថិតនៅក្នុងភាពពុំពិតប្រាកដមួយដែលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេអាចត្រូវដកហូតវិញ។

២៦. បើទោះបីជាវិធានផ្ទៃក្នុងមិនបានចែងអំពីបទដ្ឋានក្នុងការសម្រេចលើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ អង្គជំនុំជម្រះបានអះអាងនៅអំឡុងពេលសវនាការបឋមថា អង្គជំនុំជម្រះបានប្រើប្រាស់ "*បទដ្ឋានសច្ចធារណ៍នៃភស្តុតាង* សម្រាប់ការវាយតម្លៃលើលក្ខណៈវិនិច្ឆ័យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី...." ។[៦៨] នៅពេលដែលអង្គជំនុំជម្រះទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាមួយដោយប្រើប្រាស់*បទដ្ឋានសច្ចធារណ៍នៃភស្តុតាង*នេះ ជនរងគ្រោះនោះត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី និង អាចអនុវត្តសិទ្ធិជាភាគីនៅក្នុងការកាត់ក្តីបាន។[៦៩] ដើមបណ្តឹងរដ្ឋប្បវេណីកន្លងមកបានអនុវត្តសិទ្ធិរបស់ពួកគេ ដូចជា សិទ្ធិមានមេធាវីតំណាងដែលជ្រើសរើសដោយខ្លួនឯង[៧០] សិទ្ធិមើលសំណុំរឿង[៧១] និង បានសួរសំណួរទៅកាន់ចុងចោទតាមរយៈមេធាវីតំណាងរបស់ពួកគេ។[៧២]

២៧. CPG-1 សូមអះអាងថា ការកែប្រែណាមួយនៃឋានៈតាមនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចដែលបានលើកឡើងដោយខាងមេធាវីចុងចោទ គឺជាការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកាលពីអំឡុងសវនាការបឋម។ ជាដំបូង CPG-1 សូមអះអាងថា មេធាវីចុងចោទ មិនអាចដាក់សារណានេះជូនអង្គជំនុំជម្រះនៅពីរសប្តាហ៍មុនពេលបញ្ចប់សវនាការ បន្ទាប់ពីមានការសម្រេចលើបញ្ហានេះរួចហើយ។ បើទោះបីជាខាងចុងចោទអាចដាក់សារណានេះទោះជាយឺតពេលក៏ដោយ បន្ទុកដ៏ធ្ងន់ធ្ងរក្នុងការពិនិត្យមើលពាក្យបណ្តឹងរដ្ឋប្បវេណីឡើងវិញនៅពេលវេលាចុងក្រោយ

---

[៦៨] ប្រតិចារឹក ថ្ងៃទី ១៧ ខែកុម្ភៈ ២០០៩ (សាធារណៈ), ទំព័រ ៣៨។ វិធាន ៨៣(១)។

[៦៩] សូមមើល footnote ខាងលើ។ សូមមើលផងដែរ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ការទទួលស្គាល់បណ្តោះអាសន្នជាដើមបណ្តឹងរដ្ឋប្បវេណី, ៩ មករា ២០០៩, ឯកសារលេខ E2/26/4, វាក្យខណ្ឌ ២។

[៧០] សូមមើល footnote ខាងលើ, វិធាន ២៣(៧)។

[៧១] សូមមើល footnote ខាងលើ, វិធាន ៨៦។

[៧២] សូមមើល footnote ខាងលើ, វិធាន ៩០(២)។

ស្ថិតនៅលើខាងចុងចោទទាំងស្រុងក្នុងការបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនសម្តែងភាពស្មោះត្រង់។ ខាងចុងចោទមានកាតព្វកិច្ចក្នុងការបង្ហាញថា មាន "កំហុសយ៉ាងច្បាស់អំពីការឱ្យហេតុផល" ឬបង្ហាញថា "មានស្ថានភាពពិសេសកើតឡើងដែលអាចនាំឱ្យមានការពិចារណាឡើងវិញ [អំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ] ដើម្បីចៀសវាងភាពអយុត្តិធម៌"។[៧៣] ខាងមេធាវីចុងចោទខកខានមិនបានបំពេញនូវបន្ទុកដ៏ធ្ងន់ធ្ងរនេះ។ ជាក់ស្តែង ភស្តុតាង និង ការឱ្យហេតុផលទាំងអស់ដែលបានលើកមកពិចារណា នៅពេលផ្តល់ការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនរងគ្រោះមន្ទីរស-២១កាលពីដំបូង នៅតែមានតម្លៃ និង មិនអនុញ្ញាតឱ្យមានការពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទេ។

### គ. បទដ្ឋានត្រួតពិនិត្យនៅសាលាជំនុំជម្រះផ្សេងៗ

២៨. បើទោះបីជានៅក្នុងដំណាក់កាលស៊ើបអង្កេត សំណួរស្រដៀងគ្នានេះត្រូវបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ II របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនៅទីនោះ ចៅក្រមដែលមានតែមួយនៅក្នុងសំណុំរឿងប្រទេសអ៊ូហ្គាន់ដា (Situation of Uganda) បានយល់ឃើញថា អវត្តមាននៃការណែនាំផ្លូវច្បាប់ទាក់ទងនឹងបន្ទុកនៃការបង្ហាញភស្តុតាងសម្រាប់ពាក្យបណ្តឹងរបស់ជនរងគ្រោះ បានផ្តល់ឱ្យអង្គជំនុំជម្រះនូវឆន្ទានុសិទ្ធិធំទូលាយ "នៅក្នុងការវាយតម្លៃលើភាពសមហេតុផលរបស់សក្ខីកម្ម ឬភស្តុតាងណាមួយ"។[៧៤] ចៅក្រមនោះបានលើកហេតុផលថា ការវាយតម្លៃលើពាក្យបណ្តឹងរបស់ជនរងគ្រោះគួរតែអាស្រ័យទៅលើគោលការណ៍ទូទៅនៃច្បាប់ដែលចែងថា បន្ទុកបង្ហាញភស្តុតាងស្ថិតនៅលើភាគីដែលអះអាង។[៧៥]

២៩. នៅក្នុងកំណត់ថាតើតម្រូវការជាអប្បរមាសម្រាប់ឱ្យពាក្យបណ្តឹងមួយអាចគ្រប់គ្រាន់តាមបន្ទុកបង្ហាញភស្តុតាង ចៅក្រមនោះបានកត់សម្គាល់ថា ជនរងគ្រោះមិនមែនជានិច្ចកាលសុទ្ធតែត្រូវទទួលបន្ទុកជាអ្នកបង្ហាញភស្តុតាងគាំទ្រដល់ពាក្យបណ្តឹងរបស់ខ្លួននោះទេ។[៧៦] នៅពេលដែលជនរងគ្រោះមិនអាច

---

[៧៣] *Kajelijeli v. Prosecutor*, Case No. ICTR-98-44A-A, សាលក្រម, ២៣ ឧសភា ២០០៥, វាក្យខណ្ឌ ២០៣-២០៤។

[៧៤] សំណុំរឿងប្រទេសអ៊ូហ្គាន់ដា (Situation of Uganda), ICC-02/04-101, សេចក្តីសម្រេចស្តីអំពីពាក្យបណ្តឹងសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 to a/0070/06, a/0081/06 to a/0104/06 and a/0111/06 to a/0127/06, Pre-Trial Chamber II (Single Judge), ១០ សីហា ២០០៧, វាក្យខណ្ឌ ១៣។

[៧៥] សូមមើល footnote ខាងលើ។

[៧៦] សូមមើល footnote ខាងលើ នៅវាក្យខណ្ឌ ១៥។

ផ្តល់ភស្តុតាងផ្ទាល់បញ្ជាក់អំពីពាក្យបណ្តឹងរបស់ខ្លួនដោយសារហេតុផលឧបសគ្គជាក់ស្តែង "ភស្តុតាងប្រយោល"(ដូចជា ភស្តុតាងដែលមើលទៅទំនងជាការពិត ឬ ការយោងទៅតាមអង្គហេតុ) គឺត្រូវគិតថាគ្រប់គ្រាន់។[៧៧] ចៅក្រមម្នាក់នោះបានឱ្យហេតុផលថា ដូច្នេះ តុលាការគួរវាយតម្លៃលើសក្ខីកម្មនីមួយៗដោយផ្អែកលើភាពប្រទាក់ក្រឡានៃសក្ខីកម្ម ក៏ដូចជាផ្អែកទៅលើពតិមានដែលតុលាការដឹង។[៧៨]

៣០. ដោយសារថាទាំងវិធានផ្ទៃក្នុងវិសោធនកម្មលើកទី៣ និង ទី៤ មិនបានផ្តល់នូវការណែនាំបន្ថែមទៀត ទាក់ទងនឹងការវាយតម្លៃលើពាក្យបណ្តឹង និង ធាតុផ្សំដែលត្រូវយកមកពិចារណា CPG-1 យល់ថាអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិយ៉ាងទូលាយនៅក្នុងការវាយតម្លៃលើភាពជឿជាក់បាននូវសក្ខីកម្ម និង ភស្តុតាងដាក់ជូនដោយជនរងគ្រោះ នូវក្នុងការពិចារណាសម្រេចលើការទទួលស្គាល់ពាក្យបណ្តឹងនោះ។[៧៩] ស្រដៀងគ្នាទៅនឹងជនរងគ្រោះនៅក្នុងសំណុំរឿងប្រទេសអ៊ុយហ្គាន់ដា (Situation of Uganda)ដែរ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ជួបប្រទះនឹងការលំបាកក្នុងការផ្តល់"ភស្តុតាងផ្ទាល់"ឱ្យបានគ្រប់គ្រាន់ ដោយសារថាភាគច្រើននៃឯកសារអំពីក្រុមគ្រួសារត្រូវបានបំផ្លាញ។[៨០] ប្រើប្រាស់បទដ្ឋានត្រួតពិនិត្យផ្សេងដ៏ទៃទៀត គឺមានន័យទៅនឹងការបដិសេធនីពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់

[៧៧] សូមមើល footnote ខាងលើ។ ចៅក្រមម្នាក់នោះបានថ្លែងថា នៅក្នុងប្រទេសខ្ទេចខ្ទាំដោយ សង្គ្រាមដូចជាអ៊ុយហ្គាន់ដា វាគឺ"...មិនត្រឹមត្រូវទេក្នុងការរំពឹងឱ្យជនរងគ្រោះអ្នកដាក់ពាក្យបណ្តឹងផ្តល់នូវភស្តុតាងបង្ហាញអត្តសញ្ញាណដូចអ្នកផ្សេងទៀតរស់នៅតំបន់ដែលមិនជួបប្រទះការលំបាកដូចគ្នានេះ"។ សូមមើល footnote ខាងលើ, វាក្យខណ្ឌ ១៦។

[៧៨] សូមមើល footnote ខាងលើ, នៅវាក្យខណ្ឌ ១៥។

[៧៩] ការនេះគឺជាប់ពាក់ព័ន្ធជាពិសេសនៅក្នុងសំណុំរឿង០០២ ដែលវិធានផ្ទៃក្នុងបានចែងថា ការត្រួតពិនិត្យមើលពាក្យបណ្តឹងអាចធ្វើបានតែនៅក្នុងដំណាក់កាលមុនជំនុំជម្រះប៉ុណ្ណោះ។

[៨០] ប្រតិចារឹត ថ្ងៃទី ២៦ ខែសីហា ២០០៩ (សាធារណៈ), ទំព័រ ២៦-២៧។ កញ្ញាទី ស្រ៊ុនណា បានពន្យល់អំពីរបៀបដែលដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយឈ្មោះ សួន សៀង មិនអាចផ្តល់ឯកសារបញ្ជាក់ដើម្បីភ្ជាប់ទំនាក់ទំនងរវាងគាត់ទៅនឹងបងប្អូនជីដូនមួយរបស់គាត់ដែលជាប់នៅស-២១ ដោយសារថា ឯកសារនេះត្រូវបានបំផ្លាញចោលកាលពីរបបខ្មែរក្រហមដើម្បីចៀសវាងការចាប់ទោសម្នាក់ដូចបងប្អូនជីដូនមួយគាត់ដែរ។ រឿងបែបនេះកើតឡើងជាពិសេសនៅក្នុងសំណុំរឿង០០២ ដែលភស្តុតាងជាឯកសារមានតិចតួច ឬ គ្មានទាល់តែសោះ ដើម្បីគាំទ្រដល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងពាក្យបណ្តឹងរបស់ពួកគេ។ សូមមើល footnote ខាងលើ នៅទំព័រ១៥ លោកវីនីរបានបង្ហាញតាមរយៈសៀវភៅរបស់លោកនិក ដាន់ឡូប អំពី របៀបដែលភស្តុតាងជាឯកសារត្រូវបានបំផ្លាញបន្ទាប់ពីការដួលរលំរបបខ្មែរក្រហម។ ជាឧទាហរណ៍ លោកដាន់ឡូប បានរាយការណ៍ថា ចម្លើយសារភាពនិងភស្តុតាងជាឯកសារផ្សេងទៀត ត្រូវគេយកមកប្រើសម្រាប់ខ្ចប់ចេក នៅក្នុងសម័យក្រោយរបបខ្មែរក្រហម។

E159/7

ដោយសារតែការខ្វះខាតភស្តុតាងគាំទ្រ។ ប្រាកដណាស់នេះមិនមែនជាគោលបំណងរបស់វិធានផ្ទៃក្នុងទេ។

៣១. ដូចដែលបានលើកឡើងដោយមេធាវីចុងចោទ[៨១] ការខកខានមិនបានផ្តល់នូវភស្តុតាងគាំទ្រដល់ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនគួរជាឧបសគ្គនោះទេ ដោយសារច្បាប់ព្រហ្មទណ្ឌអន្តរជាតិមិនតម្រូវឱ្យមានភស្តុតាងគាំទ្របែបនេះទេ។[៨២] ជាការពិត ជនជាប់ចោទម្នាក់អាចត្រូវរកឃើញថាមានទោស ដោយសំអាងទៅលើសក្ខីកម្មរបស់សាក្សីដែលគ្មានអ្វីបញ្ជាក់បន្ថែម ប្រសិនបើអង្គជំនុំជម្រះជឿជាក់លើសាក្សីរូបនោះ។[៨៣] ដើមបណ្តឹងរដ្ឋប្បវេណីដែលជឿជាក់ថាអាចជឿជាក់បាន និង ដែលភាគច្រើនមិនបាននិយាយដាក់កំហុសលើជនជាប់ចោទនៅពេលសវនាការ មិនគួរត្រូវបានដកហូតឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីវិញ ដោយសារតែការចង់បានភស្តុតាងល្អឥតខ្ចោះពេកនោះទេ។

៣២. ជាការពិត ទាំងវិធានផ្ទៃក្នុង និង សេចក្តីណែនាំអំពីការចូលរួមរបស់ជនរងគ្រោះ មិនបានចែងថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបដិសេធន៍ដោយសារតម្រូវការភស្តុតាង។[៨៤] ជាការគួរឱ្យកត់សម្គាល់ វិធាន២៣(៥) បានចែងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "ត្រូវមានពត៌មានគ្រប់គ្រាន់... និង *ប្រសិនបើចាំបាច់* មានបញ្ចូលភស្តុតាងទាំងឡាយណាដែលអាចបញ្ជាក់ពីការកើតឡើង

---

[៨១] ជាឧទាហរណ៍ សូមមើលប្រតិចារឹក ថ្ងៃទី ២៧ ខែសីហា ២០០៩ (សាធារណៈ), ទំព័រ ៩។ មេធាវីចុងចោទលោកហ្វ្រង់ស្វ័រ រូ បានអះអាងថា មិនមានឯកសារនៅក្នុងសំណុំរឿងដើម្បីគាំទ្រដល់ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី E2/49, E2/69, E2/73, E2/74, E2/75 ។

[៨២] ជាឧទាហរណ៍ សូមមើលសំណុំរឿង *Prosecutor v. Akayesu*, សាលក្រម, សំណុំរឿងលេខ ICTR-96-4-T, ២ កញ្ញា ឆ្នាំ១៩៩៨ វាក្យខណ្ឌ ១៣៥ (អង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះអាចសម្រេចលើអង្គហេតុ ដោយសំអាងលើសក្ខីកម្មតែមួយដែលគ្មានភស្តុតាងបញ្ជាក់បន្ថែម ប្រសិនបើសក្ខីនោះ "ជាប់ពាក់ព័ន្ធ និង ជឿជាក់បាន")។

[៨៣] ជាឧទាហរណ៍ សូមមើលសំណុំរឿង *Prosecutor v. Rutaganda*, សាលក្រម, សំណុំរឿងលេខ ICTR- 96-3-T, ៦ ធ្នូ ឆ្នាំ១៩៩៩ វាក្យខណ្ឌ ១៨។ សំណុំរឿង *Prosecutor v. Alfred Musema*, សំណុំរឿងលេខ ICTR 96-13-T, សាលក្រម និងការដាក់ទោស, ២៧ មករា ២០០០ (អង្គជំនុំជម្រះសាលាដំបូង) នៅវាក្យខណ្ឌ ៤៣។

[៨៤] វិធាន២៣(៥)។ សេចក្តីណែនាំអំពីការចូលរួមរបស់ជនរងគ្រោះ 02/2007/Rev.1, មាត្រា ៣.៥(ឃ)។

00399996



នូវព្យសនកម្មប្រសិនបើចាំបាច់"។[៨៥] ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនមានកាតព្វកិច្ចផ្តល់ភស្តុតាងដើម្បីគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន លើសពីសក្ខីកម្មរបស់ខ្លួននោះទេ។[៨៦]

**ឃ. ឋានៈតាមនីតិវិធី និង ពាក្យបណ្តឹងអំពីព្យសនកម្ម**

៣៣. អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ បានធ្វើការកត់សំគាល់ថា បើទោះបីជាការត្រួតពិនិត្យមើលពាក្យបណ្តឹងជាបឋមត្រូវបានធ្វើឡើងកាលពីសវនាការបឋម អង្គជំនុំជម្រះនឹងធ្វើការត្រួតពិនិត្យមើលឡើងវិញនៅពេលសវនាការជំនុំជម្រះទោស ដើម្បីបញ្ជាក់ថាតើ"ព្យសនកម្មដែលបានចោទប្រកាន់ពិតជាកើតមានឡើងមែនឬទេ"។[៨៧] បើទោះបីជាអង្គជំនុំជម្រះមិនបានបញ្ជាក់ច្បាស់បែបនេះក៏ដោយ អង្គជំនុំជម្រះបានយោងការសម្រេចរបស់ខ្លួនលើវិធាន១០០(១)ដែលបានចែងថា អង្គជំនុំជម្រះនឹង"សម្រេចលើការទទួលស្គាល់ និង ខ្លឹមសារពាក្យបណ្តឹងដើមបណ្តឹង[រដ្ឋប្បវេណី]ប្រឆាំងនឹងជនជាប់ចោទ"។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃបែបនេះជាប់ពាក់ព័ន្ធទៅនឹងការវិភាគលើទោសកំហុសរបស់ជនជាប់ចោទ មិនមែនពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យតាមនីតិវិធីនៃឋានៈរបស់ជនរងគ្រោះដូចដែលបានចែងនៅក្នុងវិធាន២៣ទេ។[៨៨]

៣៤. ដូច្នេះ ការពិភាក្សាណាមួយជុំវិញការទទួលស្គាល់ពាក្យបណ្តឹងរដ្ឋប្បវេណីគឺត្រូវសម្រេចនៅក្នុងបរិបទនៃសំណងជម្ងឺចិត្ត សមរម្យជាងបរិបទសិទ្ធិតាមនីតិវិធីរបស់ជនរងគ្រោះក្នុងការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី។ ការណែនាំអាចរកបានពីការជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលក្នុង

---

[៨៥] មានបន្ថែមការសង្កត់សម្លេង។

[៨៦] ប្រតិចារឹត ថ្ងៃទី ២៧ ខែសីហា ២០០៩ (សាធារណៈ), ទំព័រ ១១-១២។ លោកជីន័រពីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានអះអាងថា អវត្តមានភស្តុតាងមិនគួរប៉ះពាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចបង្ហាញអំពីទំនាក់ទំនងញាតិសន្តាននោះទេ។

[៨៧] ប្រតិចារឹត ថ្ងៃទី ១៧ ខែកុម្ភៈ ២០០៩ (សាធារណៈ), ទំព័រ ៣១។

[៨៨] សំណុំរឿងប្រទេសអ៊ូហ្គាន់ដា(Situation of Uganda), នៅវាក្យខណ្ឌ១៣។ ចៅក្រមតែម្នាក់នៅអង្គបុរេជំនុំជម្រះ II បានយល់ស្របទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ថា គោលបំណងនៃការត្រួតពិនិត្យឡើងវិញនៅក្នុងវិធាន៨៩ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ទាក់ទងនឹងការពាក្យបណ្តឹងជនរងគ្រោះគឺមិនមែន"ជាសេចក្តីសម្រេចដាច់ខាតនៃព្យសនកម្មទទួលរងដោយជនរងគ្រោះនោះទេ ដោយសារថាករណីនេះត្រូវសម្រេចនៅពេលក្រោយមកទៀតនៅពេលសមស្រប ដោយអង្គជំនុំជម្រះសាលាដំបូងតាមបរិបថរបស់សំណុំរឿង"។ សូមមើលសំណុំរឿងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, ICC-01/04-505, អង្គបុរេជំនុំជម្រះ I, ៣ កក្កដា ឆ្នាំ២០០៨ វាក្យខណ្ឌ ៣០។

នោះចៅក្រមតែម្នាក់នៅក្នុងសំណុំរឿងប្រទេសយូហ្គាន់ដា បានប្រកាន់យក"វិធីសាស្ត្រជាក់ស្តែង តាមអង្គហេតុដែលតាមរយៈនោះ ព្យសនកម្មដែលចោទថាបានកើតឡើងនឹងត្រូវចាត់ទុកថាជា"លទ្ធផលពី"ហេតុការណ៍ដែលត្រូវចោទថាបានកើតឡើង នៅពេលដែលកាលៈទេសៈពាក់ព័ន្ធ និង ពេលវេលាពាក់ព័ន្ធនឹងការលេចឡើងនូវព្យសនកម្មនិងការកើតឡើងនូវព្រឹត្តិហេតុ ទំនងជាត្រួតស៊ីគ្នា ឬ យ៉ាងហោចណាស់ស៊ីគ្នា មិនមែនមិនត្រូវគ្នាសោះនោះទេ"។[៨៩]

៣៥. បើទោះបីជាអង្គជំនុំជម្រះនៃសាលាដំបូងជាធម្មជាតិមាន កាតព្វកិច្ចថ្លឹងថ្លែងគោលការណ៍សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់ជនជាប់ចោទទៅនឹងសិទ្ធិចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី គេយល់ថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ចុងចោទទេ។[៩០] ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ បានផ្តល់នូវភស្តុតាងតិចតួចនៅអំឡុងពេលសវនាការ ដែលក្នុងនោះចម្លើយ និងសក្តីកម្មរបស់ពួកគេពាក់ព័ន្ធភាគច្រើនទៅនឹងបញ្ហាព្យសនកម្ម ដោយសារថា វាទាក់ទងនឹងបញ្ហាសំណងជម្ងឺចិត្ត ជាជាងពាក់ព័ន្ធនឹងទោសកំហុសរបស់ជនជាប់ចោទ។ ជាការពិត ភាគច្រើននៃដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់សក្ខីកម្មប្រឆាំងនឹងជនជាប់ចោទទេ និង មិនបានផ្តល់ចម្លើយអ្វីបន្ថែមទៅឱ្យតុលាការក្រៅពីពាក្យបណ្តឹងរបស់គេឡើយ។[៩១] ជាងនេះទៅទៀត ដូចដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ លោកវើន័រ បានពន្យល់ សំណងជម្ងឺចិត្តជាថវិកាជាបុគ្គលណាមួយ ដែលនឹងត្រូវផ្តល់ដោយអង្គជំនុំជម្រះ នឹងមិនត្រូវចេញដោយជនជាប់ចោទទេ។[៩២] ដូច្នេះ វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនធ្វើឱ្យលម្អៀងដល់ជនជាប់ចោទតាមរបៀបណាមួយឡើយ។

---

[៨៩] សូមមើល footnote ខាងលើ, ទំព័រ ១៤។

[៩០] សូមមើលយោបល់ជំទាស់របស់ចៅក្រម រ៉េណេ ប្លែតមែន (René Blattmann) នៅក្នុងសេចក្តីសម្រេចអំពីការចូលរួមរបស់ជនរងគ្រោះ (អង្គជំនុំជម្រះសាលាដំបូង I), ICC-01/04-01/06-1119, វាក្យខណ្ឌ ២៦, ទំព័រ ៥៨។

[៩១] ប្រតិចារឹក ថ្ងៃទី ២៧ ខែសីហា ២០០៩ (សាធារណៈ), ទំព័រ ១៣-១៤។ លោកវើន័រពីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានពន្យល់ថា ជាការពិត ដើមបណ្តឹងរដ្ឋប្បវេណី៤រូបនៅក្នុងក្រុម១ដែលត្រូវបានជំទាស់ដោយខាងចុងចោទមិនបានផ្តល់ភស្តុតាងដាក់កំហុសដល់ចុងចោទទាល់តែសោះ។

[៩២] សូមមើល footnote ខាងលើ, នៅទំព័រ ១៤។

៣៦. ជាការពិត គោលបំណងសំខាន់របស់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី គឺការផ្ដល់ឱ្យនូវសិទ្ធិ*ចូលរួម* ដែលបានផ្ដល់ឱ្យរួចហើយ និង ត្រូវបានប្រើប្រាស់យ៉ាងពេញលេញ។ គេមិនយល់ទាល់តែសោះអំពីគោលបំណងនៃការបដិសេធនីសេចក្ដីសម្រេចរបស់តុលាការក្រោយពេលចេញរួចហើយនេះ ក្រៅអំពីការបដិសេធន៍សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការលើកអំណះអំណាងសន្និដ្ឋានបញ្ចប់ ឬបដិសេធន៍សិទ្ធិទទួលបានសំណងជម្ងឺចិត្ត។ ដូចដែលបានពិភាក្សាខាងលើ សំណងជម្ងឺចិត្តគឺមិនមែនតម្រូវឱ្យជនជាប់ចោទជាអ្នកចេញទេ។ ប៉ុន្ដែ សំណងជម្ងឺចិត្តនេះជាសំណងជម្ងឺជារួម និង ផ្លូវចិត្ត ដែលមិនមែនបានទៅដើមបណ្ដឹងរដ្ឋប្បវេណីណាមួយជាបុគ្គលទេ។

៣៧. សិទ្ធិមួយក្នុងចំណោមសិទ្ធិសំខាន់ៗរបស់ជនជាប់ចោទគឺការសន្មត់ថាគ្មានទោស។ CPG-1 យល់ថា សិទ្ធិមួយក្នុងចំណោមសិទ្ធិសំខាន់ៗដែលគួរតែផ្ដល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីគឺការសន្មត់ថា ពួកគេសំដែងភាពស្មោះត្រង់នៅពេលដាក់ពាក្យបណ្ដឹងរបស់ពួកគេ និង ពេលចូលរួមនៅក្នុងសវនាការ។ ដូច្នេះ ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគេ ដែលត្រូវបានផ្ដល់ឱ្យនៅសវនាការមុន មិនគួរត្រូវសើរើឡើងវិញតាមរយៈសំណើររបស់ជនជាប់ចោទទេ។ ក្នុងករណីនេះ ជនជាប់ចោទមានបន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងការបង្ហាញផ្ទុយមកវិញថា ជនរងគ្រោះមិនគួរទទួលបានឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីទេ បើពិនិត្យមើលអំពីភស្ដុតាងទាំងអស់ ដែលរួមមានសក្ខីកម្ម ចម្លើយជាលាយលក្ខណ៍អក្សរ និង ភស្ដុតាងជាឯកសារ។ កន្លងមក ជនជាប់ចោទ ខកខានមិនបានបំពេញនូវបន្ទុកធ្ងន់ធ្ងរនេះទេ។ អង្គជំនុំជម្រះសាលាដំបូងនេះគួរតែប្រើប្រាស់នៅក្នុងសវនាការទាំងនេះ នូវការសន្មត់ដែលមិនងាយនឹងសើរើឡើងវិញថា ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីមិនគួរដកហូតពីជនរងគ្រោះនៅក្នុងដំណាក់កាលចុងបញ្ចប់សវនាការនោះទេ ដោយការខ្វះខាតនូវភស្ដុតាងសំខាន់ថ្មី។

## IV. មូលដ្ឋានអង្គហេតុនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៣៨. បន្ថែមពីលើមូលដ្ឋានច្បាប់សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់បន្ថែមនូវមូលដ្ឋានអង្គហេតុសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។[៥៣] បើយោងតាមវិធានផ្ទៃក្នុង "គ្រប់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ .... ត្រូវផ្តល់ពត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និង ភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនដែលត្រូវចោទប្រកាន់"។[៥៤] តាមរយៈនេះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដោយក្តីគោរព សូមដាក់ជូននូវពត៌មានលម្អិតរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ។ ភាគច្រើន ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នូវភស្តុតាងជាសក្ខីកម្ម និង/ឬ ជាឯកសារ បញ្ជាក់អំពីព្យសនកម្ម និងការឈឺចាប់ដែលពួកគេទទួលរង។[៥៥] ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមិនអាចផ្តល់ភស្តុតាងជាឯកសារបាន ដោយសារការបំផ្លាញឯកសារនៅសម័យកម្ពុជាប្រជាធិបតេយ្យ។[៥៦] ដើមបណ្តឹងរដ្ឋប្បវេណីបានចង្អុលបង្ហាញថា ពួកគេទទួលរងគ្រោះព្យសនកម្មរូបរាងកាយ និង ផ្លូវចិត្តដែលមិនអាចជួសជុលបានដោយសារការបាត់បង់សមាជិកគ្រួសារនៅស-២១។[៥៧] នៅពេលមិនមានបញ្ជាក់ព្យសនកម្មជាក់លាក់ណាមួយនោះ គេសន្និដ្ឋានថា ភាគីទទួលរងនូវការខូចខាតផ្លូវចិត្ត ដូចដែលទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង។[៥៨]

### ក. ពាក្យបណ្តឹងធ្វើដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល

---

[៥៣] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណងជម្ងឺចិត្ត និង ស្តីអំពីការដាក់សារណាជាលាយលក្ខណ៍អក្សរបញ្ចប់, ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០៩, E159 ។

[៥៤] វិធាន ២៣(៥) ។

[៥៥] ភស្តុតាងឯកសារមានទម្រង់ជាប្រវត្តិរូបអ្នកទោសជាជនរងគ្រោះផ្ទាល់, បញ្ជីអ្នកទោសដែលមានឈ្មោះជនរងគ្រោះផ្ទាល់, រូបថតពីមន្ទីរស-២១ និង ចម្លើយសារភាពស-២១របស់ជនរងគ្រោះផ្ទាល់ដែលធ្វើមុនពេលត្រូវសម្លាប់ ។

[៥៦] សូមមើល ជំពូក III (គ), វាក្យខណ្ឌ ៣០ ។

[៥៧] សូមមើល footnote ខាងលើ, នៅវិធាន ២៣(២) ។

[៥៨] សេចក្តីណែនាំអំពីការចូលរួមរបស់ជនរងគ្រោះ 02/2007/Rev.1, មាត្រា ៣.២(គ) ("ការខូចខាតផ្លូវចិត្តអាចរួមបញ្ចូលទាំងការស្លាប់របស់សាច់ញាតិដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនោះ") ។

៣៩. ដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា (E2/61) ជាជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ និង ត្រូវបានបញ្ជាក់ដោយភស្តុតាងជាឯកសារ ដែលជនជាប់ចោទ និង សាក្សី ម៉ម ណៃ បានបញ្ជាក់បន្ថែម[៩៩] ហើយសក្ខីកម្មរបស់លី ហ៊ា ផ្ទាល់ខ្លួនក៏បានបញ្ជាក់ពីការឃុំខ្លួនរបស់គាត់នៅមន្ទីរស-២១ដែរ។[១០០] លី ហ៊ា ទទួលរងគ្រោះព្យសនកម្មផ្ទាល់ ជាលក្ខណៈបុគ្គល និង មិនអាចជួសជុលបាន ដោយសារតែការឃុំខ្លួននៅមន្ទីរស-២១។[១០១]

៤០. ជនរងគ្រោះផ្ទាល់ ឃែរី ហាមីល (Kerry Hamill) ជាប្អូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី រ៉ូបឺត ហាមីល (Robert Hamill)(E2/87)។[១០២] ជនជាប់ចោទចំណាំឃែរី ហាមីល ថាជាជនបរទេសម្នាក់ឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១[១០៣] ហើយចម្លើយសារភាពពីមន្ទីរស-២១បានបញ្ជាក់បន្ថែម[១០៤] លើសក្ខីកម្មនេះ។ ការស្លាប់របស់ឃែរី ហាមីល មានផលប៉ះពាល់"យ៉ាងធំធេង និង មិនអាចយល់បាន"ទៅលើរ៉ូបឺត ហាមីល និង ក្រុមគ្រួសារទាំងមូលរបស់គាត់។[១០៥] "ជីវិតជាក្រុមគ្រួសាររបស់គាត់ត្រូវបាក់បែក"[១០៦] បន្ទាប់ពីការស្លាប់របស់ឃែរីៈ បងប្រុសរបស់គាត់ធ្វើអត្តឃាដ[១០៧] ឪពុកម្តាយរបស់គាត់"បាត់បង់សម្ភាព

---

[៩៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំណើរសុំដាក់ឋានៈរបស់លី ហ៊ា ជាអ្នករួចរស់ជីវិតពីមន្ទីរស-២១ និង ភាពពិតត្រឹមត្រូវនៃឯកសារ, ២៨ កក្កដា ឆ្នាំ២០០៩ ឯកសារលេខ E137។

[១០០] ប្រតិចារឹក ថ្ងៃទី ៦ ខែកក្កដា ២០០៩។

[១០១] ប្រតិចារឹក ថ្ងៃទី ៦ ខែកក្កដា ២០០៩។

[១០២] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់ រ៉ូបឺត ម៉ាលស៍ ហាមីល (Robert Miles Hamill), E2/87.14។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់ ឃែរី ចច ហាមីល (Kerry George Hamill ), E2/87.15 ។

[១០៣] ប្រតិចារឹក ថ្ងៃទី ១៥ ខែមិថុនា ២០០៩, ទំព័រ៩២។ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ២០០៩ ទំព័រ២៨-២៩។ ប្រតិចារឹក ថ្ងៃទី១៧ សីហា ឆ្នាំ២០០៩ ទំព័រ ១០៨-១០៩។

[១០៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ចម្លើយសារភាពរបស់ឃែរី ចច ហាមីល (Kerry George Hamill), E2/87.7។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបរបស់ចន ដសុន ឌូហឺស្ទ (John Dawson Dewhirst), E2/87.15 ។

[១០៥] ប្រតិចារឹក ថ្ងៃទី ១៧ ខែសីហា ២០០៩, ទំព័រ៩៤។

[១០៦] ប្រតិចារឹក ថ្ងៃទី ១៧ ខែសីហា ២០០៩, ទំព័រ៩២។

[១០៧] ប្រតិចារឹក ថ្ងៃទី ១៧ ខែសីហា ២០០៩, ទំព័រ៩៣-៩៤។

ធ្វើជាឪពុកម្ដាយអស់រយៈពេលយ៉ាងយូរ"ដោយសារតែទុក្ខព្រួយធ្ងន់ធ្ងរពេក[១០៨] ហើយគាត់ខ្លួនឯង"ងាកមកផឹកស្រា"ដែលបានធ្វើឱ្យប៉ះពាល់ការរៀនសូត្ររបស់គាត់។[១០៩]

៤១. ជនរងគ្រោះផ្ទាល់ ចិន សៀ ហៅ ហាវ ហាន ជាឪពុករបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហាវ សុភា (<u>D25/4</u>)។[១១០] ប្រវត្តិរូបអ្នកទោសស-២១របស់ ចិន សៀ[១១១] និង ឈ្មោះរបស់គាត់នៅបញ្ជីអ្នកទោសរួម[១១២] ត្រូវបានបញ្ជាក់បន្ថែមកាន់តែច្បាស់ដោយជនជាប់ចោទបានទទួលស្គាល់ថា ចិន សៀ ជាជនរងគ្រោះម្នាក់នៅមន្ទីរស-២១។[១១៣] ព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីហាវសុភាពីការបាត់បង់ឪពុកគឺមានយ៉ាងជាក់ស្ដែងៈ "ទាំងផ្លូវចិត្ត ទាំងរូបរាងកាយ [និង] ផ្នែកស្មារតី [ក្រុមគ្រួសាររបស់គាត់] ស្ថិតនៅក្នុងស្ថានភាពដ៏លំបាក"។[១១៤] អស់រយៈពេលយ៉ាងយូរ គាត់"បានតស៊ូដើម្បីជីវភាព"[១១៥] ហើយដោយសារតែការបាត់បង់ឪពុកនេះ គាត់មិនអាចទៅរៀនសូត្របាន ដែលនេះធ្វើឱ្យបំណងក្លាយជា

---

[១០៨] ប្រតិចារឹក ថ្ងៃទី ១៧ ខែសីហា ២០០៩, ទំព័រ៩៣-៩៤។

[១០៩] ប្រតិចារឹក ថ្ងៃទី ១៧ ខែសីហា ២០០៩, ទំព័រ១០១។

[១១០] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ — សារណាដើម្បីបង្កើតទំនាក់ទំនងគ្រួសាររវាងដើមបណ្ដឹងរដ្ឋប្បវេណី៤នាក់នៅក្នុងក្រុម១ និង ជនរងគ្រោះផ្ទាល់នៅមន្ទីរស-២១, ៦ សីហា ឆ្នាំ២០០៩, ឯកសារលេខ E140 វាក្យខណ្ឌ ៩-១៥ [បន្ទាប់ពីនេះ សារណានេះត្រូវបានហៅថា "សារណាស្ដីអំពីដើមបណ្ដឹងរដ្ឋប្បវេណី៤រូប"]។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់ ហាវ សុភា, ឯកសារលេខ E140.4។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សៀវភៅគ្រួសាររបស់ រៀម សុផាត, ឯកសារលេខ E140.5។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បណ្ណបោះឆ្នោតរបស់ហាវ សុភា, ឯកសារលេខ E2/7.1។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ ហាវ សុភា, ឯកសារលេខ D25/4, ៩ ឧសភា ២០០៨។

[១១១] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសរបស់ ចិន សៀ ហៅ ហាន, ឯកសារលេខ E140.3, ៩ ឧសភា ២០០៨។

[១១២] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសស-២១រួម, ១៩ ឧសភា ២០០៩, ឯកសារលេខ E68.1, ទំព័រ៦៤ (ដែលបញ្ជាក់ថា ចិន សៀ ហៅ ហាន ត្រូវកម្ទេចថ្ងៃ១៥ ខែឧសភា ឆ្នាំ១៩៧៦)។

[១១៣] ប្រតិចារឹក ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ៥៧-៥៨។

[១១៤] ប្រតិចារឹក ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ៥០។

[១១៥] ប្រតិចារឹក ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ៥០។

គ្រូបង្រៀនរបស់គាត់មិនអាចសម្រេចបាន។[១១៦] បន្ទាប់ពីទៅមើលមន្ទីរទួលស្លែងកាលពីឆ្នាំ២០០៧ គាត់យល់សប្តិអាក្រក់ជុំវិញព្រឹត្តិការណ៍នៃការស្លាប់របស់ឪពុកគាត់។[១១៧]

៤២. ជនរងគ្រោះផ្ទាល់ឈ្មោះ នេត ប៊ុនធី ជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី នេត ផល្លី (<u>E2/50</u>)។[១១៨] ប្រវត្តិរូបអ្នកទោសស-២១របស់នេត ប៊ុនធីនៅក្នុងសំណុំរឿង[១១៩] ដែលត្រូវបានបញ្ជាក់បន្ថែមដោយជនជាប់ចោទទទួលស្គាល់ថា នេត ប៊ុនធី ជាជនរងគ្រោះនៅស-២១។[១២០] នេត ផល្លី និងក្រុមគ្រួសាររបស់គាត់មាន"ទុក្ខសោកយ៉ាងខ្លាំង" នៅពេលដឹងអំពីការសម្លាប់បងប្រុសរបស់គាត់នៅមន្ទីរស-២១។[១២១] ថ្ងៃមួយ នៅពេលដែលគាត់មានទុក្ខព្រួយខ្លាំងពេកមិនបានចាប់អារម្មណ៍មែកឈើបាក់ធ្លាក់ធ្វើឱ្យគាត់បាត់បង់ដៃអស់មួយចំហៀង។[១២២]

៤៣. ជនរងគ្រោះផ្ទាល់ឈ្មោះ ចេមស៍ វិល្លៀម ខ្លាក (James W. Clark) ជាឪពុកមា[១២៣] របស់ដើមបណ្តឹងរដ្ឋប្បវេណីចស្សួហួ រ៉ស់ឆាលដ៍ (Joshua Rothchild) (<u>E2/88</u>) និង ជេហ្វ្រីយ៍ ចេមស៍ (Jeffrey

---

[១១៦] ប្រតិចារឹត ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ៥១។

[១១៧] ប្រតិចារឹត ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ៥២-៥៣។

[១១៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សៀវភៅគ្រួសាររបស់ នេត ផល្លី, ឯកសារលេខ E2/140.8។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសឃុំឃាំង, ឯកសារលេខ E140.6 (ជាភស្តុតាងបង្ហាញថា ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុកម្តាយរួមគ្នា)។ សូមមើល សារណាស្តីអំពីដើមបណ្តឹងរដ្ឋប្បវេណី៤រូប, វាក្យខណ្ឌ១៧-២០។

[១១៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង, ឯកសារលេខ E140.6។

[១២០] ប្រតិចារឹត ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ១១១-១១២។

[១២១] ប្រតិចារឹត ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ១០៦។

[១២២] ប្រតិចារឹត ថ្ងៃទី ១៨ ខែសីហា ២០០៩, ទំព័រ១០៦។

[១២៣] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា១៦ ("ក្នុងករណីដែលជនរងគ្រោះបាត់បង់ជីវិត ពាក្យបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានចាប់ផ្តើម ឬ បន្តដោយសិទ្ធិវន្ត")។ ប្រតិចារឹត ថ្ងៃទី ២៧ ខែសីហា ២០០៩, ទំព័រ២៨ (ដែលពន្យល់ថា "សិទ្ធិវន្ត"គឺសំដៅទៅសាច់សាលោហិត)។ *សូមមើលផងដែរ Prosecutor v. Joseph Kony, Vincent Otti, Okot Odhiambo and Dominic Ongwen*, សាលក្រមស្តីអំពីបណ្តឹងជំទាស់របស់ចុងចោទប្រឆាំងនឹងសេចក្តីសម្រេចមានចំណងជើងថា "សេចក្តីសម្រេចស្តីអំពីពាក្យបណ្តឹងចូលរួមរបស់ជនរងគ្រោះ", a/0010/06, a/0064/06 to a/0070/06, a /0081/06, a/0082/06, a/0084/06 to a/0089/06, a/0091/06 to a/0097/06, a/0099/06, a/0100/06, a/0102/06 to a/0104/06, a/0111/06, a/0113/06 to a/0117/06, a/0120/06, a/0121/06 and a/0123/06 to a/0127/06' of Pre-Trial Chamber II, Appeals Chamber, 23 February 2009, para. 38 (សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ មិនបញ្ជាក់ទំនាក់ទំនងគ្រួសារចំពោះពាក្យបណ្តឹង

James) (E2/86) ។[១២៤] ឈ្មោះរបស់ចេមស៍ ខ្លាក នៅលើបញ្ជីអ្នកទោសស-២១[១២៥] និង ចម្លើយសារភាពពីមន្ទីរស-២១របស់គាត់ បញ្ជាក់ថា គាត់ត្រូវបានឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។[១២៦] ដើមបណ្ដឹងរដ្ឋប្បវេណី ចស្សហ្វូ រីស់ឆាលជី និង ជេហ្វ្រីយ៍ ចេមស៍ មានជម្ងឺដេកមិនលក់ យល់សប្ដិអាក្រក់ និង ថប់អារម្មណ៍ ចាប់ពីទទួលដំណឹងអំពីការស្លាប់របស់ឪពុកមាម្ដេះ។[១២៧]

---

ដែលទទួលយកដោយអង្គជំនុំជម្រះឧទ្ធរណ៍), *Prosecutor v. Thomas Lubanga Dyilo*, សេចក្ដីសម្រេចអំពីពាក្យសុំចូលរួមក្នុងសវនាការ ដាក់ជូនដោយ VPRS 1 to VPRS 6 in the Case the Prosecutor v. Thomas Lubanga Dyilo, No. ICC-01/04-01/06-172, Pre-Trial Chamber I, 29 June 2006, pp. 7-8 (ទទួលស្គាល់ថា "សាច់ញាតិជិតស្និទ្ធ" របស់ជនរងគ្រោះអាចប្ដឹងជំនួសឱ្យជនរងគ្រោះ)។

[១២៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់ ជេហ្វ្រីយ៍ ចេមស៍, ឯកសារលេខ E140.10, សារណាស្ដីអំពីដើមបណ្ដឹងរដ្ឋប្បវេណី៤រូប, វាក្យខណ្ឌ២២-២៤។ ចស្សហ្វូ រីស់ឆាលជី ជាបងប្អូនបង្កើតរបសជេហ្វ្រីយ៍ ចេមស៍ ដូច្នេះគាត់ត្រូវជាក្មួយរបស់ ចេមស៍ ខ្លាក ដែរ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, របាយការណ៍ស្ដីអំពីពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ ចស្សហ្វូ រីស់ឆាលជី, ៤ កុម្ភៈ ២០០៩, ឯកសារលេខ E2/88.1។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអះអាងរបស់ចស្សហ្វូ រីស់ឆាលជី, ៥ កុម្ភៈ ២០០៩, ឯកសារលេខ E2/88.2។ សំបុត្រកំណើតរបស់ចស្សហ្វូ រីស់ឆាលជី (ភ្ជាប់ជាមួយនេះ), សំបុត្រកំណើតម្ដាយរបស់ជេហ្វ្រីយ៍ ចេមស៍ (ភ្ជាប់ជាមួយនេះ)។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអះអាងរបស់ជេហ្វ្រីយ៍ ចេមស៍, ២៣ មករា ២០០៩, ឯកសារលេខ E2/86.2។

[១២៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសចូល ២១.៤.៧៨ — ២៨.៤.៧៨, ឯកសារលេខ D57 ទំព័រ៤។

[១២៦] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ចម្លើយសារភាពរបស់ ចេមស៍ វិល្លៀម ខ្លាក, ២៣ សីហា ១៩៧៨, ឯកសារលេខ E2/88.3។

[១២៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ ជេហ្វ្រីយ៍ ចេមស៍, ២៣ មករា ២០០៩, ឯកសារលេខ E2/86។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ចស្សហ្វូ រីស់ឆាលជី, ២៣ មករា ២០០៩, ឯកសារលេខ E2/88។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអះអាងរបស់ចស្សហ្វូ រីស់ឆាលជី, ៥ កុម្ភៈ ២០០៩, ឯកសារលេខ E2/88.2។

៤៤. ជនរងគ្រោះផ្ទាល់ ម៉ាន ស៊ីម ជាកូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន សួត (D25/18) ។[១២៨] ម៉ាន ស៊ីម ហៅ វៀម ចូលមន្ទីរស-២១នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៦ និង ត្រូវបានសម្លាប់នៅថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៧៧។[១២៩] ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន សួត កំពុងស្ថិតនៅក្នុង"ភាពឈឺចាប់សព្វថ្ងៃនេះ" ដោយសារតែការស្លាប់យ៉ាងវេទនារបស់កូនប្រុសគាត់នៅមន្ទីរស-២១ ដូចជាការសោកសង្រេងទឹករលីក កូន និង ជម្ងឺក្រពះជាប្រចាំ។[១៣០]

៤៥. ជនរងគ្រោះផ្ទាល់ ស្មាន ស្លេះ ជាបងប្អូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្មាន ណុប (E2/44) និង ស្មាន សរ (E2/45)[១៣១] ហើយជនរងគ្រោះផ្ទាល់ឈ្មោះ សា ម៉ាត់ ជាក្មួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

[១២៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ម៉ាន សួត, ៨ សីហា ២០០៨, ឯកសារលេខ D25/18 ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ម៉ាន ស៊ីម ឯកសារលេខ D25/18/2 ( មានបញ្ជាក់ឈ្មោះឪពុកថា "ម៉ាន សួត" ) ។

[១២៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសស-២១រួម, ១៩ ឧសភា ២០០៩, ឯកសារលេខ E68.1, ln. 5309 ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង,បញ្ជីឈ្មោះអ្នកទោសចូលមន្ទីរស-២១, ផ្ទះ ខ និង ឆ, ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ១៦.៤៥, ទំព័រ១០ ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីឈ្មោះអ្នកទោស និង អ្នកសួរចម្លើយក្នុងក្រុម៨ របស់សមមិត្ត ស្ងួន, ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ១៦.៣១, ទំព័រ៣។ ប្រវត្តិរូបរបស់អ្នកទោសមន្ទីរស-២១ ឈ្មោះ "ម៉ន ស៊ីម" ក៏ជាប្រវត្តិរូបរបស់ម៉ាន ស៊ីមនេះឯង គ្រាន់តែប្រកបខុសគ្នាជាភាសាអង់គ្លេសតែប៉ុណ្ណោះ ហើយប្រវត្តិរូបលម្អិត ដូចជា អាយុ ភេទ និង តំណែង គឺ ដូចគ្នាមែនទែនទៅនឹងឈ្មោះនេះនៅលើបញ្ជីអ្នកទោស ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ម៉ាន ស៊ីម, ឯកសារលេខ D25/18/2 ។

[១៣០] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ម៉ាន សួត, ៨ សីហា ២០០៨, ឯកសារលេខ D25/18 ។

[១៣១] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ស្មាន ស្លេះ, ឯកសារលេខ E2/44.1, ទំព័រ២ (ដែលនៅក្នុងនោះមានបញ្ជាក់ឈ្មោះបងប្អូនបង្កើតជា "ស្មាន ណុប" និង "ស្មាន សរ") ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ស្មាន ណុប . ១៦ សីហា ឆ្នាំ២០០៨, ឯកសារលេខ E2/44, *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ស្មាន សរ . ១៦ សីហា ឆ្នាំ២០០៨, ឯកសារលេខ E2/45 ។

ស្មាន ណុប និង ជាកូនប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស្មាន សរ។[១៣២] ស្មាន ស្លេះ ហៅ ឡេង សុខា ត្រូវឃុំឃាំងខ្លួន និង សម្លាប់នៅមន្ទីរស-២១ ដូចដែលមានឃើញនៅក្នុងបញ្ជីអ្នកទោសស-២១រូម[១៣៣] និង ប្រវត្តិរូបអ្នកទោសស-២១របស់គាត់។[១៣៤] សា ម៉ាត់ ហៅ សារឿន ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១ដែរ ដូចដែលមានឃើញនៅក្នុងបញ្ជីអ្នកទោសស-២១រូម[១៣៥] និង ប្រវត្តិរូបអ្នកទោសរបស់គាត់។[១៣៦]

៤៦. ជនរងគ្រោះផ្ទាល់ តាឡុស ម៉ាត់ ហៅ ម៉ាន ម៉ាត់ និងហៅ ម៉ាន ម៉ា ជាកូនប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ម៉ះ (E2/51) ហៅ ម៉ាន ម៉ាលីម៉ះ។[១៣៧] ប្រវត្តិរូបអ្នកទោសស-២១របស់ឈ្មោះ តាឡុស ម៉ាត់[១៣៨] ចម្លើយសារភាពពីមន្ទីរស-២១[១៣៩] និង ឈ្មោះរបស់គាត់នៅក្នុងបញ្ជីអ្នកទោសស-២១រូម[១៤០] បញ្ជាក់ថា គាត់ពិតត្រូវឃុំឃាំង និង សម្លាប់នៅមន្ទីរស-២១។

---

[១៣២] *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ សា ម៉ាត់ ហៅ សារឿន, ឯកសារលេខ E2/45.5 ។ ម្ដាយរបស់ សា ម៉ាត់ ឈ្មោះ ស្មាន សរ។ ដោយសារថាស្មាន សរ និង ស្មាន ណុប ជាបងប្អូនបង្កើត ដូច្នេះ សា ម៉ាត់ ត្រូវជាក្មួយរបស់ស្មាន ណុប។

[១៣៣] *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសស-២១រូម, ១៩ ឧសភា ២០០៩, ឯកសារលេខ E68.1, ln 9399 ។

[១៣៤] *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ស្មាន ស្លេះ, ១៩ ឧសភា ២០០៩, ឯកសារលេខ E2/44.1 ។

[១៣៥] *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសស-២១រូម, ១៩ ឧសភា ២០០៩, ឯកសារលេខ E68.1, ln 9399 ។

[១៣៦] *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ សា ម៉ាត់ ហៅ សារឿន, ឯកសារលេខ E2/45.5 ។

[១៣៧] *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ម៉ាន ម៉ាត់, ឯកសារលេខ E2/51.3 (ដែលនៅក្នុងនោះមានបញ្ជាក់ឈ្មោះម្ដាយ "ម៉ាន ម៉ះ")។ *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង,
សេចក្ដីសម្រេចអំពីឋានៈដើមបណ្ដឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណី E2/36, E2/51 និង E2/69, ៤ មិនា ២០០៩, ឯកសារលេខ E2/44/2, ទំព័រ ២ (ដែលមានបញ្ជាក់ថាបានទទួល ប័ណ្ណបោះឆ្នោតរបស់ម៉ាន ម៉ះ និង បញ្ជាក់អំពីឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ម៉ាន ម៉ះ)។

[១៣៨] *សំណុំរឿងការ ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ម៉ាន ម៉ាត់, ឯកសារលេខ E2/51.3 ។

00400006

E159/7

៤៧. ជនរងគ្រោះផ្ទាល់ ធួក លួន ហៅ យ៉ន ជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម ឡេង (D25/23)។[១៤១] ប្រវត្តិរូបអ្នកទោសស-២១របស់ធួក លួន[១៤២] និង ឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៤៣] បញ្ជាក់ថា គាត់ពិតជាត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។

៤៨. ជនរងគ្រោះផ្ទាល់ សួស សុវណ្ណ ត្រូវជាបងស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សួស សារិន (D25/24)។[១៤៤] ប្រវត្តិរូបអ្នកទោសរបស់សួស សុវណ្ណ[១៤៥] និង រូបថតពីមន្ទីរស-២១[១៤៦] និង ឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៤៧] បញ្ជាក់ថា គាត់ពិតជាត្រូវឃុំឃាំង និង សម្លាប់នៅមន្ទីរស-២១។

---

[១៣៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ចម្លើយសារភាពអ្នកទោសស-២១របស់ម៉ាន ម៉ាត់ ហៅ ម៉ាន, ឯកសារលេខ E2/51.5 ។

[១៤០] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសស-២១រួម, ១៩ ឧសភា ២០០៩, ឯកសារលេខ E68.1, ln.5302 ។

[១៤១] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ យឹម ឡេង, ៨ សីហា ឆ្នាំ២០០៨, ឯកសារលេខ D25/23 ។

[១៤២] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសរបស់ធួក លួន ហៅ យ៉ន, ឯកសារលេខ D25/23/2 ។

[១៤៣] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 10646 ។

[១៤៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ សួស សារិន, ៨ សីហា ឆ្នាំ២០០៨, ឯកសារលេខ D25/24 (ដែលមានដាក់ឈ្មោះឪពុកជា សួស ភឹម និង ម្តាយឈ្មោះ ចិន ហ៊ិន)។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសមន្ទីរទួលស្លែងរបស់ សួស សុវណ្ណ, ឯកសារលេខ D25/24/3 (ដែលមានដាក់ឈ្មោះឪពុកជា សួស ឡាញ់ និង ម្តាយឈ្មោះ ចិន ហេន)។ បន្ទាប់ពីសួស សារិន ទទួលអនិច្ចកម្មកាលពីថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៩ សួស សារិន ត្រូវបានតំណាងដោយប្តីរបស់គាត់នៅក្នុងសវនាការទាំងនេះ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងអំពីការស្លាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីសួស សារិន, ២៣ មករា ឆ្នាំ២០០៩, ឯកសារលេខ E2/S/1 ។

[១៤៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែងរបស់ឈ្មោះ សួស សុវណ្ណ, ឯកសារលេខ D25/24/3 ។

[១៤៦] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតរបស់ សួស សុវណ្ណ នៅទួលស្លែង, ឯកសារលេខ D25/24/5 ។

[១៤៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 10208 ។

៤៩. ជនរងគ្រោះផ្ទាល់ឈ្មោះ កែ កេងស៊ី ហៅ ដន ត្រូវបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ កែ ខុន (D25/25) និង កែ សាម៉ូត (E2/46)។[១៤៨] ប្រវត្តិរូបអ្នកទោសទួលស្លែងរបស់កែ កេងស៊ី[១៤៩] និងឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៥០] បញ្ជាក់ថា គាត់ពិតជាត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។

៥០. ជនរងគ្រោះផ្ទាល់ឈ្មោះ ឆៃ ហេង ត្រូវជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឆៃ ហ៊ាប (D25/10)។[១៥១] ប្រវត្តិរូបអ្នកទោសស-២១របស់ ឆៃ ហេង (មានភ្ជាប់ជាមួយនូវរូបថត) បញ្ជាក់ថា គាត់ពិតជាត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។[១៥២]

៥១. ជនរងគ្រោះផ្ទាល់ឈ្មោះ ម៉ៃឃើល ឌីដស៍ (Michael Deeds) ត្រូវជាប្អូនប្រុសរបស់ ធីម៉ូស៊ី ឌីដស៍ (Timothy Deeds) (D25/22)។[១៥៣] ចម្លើយសារភាពរបស់ម៉ៃឃើល ឌីដស៍ ពីមន្ទីរស-២១ បញ្ជាក់ថា គាត់ត្រូវបានឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។[១៥៤]

---

[១៤៨] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ កែ ខុន, ៨ សីហា ឆ្នាំ២០០៨, ឯកសារលេខ D25/25 (ដែលមានដាក់ឈ្មោះឪពុកជា កែ ស៊ីវ និង ម្តាយឈ្មោះ យង់ តាន់)។ *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ កែ សាម៉ូត, ៣ កញ្ញា ឆ្នាំ២០០៨, ឯកសារលេខ E2/46 (ដែលមានដាក់ឈ្មោះឪពុកជា កែ ស៊ីវ និង ម្តាយឈ្មោះ យង់ តាន់ )។ *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែងរបស់កែ កេងស៊ី, ឯកសារលេខ D25/25/2 (ដែលមានបញ្ជាក់ឈ្មោះឪពុកជា កែ ស៊ីវ និង ម្តាយឈ្មោះ យង់ តាន់)។

[១៤៩] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែងរបស់ កែ កេងស៊ី, ឯកសារលេខ D25/25/2 ។

[១៥០] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 3064 ។

[១៥១] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែរបស់ ឆៃ ហេង, ឯកសារលេខ D25/10/2, សំបុត្រកំណើតរបស់ឆៃ ហ៊ាប (ឧបសម្ពន្ធ"គ"). (ប្រវត្តិរូបរបស់អ្នកទោសទួលស្លែង ឯកសារលេខ D25/10/2 មានដាក់ឈ្មោះឪពុកម្តាយដូចគ្នាទៅនឹងឈ្មោះឪពុកម្តាយមាននៅក្នុងសំបុត្រកំណើតរបស់ឆៃ ហ៊ាប)។ *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ ឆៃ ហ៊ាប, ៨ សីហា ឆ្នាំ២០០៨, ឯកសារលេខ D25/10 ។

[១៥២] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែរបស់ ឆៃ ហេង, ឯកសារលេខ D25/10/2 ។

[១៥៣] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ ធីម៉ូស៊ី ស្កុត ឌីដស៍ (Timothy Scott Deeds), ៨ សីហា ឆ្នាំ២០០៨, ឯកសារលេខ D25/22 ។ *សំណុំរឿងការ៉ង ហ្គេកអ៊ាវ*, ០០១/១៨-

៥២. ជនរងគ្រោះផ្ទាល់ រូន ម៉ាត់ ហៅ រូន សារី ជាបងប្អូនប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី រូន ស្រីណុប (E2/42)។[១៥៥] រូន ម៉ាត់ ហៅ សារី មានឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៥៦] និង ចម្លើយសារភាព[១៥៧] និង ប្រវត្តិរូប[១៥៨] បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។

៥៣. ជនរងគ្រោះផ្ទាល់ អ៊ីស្មាអែល អាម៉ាត់ ហៅ សុខ ជាបងប្រុសរបស់ឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី អែល លីម៉ះ (E2/43)។[១៥៩] ប្រវត្តិរូបអ្នកទោសស-២១របស់អ៊ីស្មាអែល អាម៉ាត់[១៦០] និង ឈ្មោះនៅក្នុង បញ្ជីអ្នកទោសរួម[១៦១] បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។

---

០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីចម្លងលិខិតឆ្លងដែនរបស់ ធីម៉ូស៊ី ឌីដស៍, ឯកសារលេខ D25/22/1។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់ម៉ែឃើល ស្កុត ឌីដស៍, ១ មិថុនា ២០០៩ ឯកសារលេខ D25/22/3, ទំព័រ ២ ( មានបញ្ជាក់ឈ្មោះបងប្រុសថាជា ធីម៉ូស៊ី) ។

[១៥៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់ម៉ែឃើល ស្កុត ឌីដស៍, ១ មិថុនា ២០០៩ ឯកសារលេខ D25/22/3 ។

[១៥៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសរបស់រូន ម៉ាត់ ហៅ សារី, ឯកសារលេខ E2/42.3, ទំព័រ៥ ( មានបញ្ជាក់ថា ឪពុកឈ្មោះរូន និង ម្តាយឈ្មោះ លី ជីប) ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ រូន ស្រីណុប, ១៦ សីហា ២០០៨ ឯកសារលេខ E2/42 ។

[១៥៦] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1 ។

[១៥៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ចម្លើយសារភាពរបស់រូន សារី, ឯកសារលេខ E5/2.5 ។

[១៥៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសរបស់រូន ម៉ាត់ ហៅ សារី, ឯកសារលេខ E2/42.3 ។

[១៥៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់អែល លីម៉ះ, ១៩ សីហា ២០០៨, ឯកសារលេខ E2/43 ( មានបញ្ជាក់ឈ្មោះឪពុកជា លី អ៊ីស្មាអែល និង ម្តាយឈ្មោះ យូសុះ អារីហ្វាស់ និង មានបញ្ជាក់ថាជា ខ្មែរអ៊ីស្លាម) ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបរបស់អ៊ីស្មាអែល អាម៉ាត់ ហៅ សុខ, ឯកសារលេខ E2/43.3 ( មានបញ្ជាក់ឈ្មោះឪពុកជា លី អែល និង ម្តាយឈ្មោះ សូ ភស្ស និង មានបញ្ជាក់ថាជា ខ្មែរអ៊ីស្លាម) ។

[១៦០] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបរបស់អ៊ីស្មាអែល អាម៉ាត់ ហៅ សុខ, ឯកសារលេខ E2/43.3 ។

៥៤. ជនរងគ្រោះផ្ទាល់ឈ្មោះ មិន កាន ត្រូវជាកូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ែន ឡាយ (E2/47) ។[១៦២] មិនកាន មានឈ្មោះនៅលើបញ្ជីអ្នកទោសរួម ចូលក្នុងមន្ទីរស-២១នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៥ និង ក្រោយមកត្រូវសម្លាប់នៅឆ្នាំ១៩៧៥ ។[១៦៣]

៥៥. ជនរងគ្រោះផ្ទាល់ឈ្មោះ ញ៉ែម ចុល ហៅ រ៉ា ជាបងស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ែម សុផាន (E2/48) ។[១៦៤] ញ៉ែម ចុល ហៅ រ៉ា មានឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៦៥] ហើយនេះបញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១ ។

៥៦. ជនរងគ្រោះផ្ទាល់ ស្រី យ៉េង ជាប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ កុំ ម៉ែន ឬ គុម ម៉ែន (E2/48) ។[១៦៦] ប្រវត្តិរូបអ្នកទោសស-២១ (មានរូបថត)របស់ស្រី យ៉េង[១៦៧] និង ឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៦៨] បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១ ។

---

[១៦១] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 3015 ។

[១៦២] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ម៉ែន ឡាយ, ២ កញ្ញា, ឯកសារលេខ E2/47 ។

[១៦៣] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 5723 ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ឈ្មោះ មិន កាន, ឯកសារលេខ E2/47.3 ។

[១៦៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ញ៉ែម សុផាន, ៣ កញ្ញា ២០០៨, ឯកសារលេខ E2/48 ។

[១៦៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 6401 ។

[១៦៦] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់កុំ ម៉ែន, ៩ កញ្ញា ២០០៨, ឯកសារលេខ E2/52 ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសរបស់ស្រី យ៉េង, ឯកសារលេខ E2/52.6 (មានបញ្ជាក់ឈ្មោះភរិយាជា គុំ ម៉ែន) ។

[១៦៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបរបស់ស្រី យ៉េង, ឯកសារលេខ E2/52.6 ។

[១៦៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 9961 ។

៩៧. ជនរងគ្រោះផ្ទាល់ឈ្មោះ ខឿង មួយស័រ ហៅ ខឿង បួយស័រ ជាបងប្អូនប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទ្រី ង៉ិចលាង (E2/48)។[១៦៩] មួយស័រ មានឈ្មោះនៅលើបញ្ជីឈ្មោះជនរងគ្រោះសម្លាប់នៅមន្ទីរស-២១ក្នុងឆ្នាំ១៩៧៦[១៧០] ហើយបញ្ជីអ្នកទោសរួមបានបញ្ជាក់ថា គាត់ចូល មន្ទីរស-២១ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧ និង ត្រូវសម្លាប់នៅថ្ងៃ២០ កក្កដា ឆ្នាំ១៩៧៧។[១៧១]

៩៨. ជនរងគ្រោះផ្ទាល់ឈ្មោះសុខ ហេង ជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ង៉ិចហុង (E2/48)។[១៧២] ប្រវត្តិរូបអ្នកទោសស-២១របស់សុខ ហេង (មានរូបថត)[១៧៣] និង ឈ្មោះនៅក្នុងបញ្ជីអ្នកទោសរួម[១៧៤] បញ្ជាក់ថាគាត់ត្រូវឃុំឃាំងខ្លួន និង សម្លាប់នៅមន្ទីរស-២១។

៩៩. ជនរងគ្រោះផ្ទាល់ បេង ពុំ ជាបងប្អូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី បេង ចាន់ថន (E2/55)។[១៧៥] ប្រវត្តិរូបអ្នកទោសរបស់បេង ពុំ[១៧៦] និង ឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៧៧] បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។

---

[១៦៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ទ្រី ង៉ិចលាង, ១៦ កញ្ញា ២០០៨, ឯកសារលេខ E2/53។

[១៧០] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីជនរងគ្រោះសម្លាប់នៅមន្ទីរស-២១ (ទួលស្លែង), ឯកសារលេខ E2/53.2, ln. 4231។

[១៧១] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 3686។

[១៧២] ប័ណ្ណគ្រួសាររបស់ហេង ង៉ិចហុង (សូមមើលឧបសម្ព័ន្ធ"ត") (មានបញ្ជាក់ឈ្មោះ សុខ ហេង ជាឪពុក)។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ហេង ង៉ិចហុង, ១៨ កញ្ញា ២០០៨, ឯកសារលេខ E2/54 (មានបញ្ជាក់ថា សុខ ហេង ជាឪពុក និង មានបញ្ជាក់ទីកន្លែងកំណើតជាភូមិព្រៃករុន ឃុំព្រែកកុយ ស្រុកស្អាង ខេត្តកណ្តាល)។ *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោស សុខ ហេង, ឯកសារលេខ E2/54.3 (បញ្ជាក់ទីកន្លែងកំណើតថានៅភូមិព្រៃករុនលើ ឃុំព្រែកកុយ ស្រុក២០ ខេត្តកណ្តាល)។

[១៧៣] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោស សុខ ហេង, ឯកសារលេខ E2/54.3។

[១៧៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 9582។

[១៧៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់បេង ពុំ, ឯកសារលេខ E2/55.3 (មានបញ្ជាក់ថាម្តាយឈ្មោះ សោ ហេង និង ឪពុកឈ្មោះ ញឹប បេន ឬ ទៀម ប៉េង), អត្តសញ្ញាណប័ណ្ណ និង សំបុត្រកំណើតរបស់បេង ចាន់ថន (ឧបសម្ព័ន្ធ"ត") (មានដាក់ឈ្មោះម្តាយ សោ ហេង និង ឪពុកឈ្មោះ ញឹប បេន

E159/7

៦០. ជនរងគ្រោះផ្ទាល់ យន់ លឿន ជាក្មួយប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី យុន ឈីន (E2/55)។[១៧៨] ប្រវត្តិរូបអ្នកទោសស-២១របស់ យុន លឿន បញ្ជាក់ថា គាត់ត្រូវឃុំឃាំងខ្លួន និង សម្លាប់នៅមន្ទីរស-២១។[១៧៩]

៦១. ជនរងគ្រោះផ្ទាល់ឈ្មោះ អ៊ួយ វ៉ែន ឬ អ៊ួយ វ៉ៃន ហៅ ម៉ៅ ជាប្អូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី លី ឃៀក (E2/57)។[១៨០] ឈ្មោះរបស់អ៊ួយ វ៉ែន ត្រូវបានរកឃើញនៅលើ"បញ្ជីគ្រប់គ្រងអ្នកទោសស-២១ប្រចាំថ្ងៃ" នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ ដែលនេះបញ្ជាក់អំពីការឃុំខ្លួន និង ស្លាប់នៅមន្ទីរស-២១។[១៨១]

---

ឬ នៀម ប៉េង)។ *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ បេង ចាន់ថន, ១៧ កញ្ញា ២០០៨, ឯកសារលេខ E2/55 ។

[១៧៦] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបរបស់បេង ពុំ, ឯកសារលេខ E2/55.3 ។

[១៧៧] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 165 ។

[១៧៨] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសស-២១របស់ យុន លឿន, ឯកសារលេខ E2/56.2។ ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់យុន ឈីន, ១៧ កញ្ញា ២០០៨ ឯកសារលេខ E2/56។ អត្តសញ្ញាណបណ្ណ និង បណ្ណគ្រួសាររបស់ យុន ឈីន (ឧបសម្ពន្ធ"គ")។

[១៧៩] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោស សុខ ហេង, ឯកសារលេខ E2/54.3 ។

[១៨០] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ លី ឃៀក, ១៦ កញ្ញា ២០០៨, ឯកសារលេខ E2/57។ *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់លី ឃៀក, ឯលសារលេខ E165/1/4។ *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប័ណ្ណគ្រួសាររបស់ លី ឃៀក, ឯកសារលេខ E165/1/4.1។

[១៨១] *សំណុំរឿងការ៉ង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារពីប្រព័ន្ធគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកសារ D07177, ឯកសារលេខ E165/1/4.2។

៦២. ជនរងគ្រោះផ្ទាល់ ពូល តឿន ហៅ ចាំង ត្រូវជាឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី ពូល ពន្លឹក ហៅ ង៉ែត (E2/58)។[១៨២] ចម្លើយសារភាពពីមន្ទីរស-២១របស់ពូល តឿន[១៨៣] និង ឈ្មោះនៅលើបញ្ជីអ្នកទោសរួម បញ្ជាក់ថា គាត់ត្រូវឃុំឃាំង និង សម្លាប់នៅមន្ទីរស-២១។[១៨៤]

៦៣. ជនរងគ្រោះផ្ទាល់ ចាន់ ស៊ីនួន ជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ ក្រូច (E2/59)។[១៨៥] ប្រវត្តិរូបពីមន្ទីរស-២១របស់ចាន់ ស៊ីនួន[១៨៦] ឈ្មោះនៅលើបញ្ជីអ្នកទោសនិងអ្នកសួរចម្លើយនៅក្នុងក្រុម៨ របស់សមមិត្តសួន[១៨៧] និង ឈ្មោះនៅលើបញ្ជីអ្នកទោសរួម[១៨៨] បញ្ជាក់ថា គាត់ត្រូវឃុំឃាំង និង សម្លាប់នៅមន្ទីរស-២១។

---

[១៨២] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ ពូល ពន្លឹក ហៅ ង៉ែត, ២៨ វិច្ឆិកា ២០០៨, ឯកសារលេខ E2/58។

[១៨៣] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ចម្លើយសារភាពពីមន្ទីរស-២១របស់ ពូល តឿន ហៅ ចាំង, ឯកសារលេខ E2/58.6។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបសង្ខេបរបស់ពូល តឿន ហៅ ចាំង, ២៤ សីហា ២០០៩, ឯកសារលេខ E2/58.5។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារពីប្រព័ន្ធគ្រប់គ្រងទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជារបស់ពូល តឿន, ឯកសារ D07177, ឯកសារលេខ E2/58.3។

[១៨៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 7833។

[១៨៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ ចាន់ ក្រូច, ២២ មករា ២០០៩, ឯកសារលេខ E2/59។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, អត្តសញ្ញាណប័ណ្ណរបស់ចាន់ ក្រូច, ឯកសារលេខ E2/59.2។

[១៨៦] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបរបស់ចាន់ ស៊ីនួន, ៣ កញ្ញា ២០០៩, ឯកសារលេខ E2/59.5។ *សំណុំរឿងកាំង ហ្គេកអ៊ាវ.* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ចម្លើយសារភាពរបស់ចាន់ ស៊ីនួន, ៣១ សីហា ២០០៩, ឯកសារលេខ E2/59.6។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ចម្លើយសារភាពរបស់ចាន់ ស៊ីនួន នៅពេលសួរចម្លើយលើកទី៤៨, ២២ កញ្ញា ២០០៩, ឯកសារលេខ E2/59.7។

[១៨៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ក្រុម៨របស់សមមិត្តសួន, ១៦.៣១, ទំព័រ១០។

[១៨៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសរួម, ១៩ ឧសភា ឆ្នាំ២០០៩, ឯកសារលេខ E68.1, ln. 471។

00400013

E159/7

៦៤. ជនរងគ្រោះផ្ទាល់ នង គីមវ៉េត ជាបងស្រីបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី នង គីមលៀង (E2/60) ។[១៨៩] ប្រវត្តិរូបអ្នកទោសស-២១របស់នង គីមវ៉េត បញ្ជាក់ថា គាត់ត្រូវឃុំឃាំង និង សម្លាប់នៅមន្ទីរស-២១ ។[១៩០]

៦៥. ជនរងគ្រោះផ្ទាល់ [redacted] ជាបងប្អូនប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted] (E2/62) ។[១៩១] រូបថតអ្នកទោសស-២១របស់ [redacted] បញ្ជាក់ថា គាត់ត្រូវបានឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១ ។[១៩២]

៦៦. ជនរងគ្រោះផ្ទាល់ ប៉ែន អ៊ុម ហៅ វិត ជាបងប្អូនជីដូនមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណីសួន សៀង (D25/15) ។[១៩៣] ប្រវត្តិរូបរបស់អ្នកទោសប៉ែន អ៊ុម[១៩៤] និង ឈ្មោះនៅក្នុងបញ្ជីអ្នកទោសកម្ទេចនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៧ បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១ ។[១៩៥]

---

[១៨៩] *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ នង គីមលៀង, ២២ មករា ២០០៩, ឯកសារលេខ E2/60 ( មានបញ្ជាក់ឈ្មោះឪពុកថាជា នង ចឹង) ។ *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែង នង គីមវ៉េត, ២៨ សីហា ២០០៩, ឯកសារលេខ E2/60.1 ( មានបញ្ជាក់ឈ្មោះឪពុកថា នង ចឹង) ។ ទាំងពីរនាក់បងប្អូននេះប្រាប់ពីទីកន្លែងកំណើតដូចគ្នា ។

[១៩០] *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែងរបស់ នង គីមវ៉េត, ២៨ សីហា ២០០៩, ឯកសារលេខ E2/60.1 ។

[១៩១] *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១: សារណាផ្តល់ភស្តុតាងបញ្ជាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណី៩រូបក្នុងក្រុម១, ៣ កញ្ញា ២០០៩, ឯកសារលេខ E165 [បន្ទាប់ពីនេះ សារណានេះហៅកាត់ថា "សារណាស្តីអំពីដើមបណ្តឹងរដ្ឋប្បវេណី៩រូប"] ។ ប្រតិចារឹកថ្ងៃទី២៦ សីហា ២០០៩, ទំព័រ ៣៧-៤០ ។ *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតរបស់ [redacted] ឯកសារលេខ E165/1/1.2 ។ *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់ [redacted] ឯកសារលេខ E165/1/1 ។ *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតរបស់បងប្រុស [redacted] នៅមន្ទីរស-២១, ឯកសារលេខ E165/1/1.2 ។ *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ [redacted], ពត៌មានបន្ថែមសម្រាប់ផ្នែកគ, ២៧ សីហា ២០០៨, ឯកសារលេខ E2/62.2 ។

[១៩២] *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតរបស់ [redacted], ឯកសារលេខ E165/1/1.2 ។ *សំណុំរឿងការ៉ង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារពីប្រព័ន្ធទិន្នន័យរូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកសារលេខ E165/1/1.6 ។

៦៧. ជនរងគ្រោះផ្ទាល់ ណុប ង៉ាន ហៅ សរ ហៅ ចារើន ជាបងប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត សុខ (D25/20)។[១៩៦] ប្រវត្តិរូបអ្នកទោសស-២១របស់ណុប ង៉ាន បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។[១៩៧]

៦៨. ជនរងគ្រោះផ្ទាល់ ភាច គីម ត្រូវជាជីតាបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ិន ស៊ីណែត (E2/41)។[១៩៨] រូបថតពីមន្ទីរស-២១របស់ភាច គីម[១៩៩] និង "ឯកសារបាត់ខ្លួន"[២០០] បញ្ជាក់ថា គាត់ត្រូវឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។

---

[១៩៣] សូមមើលសារណាការអំពីដើមបណ្តឹងរដ្ឋប្បវេណី៩រូប. *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់សួន សៀង, ៨ សីហា ២០០៨, ឯកសារលេខ D25/15, ទំព័រ២, ប្រតិចារឹតថ្ងៃទី២៦ សីហា ២០០៩, ទំព័រ ២៦-២៧។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សៀវភៅគ្រួសាររបស់សួន សៀង, ឯកសារលេខ E165/1/2.1។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង. សអត្តសញ្ញាណប័ណ្ណរបស់សួន សៀង, ឯកសារលេខ E165/1/2។

[១៩៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបអ្នកទោសទួលស្លែងរបស់ ប៉ែន អ៊ុម, ២៨ សីហា ២០០៩, ឯកសារលេខ E165/1/2.6។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារពីប្រព័ន្ធទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជា, ប្រវត្តិរូប និង សកម្មភាពរបស់ ប៉ែន អ៊ុម ហៅ រិទ្ធ, ឯកសារ J00071, ឯកសារលេខ E165/1/2.4។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារពីប្រព័ន្ធទិន្នន័យប្រវត្តិរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ប្រវត្តិរូបរបស់ ប៉ែន អ៊ុម, ឯកសារ B12605, ឯកសារលេខ D25/15/1 ( ដែលមានបញ្ជាក់ថា ជនរងគ្រោះនេះចូលមន្ទីរស-២១នៅខែកក្កដា ១៩៧៧) ។

[១៩៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, បញ្ជីអ្នកទោសកម្ទេចនៅថ្ងៃ១៥ ខែតុលា ១៩៧៧, ឯកសារលេខ E165/1/2.2 ។

[១៩៦] *សំណុំរឿងកាំង ហ្គេកអ៊ាវ.* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់ង៉ែត សុខ, ៨ សីហា ២០០៨, ឯកសារលេខ D25/20។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់ង៉ែត សុខ, ឯកសារលេខ E165/1/5 ( ប្រៀបធៀបទៅនឹងប្រវត្តិរូបអ្នកទោស អ្នកទាំងពីរនេះមានបញ្ជាក់ឈ្មោះឪពុកម្តាយដូចគ្នា) ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, អត្តសញ្ញាណប័ណ្ណរបស់ង៉ែត សុខ, ឯកសារលេខ E165/1/5.1 ។

[១៩៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារពីប្រព័ន្ធទិន្នន័យប្រវត្តិរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោក សរ, ឯកសារលេខ D25/20/2។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបជនរងគ្រោះ, ឯកសារលេខ E165/1/5.3 ។

[១៩៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់ស៊ិន ស៊ីណែត ហៅ ស្រ៊ុន, ២២ មករា ២០០៩, ឯកសារលេខ E2/41.1។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-

៦៩. ជនរងគ្រោះផ្ទាល់ ម៉ាឃិត ជាបងប្រុសបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីលឹម យ៉ុន (E2/69) ។[២០១] លឹម យ៉ុន បានប្រាប់អំពីការដឹងរបស់គាត់អំពីការឃុំខ្លួន និង សម្លាប់នៅមន្ទីរស-២១។[២០២] លឹម យ៉ុន

---

អ.វ.ត.ក/សាលាដំបូង, រូបថតរបស់ដើមបណ្តឹងរកឃើញរូបថតជីតានៅមន្ទីរស-២១, ឯកសារលេខ **E165/1/3.5** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីប្រកាសរកក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារលេខ **E165/1/3.6** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់ស៊ិន ស៊ីណែត, ឯកសារលេខ **E165/1/3** (ប្រើប្រាស់អស័យដ្ឋានបច្ចុប្បន្ន មិនមែនទីកន្លែងកំណើតទេ ដោយសារថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបែកចេញពីក្រុមគ្រួសារតាំងពីនៅតូច) ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សៀវភៅគ្រួសាររបស់ស៊ិន ស៊ីណែត, ឯកសារលេខ **E165/1/3.1** ។ ប្រតិចារឹក ថ្ងៃទី២៦ សីហា ២០០៩, ទំព័រ ៣៥-៣៦ ។

[១៩៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតជនរងគ្រោះនៅមន្ទីរស-២១, ឯកសារលេខ **E165/1/3.4** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតរបស់ដើមបណ្តឹងរកឃើញរូបថតជីតានៅមន្ទីរស-២១, ឯកសារលេខ **E165/1/3.5** ។

[២០០] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ឯកសារបាត់ខ្លួនរបស់ជនរងគ្រោះ, ឯកសារលេខ **E165/1/3.3** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតរបស់ដើមបណ្តឹងរកឃើញរូបថតជីតានៅមន្ទីរស-២១, ឯកសារលេខ **E165/1/3.5** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ប្រវត្តិរូបជនរងគ្រោះ, ឯកសារលេខ **E165/1/3.2** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, រូបថតរបស់ជនរងគ្រោះនៅមន្ទីរស-២១, ឯកសារលេខ **E165/1/3.4** ។

[២០១] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្តឹងរដ្ឋប្បវេណីរបស់លឹម យ៉ុន, ១៣ មិនា ២០០៨, ឯកសារលេខ **E2/69** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់លឹម យ៉ុន, ៥ កុម្ភៈ ២០០៩, ឯកសារលេខ **E2/69.1** ។

[២០២] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងបន្ថែមរបស់លឹម យ៉ុន, ឯកសារលេខ **E2/69.3** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំណើរសុំផ្លាស់ប្តូររបៀបចូលរួម, គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០ មករា ២០០៩, ឯកសារលេខ **E2/69.3** ។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់លឹម យ៉ុន, ២១ សីហា ២០០៩, ឯកសារលេខ **E2/69.1** ។

មិនត្រឹមតែរងគ្រោះដោយការប៉ះពាល់ផ្លូវចិត្តចំពោះការបាត់បង់បងប្រុសនោះទេ គាត់ត្រូវមើលថែចិញ្ចឹមកូនបីនាក់របស់បងប្រុសគាត់ ដោយប្រាក់ចំណូលតិចតួចរបស់គាត់។[២០៣]

៧០. ជនរងគ្រោះផ្ទាល់ ហេង ពុន ឬ ជុន ហៅ ជុន ជាស្វាមីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប (E2/75)។[២០៤] ស្វាមីរបស់ខៀវ នាប ត្រូវសម្លាប់នៅព្រៃស។[២០៥]

៧១. ជនរងគ្រោះផ្ទាល់ នង សារួតត្រូវជាបងប្អូនជីដូនមួយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នង សារ៉ាត (E2/73)។[២០៦] នង សារួតត្រូវបានគេដឹងថាត្រូវឃុំឃាំងខ្លួន និង សម្លាប់នៅមន្ទីរស-២១។[២០៧]

៧៣. ជនរងគ្រោះផ្ទាល់ ប្រាក់ ប៉ាត ជាស្វាមីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត អ៊ុយ (E2/73)។[២០៨] ប្រាក់ ប៉ាត ត្រូវធ្វើទារុណកម្ម និង សម្លាប់នៅមន្ទីរស-២១ ដោយសារគាត់ត្រូវគេចោទថាជាសេអ៊ីអា ឬ កាហ្សេបេ។[២០៩]

---

[២០៣] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់លឹម យ៉ុន, ៦ កុម្ភៈ ២០០៩, ឯកសារលេខ E2/69។

[២០៤] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ខៀវ នាប ហៅ ខៀវ រាប, ៥ កុម្ភៈ ២០០៩, ឯកសារលេខ E2/75។

[២០៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ខៀវ នាប ហៅ ខៀវ រាប, ៦ មិនា ២០០៩, ឯកសារលេខ E2/75។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់ខៀវ នាប ហៅ ខៀវ រាប, ៥ កុម្ភៈ ២០០៩, ឯកសារលេខ **E2/75.1**។

[២០៦] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់នង សារ៉ាត់ ហៅ ព័រ, ៣០ មករា ២០០៩, ឯកសារលេខ E2/73។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សំបុត្រកំណើតរបស់នង សារ៉ាត់, ៥ កុម្ភៈ ២០០៩, ឯកសារលេខ E2/73.1។

[២០៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់នង សារ៉ាត់ ហៅ ព័រ, ២០ សីហា ២០០៩, ឯកសារលេខ E2/74។

[២០៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ង៉ែត អ៊ុយ, ២១ ឧសភា ២០០៩, ឯកសារលេខ E2/74។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់ង៉ែត អ៊ុយ, ៥ កុម្ភៈ ២០០៩ (ថ្ងៃដាក់ជូនជាភាសាខ្មែរ), ឯកសារលេខ E2/74.1។

[២០៩] *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, ពាក្យបណ្ដឹងរដ្ឋប្បវេណីរបស់ង៉ែត អ៊ុយ, ២១ ឧសភា ២០០៩, ឯកសារលេខ E2/74។ *សំណុំរឿងកាំង ហ្គេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, លិខិតអំណះអំណាងរបស់ង៉ែត អ៊ុយ, ២៤ សីហា ២០០៩, ឯកសារលេខ **E2/74.1**។

## V. ពិរុទ្ធភាពរបស់ជនជាប់ចោទ

### ក. សេចក្ដីផ្ដើម

៧៣. ក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៣៧នាក់ក្នុងក្រុមទីមួយ គឺមានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៣៦នាក់ដែលត្រូវជាសាច់ញាតិរបស់ជនរងគ្រោះដែលត្រូវបានឃុំឃាំង និង សម្លាប់នៅមន្ទីរស-២១។ មិនមានដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ដឹងច្បាស់ពីរយៈពេលដែលសាច់ញាតិរបស់គាត់ត្រូវបានឃុំខ្លួននៅមន្ទីរស-២១មុនពេលដែលត្រូវបានយកទៅ"កម្ទេច"យ៉ាងព្រៃផ្សៃទេ។ ដូចដែលដើមបណ្ដឹងរដ្ឋប្បវេណី រ៉ូប៊ឺត ហាមីល[២១០], ហាវ សោភា[២១១] និង នេត ផល្លី[២១២] បានបង្ហាញពីអារម្មណ៍ដ៏ខ្លោចផ្សារ ជាពិសេសការជឿងឆ្ងល់ពីកម្រិតនៃការឈឺចាប់ និងរងទុក្ខវេទនាដែលត្រូវបានបង្កលើខ្លួនសាច់ញាតិរបស់ពួកគាត់ខណៈពេលដែលត្រូវឃុំខ្លួននៅមន្ទីរស-២១។ រហូតមកដល់ថ្ងៃនេះ ភាពមិនច្បាស់លាស់នៃរយៈពេល និងកម្រិតនៃការឈឺចាប់ ព្រមទាំងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះទាំងនោះ នៅតែបន្តលងរំខានបុគ្គលជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗរហូតមកដល់សព្វថ្ងៃនេះ។[២១៣] គោលបំណងសំខាន់បំផុតសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការនោះ គឺដើម្បីជួយដល់ការជីកកកាយការពិតដោយបង្ហាញពីសារជាតិជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទឈ្មោះ ឌុច នៅមន្ទីរស-២១, មុខនាទីរបស់គុកនេះ និងការទទួលខុសត្រូវចំពោះការស្លាប់អ្នកទោសទាំងអស់នៅមន្ទីរស-២១។ ក្នុងកិច្ចខិតខំធ្វើការស្វែងយល់ពីជោគវាសនាសាច់ញាតិរបស់ពួកគាត់ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះត្រូវការការវិនិច្ឆ័យមួយដែលបង្ហាញការពិតដ៏ជាក់ច្បាស់ពីតួនាទីពិតប្រាកដរបស់ឌុចនៅមន្ទីរស-២១, ស្ថានភាពផ្លូវចិត្ត, អំណាច និងឥទ្ធិពលពិតប្រាកដរបស់ ឌុច ហួសពីជញ្ជាំងនៃមន្ទីរស-២១ទៅទៀត នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារតែបទពិសោធន៍ និង ផលប្រយោជន៍របស់ពួកគេ ដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដល់នូវទស្សនៈ និងការវិភាគដ៏ពិសេសមួយលើភស្តុតាងដែលត្រូវបានបង្ហាញនៅអំឡុងនៃដំណើរការនីតិវិធី។[២១៤]

---

[២១០] ប្រតិចារឹត ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩, ទំព័រ ៩៨-៩៩។

[២១១] ប្រតិចារឹត ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, ទំព័រ ៤៧-៤៩។

[២១២] ប្រតិចារឹត ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, ទំព័រ ១០០-១០១។

[២១៣] សូមមើល ឧទាហរណ៍: ប្រតិចារឹត ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩, ទំព័រ ១១១។

[២១៤] សូមមើល ជំពូកទី II ខាងលើ ផ្នែក ខ នៅវាក្យខណ្ឌទី ៧។

៧៤. ខណៈពេលដែលឌុចតែងតែសំដែងនូវអារម្មណ៍វិប្បដិសារី និងឈរលើគោលជំហរការសុំទោស និងព្យាយាមផ្តាច់ខ្លួនឱ្យឆ្ងាយពីការពិតដ៏គួរឱ្យរន្ធត់នៃមន្ទីរស-២១ក៏ដោយ ក៏ភស្តុតាងនៅពេលសវនាការបានបង្ហាញថា ឌុច មិនបានប្រាប់ពីការពិតទាក់ទងនឹងផ្នែកសំខាន់ៗនៃតួនាទីរបស់ខ្លួននៅមន្ទីរស-២១ នោះទេ។ ជាក់ស្តែងណាស់ ឌុច គឺពិតជាមានការជ្រើសរើសណាស់ចំពោះផ្នែកណាមួយនៃមន្ទីរស-២១ ដែលគាត់នឹងត្រូវយកមកនិយាយ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ នឹងដាក់ជូនដោយក្តីគោរព នូវបួនចំណុចដែលបង្ហាញថា ឌុច ពុំព្រមបង្ហាញ និងមិនស្មោះត្រង់នៅក្នុងដំណើរនីតិវិធីនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ នឹងបង្ហាញពីរបៀបដែលភស្តុតាងទាំងនោះផ្ទុយពីពាក្យសំដីរបស់ ឌុច ព្រមទាំងបញ្ជាក់អំពី (១) ស្វយ័តភាពដ៏ធំទូលាយរបស់ ឌុច ក្នុងនាមជាប្រធានមន្ទីរស-២១, (២) ភាពឃោរឃៅហួសហេតុ និងមិនចាំបាច់ដែលត្រូវបានធ្វើទៅលើអ្នកទោសនៅស-២១ ជាពិសេសបើប្រៀបធៀបទៅនឹងកម្រិត និង ប្រភេទនៃការធ្វើបាបដែលត្រូវបានប្រព្រឹត្តនៅឯមន្ទីរឃុំខ្លួនផ្សេងៗ។ (៣) ការរួមចំណែកដោយផ្ទាល់ និងគ្រោះថ្នាក់ ទៅលើប្រព័ន្ធនៃការសួរចម្លើយនៅមន្ទីរស-២១ ដែលបន្ថែមទៅលើភាពជ្រុលនិយមរបស់គណៈអចិន្ត្រៃយ៍ និងនាំទៅដល់ការបោសសម្អាតនិងចាប់ខ្លួនទ្រង់ទ្រាយធំ, (៤) កិច្ចខំប្រឹងប្រែងជាប្រចាំរបស់ ឌុច សម្រាប់ស្វ័យអភិវឌ្ឍន៍លើវិធីសាស្ត្រដើម្បីបំពេញចិត្តថ្នាក់លើ និង (៥) ស្ថានភាពផ្លូវចិត្ត និងការលើកទឹកចិត្តនៅមន្ទីរស-២១។ ឌុច មិនត្រូវបានបណ្តុះឡើងដោយសារការងាររបស់ខ្លួន និង កាលៈទេសៈនោះទេ។ វាគឺមានលក្ខណៈផ្ទុយស្រឡះទៅវិញ នោះគឺ ឌុច បណ្តុះតួនាទីរបស់ខ្លួនជាប្រធានមន្ទីរស-២១ ដោយខ្លួនឯងផ្ទាល់។

**១. ឌុចមានស្វ័យ័តភាពដ៏ធំទូលាយក្នុងនាមជាប្រធានមន្ទីរស-២១**

៧៥. អំឡុងពេលនៃដំណើការនីតិវិធី ឌុច បានអះអាងដដែលៗថា ខ្លួនមានស្វយ័តភាពតិចតួចបំផុត ឬសឹងតែគ្មានផង ខណៈពេលដែលខ្លួនកាន់កាប់មន្ទីរស-២១ រាល់ថ្ងៃអស់រយៈពេល៤ឆ្នាំ។[២១៥] នៅក្នុង

---

[២១៥] សូមមើល ឧទាហរណ៍: ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៨។ (ឌុច និយាយថា ការសម្រេចចិត្តក្នុងការធ្វើទារុណកម្មអ្នកទោសសំខាន់ៗនៅមន្ទីរស-២១ គឺតែងតែធ្វើឡើងតាមបង្គាប់របស់ថ្នាក់លើ។) សូមមើល ប្រតិចារឹត ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៨ (ឌុច និយាយថា ថ្នាក់លើនឹងសម្រេចទៅលើរយៈពេលនៃការឃុំខ្លួនអ្នកទោសសំខាន់ៗ។) សូមមើល ប្រតិចារឹត ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៥២ (ឌុច បានអះអាងថា សុន សេន នឹងទាក់ទងខ្លួនជារៀងរាល់ថ្ងៃតាមរយៈទូរស័ព្ទ ដើម្បីគ្រប់គ្រងទៅលើការងាររបស់ឌុច និងដើម្បីផ្តល់ការណែនាំ ម្យ៉ាងទៀត សុន សេន ក៏មកលេង ឌុច ជារៀងរាល់ថ្ងៃដើម្បីបញ្ជាក់ឱ្យច្បាស់ថា ឌុច ពិតជាកំពុងអនុវត្តន៍ទៅតាមមាគ៌ាបក្សត្រឹមត្រូវយ៉ាងណា។) ប្រតិចារឹត ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៩-៣០។

ទល្មីករណីមួយដូចគ្នាដែលត្រូវបានលើកឡើងនៅពេលកាត់ទោស អៃក្មាន់ នៅប្រទេសអ៊ីស្រាអែល[២១៦] ឌុច រក្សានូវគោលជំហរដែលថា គាត់មិនបានធ្វើអ្វីផ្សេងក្រៅពីការគោរពទៅតាមបញ្ជា ដោយសារតែបញ្ជានោះត្រូវបានចង្អុលបង្ហាញឡើងដោយថ្នាក់លើមកឱ្យគាត់អនុម័ត។[២១៧] យោងទៅតាមការអះអាងរបស់ឌុច ប្រព័ន្ធនៃការលាក់ការណ៍សម្ងាត់ និងការបំភិតបំភ័យដែលបានជ្រាបចូលទៅគ្រប់ជួរតំណែងទាំងអស់របស់ខ្មែរក្រហម បានរារាំងមិនឱ្យមានការចចេសរឹងរូសនោះមិនគោរពតាមបញ្ជាទេ។[២១៨]

៧៦. នៅក្នុងករណីរបស់ឌុច ការរៀបរាប់ពីព្រឹត្តិការណ៍នេះគឺមិនអាចត្រូវបានបន្ទាយឱ្យឆ្ងាយពីការពិតនោះទេ។ ឌុច មិនត្រឹមតែកាន់កាប់អំណាចនៅមន្ទីរស-២១យ៉ាងរឹងមាំទេ គាត់ថែមទាំងធ្វើដូច្នេះខណៈពេលដែលធ្វើការកែប្រែ និងធ្វើឱ្យកាន់តែប្រសើរឡើងជាប្រចាំ ក្នុងគោលបំណងធ្វើឱ្យមន្ទីរស-២១ក្លាយទៅជាប្រព័ន្ធដែលមានសមត្ថភាពជាងគេបំផុតតាមដែលគាត់អាចធ្វើទៅបាន តាមរយៈការអនុវត្តនូវស្វយ័តភាពរបស់ខ្លួន។ ឌុច មានអំណាច និងឆន្ទានុសិទ្ធគ្រប់គ្រាន់ក្នុងការសម្រេចថាតើគួរតែទុកជីវិតនរណាម្នាក់ឬយ៉ាងណា។[២១៩] ឌុច មានសមត្ថភាពក្នុងការស្នើសុំក្រុមមនុស្សជាក់លាក់មួយដើម្បីឱ្យ

---

[២១៦] សូមមើល *Attorney General v. Eichmann,* Criminal Case No. 40/61, សាលក្រម, Dist. Ct. of Jerusalem, ១១ ធ្នូ ១៩៦១, វាក្យខណ្ឌ ២៤៣ (ពួកយើងមើលឃើញម្តងហើយម្តងទៀតទាក់ទងនឹងការបត់បែនគំនិតរបស់គាត់ដោយស្ថិតក្រោមការជះឥទ្ធិពលនៃការត្រួតពិនិត្យយ៉ាងល្អិតល្អន់ ការដកថយចេញពីការបដិសេធទាំងស្រុងមកជាការបដិសេធដោយផ្នែកវិញ ហើយមានតែនៅពេលដែលគ្មានជម្រើសតែប៉ុណ្ណោះ នោះនឹងក្លាយជាការទទួលស្គាល់កំហុស។ ប៉ុន្តែជាការពិតណាស់ គាត់តែងតែស្វែងរកជម្រកមួយនៅក្នុងការសារភាពរបស់ខ្លួនចំពោះគ្រប់រឿងទាំងអស់ មិនថាតូចឬធំក្តី គឺថា គាត់អនុវត្តទៅតាមបញ្ជាដែលដាក់មកតែប៉ុណ្ណោះ។)

[២១៧] សូមមើល ឧទាហរណ៍: ប្រតិចារឹក ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ ២៤-២៥, ៧១, ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៤១-៤២, ៧៩ ។

[២១៨] សូមមើល ឧទាហរណ៍: ប្រតិចារឹក ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៣៧។

[២១៩] សូមមើល ឧទាហរណ៍: ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៩។ (ឌុច: "ខ្ញុំស្ទើរតែភ្លេចទៅហើយ មានអ្នកទោសស្រីម្នាក់ អាយុ ៦៤ ឆ្នាំ គាត់គឺជាពេទ្យធ្មេញ។ ខ្ញុំឃុំគាត់នៅក្នុងគុក។ នៅពេលដែលវៀតណាមចូលមកដល់ ពួកយើងរត់ទៅជាមួយគ្នា ប៉ុន្តែគាត់ស្លាប់ដោយសារជម្ងឺ")។ សូមមើល ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៩-៣០។ (រៀបរាប់ពីអង្គហេតុដែលថាមនុស្សបីនាក់ត្រូវបាន ឌុច ទុកជីវិតឱ្យ ហើយដែលក្រោយមកក៏រត់គេចខ្លួនជាមួយ ឌុច នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ទីកន្លែង។)

ចាកផុតពីការកម្ទេច។[២២០] ឌុច ទទួលរ៉ាប់រងការអប់រំបុគ្គលិកមន្ទីរស-២១តែម្នាក់ឯង មិនថាតែការសួរចម្លើយ និងមាគ៌ាបក្សនោះទេ។[២២១] ឌុច ត្រូវបានផ្តល់អំណាចឱ្យកសាងអាគារថ្មីនៅមន្ទីរស-២១[២២២] ហើយឌុចបានសម្រេចជ្រើសយកជើងឯកជាកន្លែងសម្លាប់។[២២៣] ឌុច បានបង្កើតតារាងរចនាសម្ព័ន្ធនៅមន្ទីរស-២១[២២៤] ហើយឌុចក៏បានធានាផងដែរថានឹងមានការហ្វឹកហ្វឺនយ៉ាងល្អប្រសើរ។[២២៥] ស្វយ័តភាពដ៏ធំទូលាយដែល ឌុច ទទួលបាននៅមន្ទីរ ស-២១ ត្រូវបានបញ្ជាក់ យ៉ាងច្បាស់លាស់ និងប្រាកដបំផុតដោយបណ្ឌិតអេចផែស្សិន[២២៦] និងបណ្ឌិតឌឿរីដ ផែនដ្ឋ័រ។[២២៧]

## ១. ឌុច មានអំណាចក្នុងការការពារមនុស្ស

៧៧. មានភស្តុតាងច្រើនលើសលប់ដែលត្រូវបានលើកឡើងនៅក្នុងសវនាការ ដែលបានលាតត្រដាងពីភាពទន់ខ្សោយនៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ខ្មែរក្រហម ដែលនឹងអនុញ្ញាតឱ្យកម្មាភិបាលដ៏មានឥទ្ធិពលម្នាក់ដូចជា ឌុច ជាដើម ដែលទទួលបានការការពារ[២២៨] និងជាអ្នកដែលមានការយល់ដឹងផ្ទៃក្នុងដ៏ពិសេស

---

[២២០] ប្រតិចារឹត ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៤។ (ឌុចៈ "នៅមន្ទីរស-២១គឺមានក្រុមមនុស្សចំនួន ២ ប្រភេទៈ អ្នកដែលជាជាងគំនូរ រឺអ្នកសិល្បៈ ហើយខ្ញុំបានស្នើទៅបក្សកុម្មុយនីស្តកម្ពុជាឱ្យទុកជីវិតពួកគេ។ ខ្ញុំចង់មានន័យថាជាអ្នកទោសដែលមិនត្រូវបានយកទៅកម្ទេច។ ពួកអ្នកទោសនោះនឹងត្រូវបានទុកជីវិតដើម្បីបម្រើឱ្យមន្ទីរ ស-២១។") ប្រតិចារឹត ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៩។ (ឌុចៈ "វាមានន័យថារាល់អ្នកទោសទាំងឡាយដែលនៅសល់ត្រូវតែកម្ទេចទាំងអស់ លើកលែងតែមនុស្ស បួន នាក់ប៉ុណ្ណោះដែលមកពីអង្គភាព យ-៨ ដែលខ្ញុំស្នើសុំទុកឱ្យពួកគេនៅរស់......ខ្ញុំចង់ឱ្យគេសួរចម្លើយអ្នកទាំងបួននេះសិន។")

[២២១] ប្រតិចារឹត ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៣៦។

[២២២] ប្រតិចារឹត ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៧១។ សូមមើលផងដែរនូវ ប្រតិចារឹត ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៩។ ប្រតិចារឹត ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៣៣។

[២២៣] ប្រតិចារឹត ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៧០។

[២២៤] ប្រតិចារឹត ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៣០។

[២២៥] ប្រតិចារឹត ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៤៧។

[២២៦] ប្រតិចារឹត ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ៨៩-៩០។

[២២៧] ប្រតិចារឹត ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៩៨-៩៩។

[២២៨] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, របាយការណ៍ចិត្តសាស្ត្ររបស់ ឌុច, E3/509, ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៨, ទំព័រ ១៨, ២១។ [ចាប់តាំងពីនេះមកនឹងហៅថា"របាយការណ៍ចិត្តសាស្ត្រ"] ឌុចព្រមទទួលយកអ្នកចិត្តសាស្ត្រអំឡុងដំណាក់កាលនៃសាលាដំបូង ដែលថា ឌុច ត្រូវបានការពារដោយ សុន សេន។

E159/7

មួយចំពោះប្រតិបត្តិការណ៍នានា[២២៩] ដើម្បីការពារ ឬជួយសង្គ្រោះជីវិតមនុស្សនៅក្នុងស្ថានភាពខ្លះ ប្រសិនបើគាត់ចង់ធ្វើ។ ជាការពិតណាស់ អតីតអ្នកនៅក្រោមបង្គាប់របស់ឌុចម្នាក់ឈ្មោះ ម៉ម ណៃ បានធ្វើការពន្យល់ថា ឌុចបានបញ្ជាក់ច្បាស់ចំពោះគាត់ថា គាត់អាចមានសមត្ថភាពការពារមនុស្សដែលបានចូលបម្រើបដិវត្តន៍អស់រយៈពេលយូរមកហើយ ដោយសារតែអ្នកទាំងនោះមិនទាន់ត្រូវបានចាប់ខ្លួនដោយពិតប្រាកដនៅឡើយទេ។[២៣០] សាក្សីជំនាញលោកបណ្ឌិត ឆែនដ្លឺរ បានបញ្ជាក់ថាកម្មាភិបាលមានសមត្ថភាពក្នុងការការពារមិត្តភ័ក្ត ក៏ដូចជាអ្នកក្រោមបង្គាប់របស់ខ្លួនចេញពីការចាប់ខ្លួន[២៣១] ហើយលោកក៏បាននិយាយពីទំហំនៃការឈឺចាប់អាចនឹងត្រូវបានបន្ធូរបន្ថយនៅមន្ទីរស-២១។[២៣២] អតីតអ្នកយាម

---

[២២៩] ប្រតិចារឹត ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៩៩-១០០។ (ថ្វីបើការបំបិទបំបាំងការហើសម្ងាត់កើតមានឡើងចំពោះអ្នកទាំងឡាយណាដែលអនុវត្តន៍ការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ សុន សេន នៅតែធ្វើការពិភាក្សា"ពីពាក្យសំដី រឺកិច្ចពិភាក្សារបស់សមាជិកផ្សេងទៀតនៅក្នុងជួរគណៈអចិន្ត្រៃយ៍"ជាមួយ ឌុច ដែរ។) ប្រតិចារឹត ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ៦០។ (លោកបណ្ឌិត Etcheson: "ឌុច មានឱកាសក្នុងការសួរចម្លើយអ្នកទោសមកពីគ្រប់អង្គភាពទាំងអស់របស់អង្គការ និងគ្រប់ជាន់ថ្នាក់ទាំងអស់មកពីទូទាំងប្រទេស។ ជាមួយនឹងការងារនោះ គាត់ទទួលបាននូវទស្សនៈដ៏ពិសេសមួយទាក់ទងនឹងអ្វីដែលបានកំពុងតែកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។")

[២៣០] ប្រតិចារឹត ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៤៧។ (ម៉ម ណៃ: "ប្រសិនបើខ្ញុំដឹងមុន ហើយពួកគេប្រាប់ខ្ញុំថាមនុស្សម្នាក់នេះមានរឿង ខ្ញុំអាចធ្វើការធានាថាមនុស្សម្នាក់នេះគឺជាសិស្សរបស់ខ្ញុំ។"

[២៣១] ប្រតិចារឹត ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៩៥។ (លោកបណ្ឌិត ឆែនដ្លឺរ បានបន្យល់ពីរបៀបដែលប្រព័ន្ធនៃការការពារមិត្តភ័ក្តរបស់បុគ្គលម្នាក់អាចដំណើរការទៅបាន។)

[២៣២] សម្លេងពីមន្ទីរ ស-២១, ទំព័រ ១៥៤។ (លោកបណ្ឌិត ឆែនដ្លឺរ: " "បង១ថ្នាក់លើ" ដែលដើរតាមក្រោយប្រតិបត្តិការនៅមន្ទីរស-២១ និង សុន សេន ព្រមទាំង ឌុច ដែលជាអ្នកទទួលខុសត្រូវដំណើរការទាំងអស់នេះដោយផ្ទាល់ដឹងថាអ្វីដែលគេកំពុងធ្វើ និងអ្វីដែលត្រូវធ្វើតទៅទៀត។ តាមការពិត បុគ្គលទាំងនេះ ប្រហែលជាអាចបន្ធូរបន្ថយការឈឺចាប់របស់អ្នកទោស ដោះលែងកូនក្មេងតូចៗដែលជាប់គុកជាមួយម្តាយ ឬបន្ធូរបន្ថយការកាប់សម្លាប់ ប្រសិនបើគេពិតជាចង់ធ្វើមែន។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺពិតជាមានពេលមួយដែលធ្វើឱ្យជម្រើសបែបនេះអាចធ្វើទៅបាន ហើយយុត្តិធម៌បដិវត្តន៍ក៏អាចធ្វើដោយក្តីមេត្តាបានដែរ។..... ប៉ុន្តែ ផ្ទុយមកវិញ សុន សេន, ឌុច និងអ្នកដែលធ្វើការនៅក្រោមបង្គាប់បានបង្កការឈឺចាប់ជាពន់ពេកមកលើអ្នកទោសដោយចិត្តត្រជាក់ជាលក្ខណៈប្រព័ន្ធ និងគ្មានវិប្បដិសារីចំពោះទង្វើរបស់ខ្លួនឡើយ។

[២៣៣] ប្រតិចារឹត ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ទំព័រ ១៧-១៨។ (សក្ខីកម្មរបស់ សោម ម៉េត)

នៅមន្ទីរស-២១ម្នាក់ បាននិយាយនៅក្នុងសវនាការអំពីឧទាហរណ៍ចំនួន២ដែលអ្នកយាមមន្ទីរស-២១ចាប់យកជំហានយ៉ាងជាក់លាក់ក្នុងការជួយសង្គ្រោះអ្នកដទៃ។[២៣៣]

### គ. ឌុចប្រើប្រាស់មុខតំណែងរបស់ខ្លួនដើម្បីបន្ថយរបបវិធីសាស្ត្រមិនចាំបាច់ និងឃោរឃៅមកលើអ្នកទោសមន្ទីរស-២១

#### ១. ឌុចព្យាយាមលាក់បាំងជាលក្ខណៈប្រព័ន្ធអំពីកម្រិតនៃការទទួលខុសត្រូវនៅមន្ទីរស-២១

៧៨. ដូចដែលលោកបណ្ឌិតអែចឆែស្សិន បានផ្តល់សក្ខីកម្មថា ភាគច្រើននៃមន្ទីរសន្តិសុខផ្សេងទៀត "មើលទៅហាក់ដូចជាប្រើប្រាស់នូវវិធីសាស្ត្រតូចៗ" បើប្រៀបធៀបទៅនឹងមន្ទីរស-២១។[២៣៤] ខណៈពេលដែលឌុច បានបញ្ជាក់ថាខ្លួនបានធ្វើឱ្យវិធីសាស្ត្រនៃការធ្វើទារុណកម្មនៅមន្ទីរស-២១ កាន់តែប្រសើរឡើង[២៣៥] ឌុចនៅតែព្យាយាមបង្រួមការដឹង និងតួនាទីរបស់ខ្លួនឱ្យកាន់តែតូចបំផុតទាក់ទងនឹងការអនុវត្តវិធីសាស្ត្រទាំងនោះ។[២៣៦] នៅពេលដែលប្រឈមមុខនឹងអំពើព្រៃផ្សៃជាក់លាក់ដែលធ្វើឡើងដោយ ឌុច

---

[២៣៤] ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ៦។

[២៣៥] ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រ ៦៧។

[២៣៦] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤៩។ (ឌុច : "...ខ្ញុំអាចនិយាយប្រាប់ថា យោងទៅតាមការចងចាំរបស់ខ្ញុំ ប្រសិនបើខ្ញុំមិនច្រឡំទេ ខ្ញុំធ្លាប់ធ្វើទារុណកម្ម ឈុិត អុីវ តែម្តងគត់ នៅពេលដែលខ្ញុំមានតំណែងជាអនុលេខាមន្ទីរនេះ។ ខ្ញុំជម្រាបបានតែប៉ុណ្ណឹងទេ។") សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៨, ២២។ (ដែល ឌុច នៅតែរក្សាជំហរថា ការសម្រេចចិត្តក្នុងការធ្វើទារុណកម្មអ្នកទោសសំខាន់ៗ គឺមានតែស្ថិតក្រោមសមត្ថកិច្ចរបស់ថ្នាក់លើតែម្យ៉ាងប៉ុណ្ណោះ) ។

[២៣៧] សូមមើល ឧទាហរណ៍: ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៨៩។ ឌុច បានអះអាងថាខ្លួនបានបដិសេធមិនអនុវត្តនីទៅតាមបញ្ជាដោយផ្ទាល់ពី នួន ជា ក្នុងការផ្តល់ថ្នាំដែលមានផ្ទុកសារធាតុគ្រោះថ្នាក់យ៉ាងខ្លាំងដល់អ្នកទោស ហើយផ្ទុយមកវិញធ្វើការជំនួសសារធាតុទាំងនោះដោយថ្នាំប៉ារ៉ាសេតាមុលទៅវិញ។ ឌុច បានធ្វើការពន្យល់ពីការចចេសរឹងរូសរបស់ខ្លួនដោយអះអាងថា ខ្លួនគ្រាន់តែមាននូវ"អារម្មណ៍អាណិតអាសូរភ្លាមៗ"ដោយសារតែខ្លួន"មិនចង់ប្រឡូកដៃដោយផ្ទាល់ក្នុងការសម្លាប់មនុស្សណាម្នាក់នោះទេ។" ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៤។ តាមសំដីរបស់ ឌុច មូលហេតុដែលវាយធ្វើបាបអ្នកទោសម្នាក់ នោះគឺដើម្បី "រារាំង ណាត មិនឱ្យទៅវាយអ្នកទោស។"

ខ្លួនឯង ឌុចបែរជាបំភ្លៃការពិត ហើយព្យាយាមបង្រួមកម្រិតនៃការទទួលខុសត្រូវរបស់ខ្លួនឱ្យកាន់តែតូចទៅវិញ។[២៣៧] តួយ៉ាង ឌុច ត្រូវប្រឈមមុខនឹងសំបុត្រមួយដែលខ្លួនសរសេរទៅ ប៊ុន ដែលណែនាំក្នុងន័យយ៉ាងច្បាស់លាស់ថា ត្រូវបន្តប្រើប្រាស់"ធមិក្តៅ"ដោយប្រើកម្លាំងបាយដែលឌុចខ្លួនឯងផ្ទាល់ដឹងថាអាចនឹង"ធ្វើឱ្យអ្នកទោសស្លាប់"។[២៣៨] ឌុចបដិសេធមិនទទួលខុសត្រូវ តែផ្ទុយមកវិញបែរជាអះអាងថា នោះគឺជា"វិធីសាស្ត្រក្នុងការកម្លាអ្នកទោស បន្លាចពួកគេដោយប្រើសំបុត្រ ដូចនេះអ្នកទោសនោះនឹងសារភាព"។[២៣៩] នៅពេលដែលប្រឈមមុខជាមួយការរៀបរាប់ពីវិធីសាស្ត្រនៃការធ្វើទារុណកម្មដោយមិនមែនស្ថិតនៅមូលដ្ឋាននៃសៀវភៅណែនាំ ដូចជាការដកក្រចក ឬក៏ការប្រើស៊ីម៉ង់សើមៗមកបាតលើមុខអ្នកទោស ឌុចបានអះអាងថា ខ្លួនមិនបានដឹងឮចំពោះការអនុវត្តទារុណកម្មទាំងនោះទេ ហើយខ្លួនបានបញ្ឈប់មិនឱ្យមានការអនុវត្តបន្តទៀតទេ នៅពេលដែលខ្លួនបានដឹងពីរឿងធ្វើទារុណកម្មទាំងនោះភ្លាម។[២៤០] ប្រសិនបើឌុចទទួលស្គាល់ថា អ្នកនៅក្រោមបង្គាប់របស់ខ្លួនមិនដែលត្រូវបានទទួលពិន័យចំពោះសកម្មភាពនៃការធ្វើទារុណកម្មនោះទេ[២៤១] ឌុច មើលទៅទំនងជាចងចាំតែរឿងការធ្វើ

---

[២៣៨] ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៣៩។

[២៣៩] ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៣៩។ ឌុច បានធានាចំពោះ ប៊ុន បន្ថែមថាគាត់ "នឹងមិនទទួលការពិន័យអ្វីនោះទេ" ប្រសិនបើគាត់បន្តប្រើប្រាស់ទារុណកម្មធមិក្តៅមកលើខ្លួនអ្នកទោស។

[២៤០] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៨៦-៨៧។

[២៤១] ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២១។

[២៤២] ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១០៧។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៨៨។ (ឌុច : "ការឱ្យសំពះសត្វឆ្កែគឺត្រូវបានយកមកអនុវត្តដោយសារតែប្រសិទ្ធិភាពរបស់វា។ ខ្ញុំទទួលស្គាល់ថាវាអាចប្រើប្រាស់បានដោយសារតែខ្ញុំឃើញថាធ្វើដូចនេះអ្នកទោសនឹងមិនត្រូវបានធ្វើបាបលើរាងកាយនោះទេ។") ឌុច បដិសេធមិនដឹងរឿងនៃការធ្វើទារុណកម្មបែបព្រៃផ្សៃបំផុតខ្លះៗដែលត្រូវបានលើកឡើងនៅក្នុងដំណើរការនីតិវិធី។ សូមមើល ឧទាហរណ៍ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១១៥។ (ការសិក្សាពីការវះកាត់ និងកាយវិភាគគឺត្រូវធ្វើឡើងលើខ្លួនអ្នកទោស)។ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៩២។ (សុដន់របស់អ្នកទោសស្រីត្រូវបានដុត ហើយសត្វល្អិតដែលមានពិសត្រូវបានយកមកប្រើលើខ្លួនអ្នកទោសទាំងអស់។) ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២១។ (អ្នកធ្វើការក្រោមបង្គាប់បានបង្ខំឱ្យអ្នកទោសម្នាក់ទទួលទានលាមករបស់ខ្លួនឯង។) ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៩ ទំព័រ ៧។ (អ្នកធ្វើការក្រោមបង្គាប់បានយកបារីមកអុជលើខ្លួនអ្នកទោស។) ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១១៤។ (ការអនុវត្តនៃការបូមឈាមអ្នកទោស។)

ទារុណកម្មបែប"ធមិត្រជាក់" បើប្រៀបធៀបទៅនឹងទម្រង់ទារុណកម្មបែបព្រៃផ្សៃ និងសប្បាយពេលឃើញអ្នកដទៃឈឺចាប់។[242]

## ២. ឌុច រៀបចំមន្ទីរស-២១ដើម្បីបញ្ចូលប្រព័ន្ធមួយដែលដាក់ទោសជាអតិបរិមានូវការឈឺចាប់ព្រៃផ្សៃដែលមិនចាំបាច់ៗ

៧៩. បុព្វសិទ្ធិនៃមុខតំណែង និងស្វយ័តភាពរបស់ឌុច បានអនុញ្ញាតឱ្យឌុចអាចធ្វើឱ្យល្អឥតខ្ចោះ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវមូលដ្ឋានការធ្វើទារុណកម្មប្រើប្រាស់នៅបណ្តាមន្ទីរសន្តិសុខផ្សេងៗ ដើម្បីបង្កើតជាប្រព័ន្ធស្មុគ្រស្មាញមួយ ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលចម្លើយសារភាពឱ្យកាន់តែច្រើនតាមដែលអាចធ្វើទៅបាន។ ខណៈពេលដែលឌុចបានអះអាងម្តងហើយម្តងទៀតថាខ្លួនគ្រាន់តែអនុវត្តទៅតាមបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ[243] ឌុចបែរជាគ្រាន់តែអាចធ្វើបទ បង្ហាញអំពីភស្តុតាងថាមិនមានបញ្ជា, ក្បួន ឬ ការបង្គាប់ណាមួយឱ្យច្បាស់លាស់នោះទេ និយាយពីកម្រិតនៃភាពព្រៃផ្សៃដែលត្រូវយកមកដាក់លើខ្លួនអ្នកទោស។[244] ជាការពិតណាស់ មន្ទីរសន្តិសុខទូទាំងប្រទេសដែលត្រូវបានដំណើការឡើង ភាគច្រើនគឺមានភាពឯករាជ្យរៀងៗខ្លួន ជាពិសេស គឺមិនមានបង្ហាញនូវប្រភេទដូចគ្នាណាមួយទៅនឹងកម្រិតនៃភាពព្រៃផ្សៃដូចនៅមន្ទីរស-២១នោះទេ។[245] ភស្តុតាងបានបង្ហាញថា ឌុច

---

[243] សូមមើល ឧទាហរណ៍ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៥។ និង ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤៨។

[244] ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩, ទំព័រ ៣។ (លោកបណ្ឌិតអេចផែស្ទិនៈ "ខ្ញុំមិនធ្លាប់ឃើញមានការបង្គាប់ ឬ បញ្ជាណា មួយឱ្យច្បាស់លាស់ ចេញពីគណៈអចិន្ត្រៃយ៍នោះទេដែលបង្គាប់ឱ្យធ្វើទារុណកម្ម....." )។ សូមមើលផងដែរ ឧទាហរណ៍ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៦។

[245] ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៩១។

[246] ប្រតិចារឹក ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៦៥។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៦៥។ (ដែល ឌុច សារភាពថាខ្លួនបានបង្កើតនូវវិធីសាស្ត្រនៃការធ្វើទារុណកម្មនៅមន្ទីរម-១៣ ហើយដែលខ្លួនយកនូវវិធីសាស្ត្រដដែលនេះមកអនុវត្តន៍នៅមន្ទីរ ស-២១។)

ប្រើប្រាស់នូវជំនាញដែលខ្លួនទទួលបានមកអនុវត្តន៍នៅមន្ទីរម-១៣[២៤៦] ជាកន្លែងដែលឌុចធ្វើជាប្រធាន ព្រមទាំងបានបង្កើតនូវវិធីសាស្ត្រនៃការធ្វើទារុណកម្ម ក្នុងគោលបំណងបង្កើននូវប្រសិទ្ធិភាព និងភាពព្រៃផ្សៃនៃប្រព័ន្ធនៅមន្ទីរស-២១។[២៤៧]

៨០. ថ្វីបើឌុចខិតខំប្រឹងប្រែងយ៉ាងសំបើម ក្នុងការកាត់បន្ថយភាពអាក្រក់នៃតួនាទីរបស់គាត់ នៅពេលអនុវត្តការធ្វើទារុណកម្មនៅមន្ទីរស-២១ក៏ដោយ ក៏ភស្តុតាងនៅតែបង្ហាញយ៉ាងជាក់ច្បាស់ថា ឌុច បានបោះជំហានចូលទៅក្នុងទំហំដ៏ធំក្រៃលែងនៃការបង្កើតប្រព័ន្ធមួយ ដែលបង្កើតឡើងដើម្បីបង្កការឈឺចាប់ក្នុងកម្រិតអតិបរិមាទៅលើអ្នកទោស។[២៤៨] ប្រាក់ ខន បានមើលឃើញដោយផ្ទាល់ពីរបៀបដែលមនុស្សមួយក្រុមមានគ្នាបួនដប់នាក់បានស្លាប់ ដោយសារតែឈាមរបស់អ្នកទាំងនោះត្រូវបានបូមយកច្រើនពេក[២៤៩] និងរៀបរាប់ពីរបៀបដែល ឌុច ផ្តល់ការណែនាំដល់ខ្លួនអំពីការធ្វើទារុណកម្មអ្នកទោស

---

[២៤៧] ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ៥។

[២៤៨] ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ១៧។ (ដូចដែល ប្រាក់ ខន ដែលជាអតីតអ្នកយាមម្នាក់នៅមន្ទីរ ស-២១ បានផ្តល់សក្ខីកម្មថា បុគ្គលិកត្រូវបានបង្ហាត់ឱ្យ "វាយអ្នកទោសនឹងរំពាត់..... ឆក់ខ្សែភ្លើង.... ហើយប្រើថង់ប្លាស្ទិកដើម្បីឱ្យអ្នកទោសថប់ដង្ហើម"។)

[២៤៩] ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៦។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣៧។ (សួស ធី បាននិយាយថាខ្លួន "ទទួលស្គាល់ការពិតដែលថាមានការបូមឈាម។ ហ៊ិ ណែនាំឱ្យកត់ឈ្មោះអ្នកទោសដែលត្រូវបានបូមឈាមចូលទៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលនឹងត្រូវយកទៅកម្ទេច។ អង្គភាពពេទ្យនឹងស្នើយកឈាមពី ហ៊ិ ហើយ ហ៊ិ នឹងស្នើសំណើរនោះទៅ ឌុច ដើម្បីសុំការអនុញ្ញាតមុនពេលដែលអ្នកទោសត្រូវបានយកទៅបូមឈាម។")

[២៥០] ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៦៧។ ("ពួកយើងត្រូវបានបង្រៀនឱ្យសូកម្ជុលចូលក្នុងក្រចក ហើយដោយធ្វើបែបនេះ គឺអ្នកទោសអាចទ្រាំនឹងមុខរបួសនៅក្រចកបាន ដោយមិនមានប៉ះពាល់ដល់ដៃ រឺជើងដែលធ្វើឱ្យអ្នកទោសដើរទៅធ្វើការមិនរួចនោះទេ។ ដូច្នេះ នេះគឺជាប្រភេទនៃការធ្វើទារុណកម្មមួយដែលស្រាលតែឈឺចាប់(...) នេះគឺជាទ្រឹស្តីដែលត្រូវបានចង្អុលបង្ហាញដោយ ឌុច ផ្ទាល់ ពីព្រោះថានេះគឺជាវិធីសាស្ត្រនៃការធ្វើទារុណកម្មធុនស្រាលដែលមិនប៉ះពាល់ដល់បេះដូងរបស់អ្នកទោសឡើយ"។)

ដោយប្រើម្ជុលចាក់ក្រោមដៃអ្នកទោសទាំងនោះ។[២៥០] ផ្ទុយពីពាក្យសំដីរបស់ឌុច ប្រាក់ ខន បានអះអាងថា ខ្លួនត្រូវបានឌុចណែនាំឱ្យបង្ខំអ្នកទោសទទួលទានលាមករបស់ពួកគេ[២៥១] ហើយពន្យល់បន្ថែមទៀតថា អ្នកទោសត្រូវបានវាយដំយ៉ាងធ្ងន់ធ្ងររហូតទាល់តែត្រូវការជំនួយពីពេទ្យ ឬក៏ដួលសន្លប់បាត់បង់ស្មារតីតែម្តង។[២៥២]

៨១. អ្នករួចរស់ជីវិតមួយចំនួនតូចពីមន្ទីរស-២១ បានធ្វើការបញ្ជាក់ស្រដៀងៗគ្នាទាក់ទងទៅនឹងកម្រិតនៃការទទួលរងការឈឺចាប់ដ៏អាក្រក់បំផុតដែលបង្កឡើងលើខ្លួនអ្នកទោស។ អ្នករួចរស់មានជីវិតពីមន្ទីរ ស-២១ វ៉ាន់ ណាត បានពិពណ៌នាពីរបៀបដែលគាត់ត្រូវបាននាំចូលទៅបន្ទប់សួរចម្លើយ ដែលមាន

---

[២៥១] ប្រតិចារឹត ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៦៩-៧១។

[២៥២] ប្រតិចារឹត ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៦៩-៧១។ នេះក៏ត្រូវបានបញ្ជាក់បន្ថែមដោយអ្នកយាមមន្ទីរ ស-២១ ម្នាក់ទៀតផងដែរ។ សូមមើល ប្រតិចារឹត ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ២២។ (សួស ធី បញ្ជាក់ថាអ្នកទោស នៅមន្ទីរ ស-២១ ត្រូវបានធ្វើទារុណកម្មរហូតដល់ស្លាប់ និងបង្អត់អាហាររហូតដល់ស្លាប់)។ ប្រតិចារឹត ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩, ទំព័រ៩-១៩។ (សេក ដន បាននិយាយថា "អ្នកទោសភាគច្រើនរាត រីកគ្រុន រីកឈឺក្បាល ហើយអ្នកទោសទាំងអស់នោះភាគច្រើនមានរបួសនៅខ្នង។ អ្នកទោសខ្លះទៀតបាត់ក្រចកដៃក្រចកជើង (...) អ្នកទោសភាគច្រើនទៀត គឺត្រូវបានធ្វើទារុណកម្ម។ ពួកគេទាំងនោះមិនមានជម្ងឺអីដូចគ្នានោះទេ។ ពួកគេឈឺដោយសារតែពួកគេត្រូវបានធ្វើទារុណកម្ម ...")។ ប្រតិចារឹត ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ ទំព័រ៩៦។ (ឡាច មាន បានបន្ថែមអំពីការធ្វើទារុណកម្ម ដោយប្រើចរន្តអគ្គិសនីថា: "ទាក់ទងនឹងការឆក់ដោយប្រើចរន្តអគ្គិសនី គឺប្រើឌីណាម៉ូកង់មកបង្កើតជាចរន្តអគ្គិសនីមកឆក់អ្នកទោស។") សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣០, ៧៣។

[២៥៣] ប្រតិចារឹត ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៨។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១១-១៤។

"ចង់ប្លាស្ទិកនៅព្យួរជាប់នឹងជញ្ជាំង, មានខ្មៅ, មានដែកឡោស៊ី, មានព្រនង់ ហើយនឹងកៅអីដែលខ្ញុំអង្គុយលើ និងមានប្រឡាក់ឈាម។ ស្នាមឈាមមានគ្រប់កន្លែង"។[២៥៣] វ៉ាន់ ណាត បន្តពន្យល់សេចក្តីលម្អិតគួរឱ្យរន្ធត់អំពីរបៀបនៃការធ្វើទារុណកម្មដែលចរន្តអគ្គិសនីត្រូវបានប្រើប្រាស់មកលើខ្លួនគាត់។[២៥៤] តាមរយៈសេចក្តីសន្និដ្ឋាន និងសក្ខីកម្មដោយផ្ទាល់ អ្នករួចរស់មានជីវិតពីមន្ទីរស-២១ផ្សេងទៀតបានពិពណ៌នាពីរបៀបដែលអ្នកយាមប្រើប្រាស់សត្វពិស[២៥៥] មកលើខ្លួនពួកគេ, របៀបដែលអ្នកទោសត្រូវជ្រមុជចូលទៅក្នុងធុងមួយដែលមានទឹក[២៥៦] និងពីរបៀបដកក្រចកដៃ។[២៥៧] ការឈឺចាប់នោះពិតជាពិបាកទ្រាំណាស់រហូតទាល់តែធ្វើឱ្យអ្នកទោសជ្រើសយកការសម្លាប់ខ្លួនឯង។[២៥៨] សក្សីជំនាញទាំងបណ្ឌិត ឆែនដ្លឺរ[២៥៩] និងលោកបណ្ឌិតអេចឆែស្សិន បានបញ្ជាក់ថា ការធ្វើទារុណកម្មនៅមន្ទីរស-២១គឺត្រូវបានកំណត់លក្ខណៈឡើងដោយភាពឃោរឃៅ និងភាពខុសៗគ្នានៃការធ្វើទារុណកម្ម។[២៦០]

---

[២៥៤] ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៨។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១១-១៤។

[២៥៥] ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤៥។

[២៥៦] ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤៣-៤៤។

[២៥៧] ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤៥-៤៦។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៥។

[២៥៨] ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១០១-១០២។

[២៥៩] សូមមើល *សម្លេងពីមន្ទីរ ស-២១* ទំព័រ ១៣០ ចំពោះ បញ្ជីប្រភេទនៃការធ្វើទារុណកម្ម។

[២៦០] ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ៦-៧។

[២៦១] ប្រតិចារឹក ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣៥។ (ចាន់ ឡាយៈ "នៅពេលដែលខ្ញុំស្រេកទឹក ខ្ញុំអត់ហានទៅសុំទេ ឬក៏ពេលដែលខ្ញុំត្រូវការបត់ជើង ខ្ញុំត្រូវទុកទឹកនោមនោះដើម្បីផឹកវិញ")។

៨២. អ្នករួចរស់មានជីវិតពីមន្ទីរ ស-២១ បានពិពណ៌នាពីស្ថានភាពអមនុស្សធម៌នៅក្នុងគុកនោះ រួមមាន : (i) កង្វះទឹក[២៦១] និងអាហារ[២៦២] (ii) កង្វះអនាម័យ[២៦៣] (iii) ត្រូវពាក់ច្រវ៉ាក់[២៦៤] (iv) ត្រូវគេងលើកម្រាលកខ្វក់[២៦៥] (v) ត្រូវបត់ជើងតូច និងជើងធំដោយប្រើកំប៉ុងជ័រនៅខាងក្នុងគុក[២៦៦] (vi) ការពិតដែលថាវាពិបាកទឹងក្រោកអង្គុយនៅក្នុងគុក[២៦៧] ឬក៏ (vii) សឹងតែមិនអាចកម្រើកបានផង បើមិនដូច្នោះត្រូវអ្នកយាមវាយ[២៦៨] (viii) កង្វះការព្យាបាល[២៦៩] (ix) កង្វះពន្លឺចេញចូលនៅក្នុងគុក[២៧០] (x) សម្រេកព្ទចេញពីអាគារជាប្រចាំ[២៧១] (xi) និងទិដ្ឋភាពដ៏គួរឱ្យរន្ធត់នៃសាកសពនៅក្នុងគុក ។[២៧២]

---

២៦២ ប្រតិចារឹត ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២០-២៣។ (វ៉ាន់ ណាត: "ខ្ញុំអត់មានគិតអ្វីផ្សេងក្រៅពីស្រេកទឹក និងឃ្លាននោះទេ។ ខ្ញុំមិនដែលធ្លាប់ឃ្លានដល់ថ្នាក់ហ្នឹងទេ រហូតទាល់តែខ្ញុំគិតថាស៊ីសាច់មនុស្សគឺជាអាហារមួយដ៏ឆ្ងាញ់សម្រាប់ខ្ញុំនៅពេលហ្នឹង ។") សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៤។ (ដែល ឌុច យល់ស្របថាអ្នកទោសត្រូវបានបង្ខំឱ្យចាប់សត្វល្អិតដើម្បីបំពេញភាពស្រេកឃ្លានរបស់ពួកគេ។) សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៤។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣៥។ (ឡាយ ចាន់: "មុនពេលដែលខ្ញុំត្រូវយកមកឃុំឃាំងនៅកន្លែងនេះ ទម្ងន់របស់ខ្ញុំគឺប្រហែល ៤២-៤៥ គីឡូ។ ហើយបន្ទាប់ពីឃុំឃាំងអស់បីខែក្រោយមក ខ្ញុំមិនបានថ្លឹងទម្ងន់ខ្ញុំនោះទេ ហើយវាពិបាកនឹងប៉ាន់ស្មានណាស់ ប្រហែលជា៣៥គីឡូ រឺតិចជាងហ្នឹង ។")

២៦៣ សូមមើល ឧទាហរណ៍ ប្រតិចារឹត ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ២៥-៧៦ ។

២៦៤ សូមមើល ឧទាហរណ៍ ប្រតិចារឹត ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៧៩។ ប្រតិចារឹត ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៧២ ។ ប្រតិចារឹត ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៨៤។

២៦៥ ប្រតិចារឹត ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ១២-១៣ ។

២៦៦ សូមមើល ឧទាហរណ៍ ប្រតិចារឹត ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ២២-២៣ ។

២៦៧ ប្រតិចារឹត ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤១ ។

២៦៨ ប្រតិចារឹត ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៧៩ ។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ២២-២៣ ។

២៦៩ សូមមើល ប្រតិចារឹត ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២៦-២។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣១-៣២ ។

២៧០ សូមមើល ប្រតិចារឹត ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៧២។

២៧១ ប្រតិចារឹត ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៣៣-៣៤ ។

២៧២ ប្រតិចារឹត ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៤៧ ។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២០-២៣ ។

២៧៣ ប្រតិចារឹត ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៤, ៥៧ ។

៨៣. ក្នុងឋានៈជាប្រធានមន្ទីរស-២១ ឌុច អាចស្ថិតនៅលើលក្ខខណ្ឌមួយដែលអាចសម្រាល បើទោះបីជាតិចតួចក្តី ការឈឺចាប់ដ៏ហួសប្រមាណមកលើអ្នកទោសទាំងអស់ ដោយស្ថានភាពនៃការឃុំឃាំងដ៏គួរឱ្យស្អប់ខ្ពើម ប៉ុន្តែ ជាក់ស្តែង ឌុចមិនជ្រើសរើសធ្វើបែបនោះទេ។ ផ្ទុយមកវិញ ឌុចតែងតែស្វះស្វែងបន្តនូវអ្វីដែលជាប្រយោជន៍ខ្លួនបន្ថែមទៀត។ ឧទាហរណ៍ ឌុច បានផ្តល់សក្ខីកម្មថា របបអាហារសម្រាប់អ្នកទោសម្នាក់ៗនៅមន្ទីរស-២១ គឺត្រូវបានកំណត់ឡើងមុនពេលដែល ឌុច ទៅធ្វើការនៅមន្ទីរនោះម្ល៉េះ ដែលនេះបង្កប់ន័យថា ឌុចមិនអាចធ្វើអ្វីបានទេដើម្បីដោះស្រាយបញ្ហានេះ។[២៧៣] នៅពេលឌុច បន្ទាប់ពីត្រូវបានដំឡើងឋានៈជាប្រធានមន្ទីរស-២១រួចហើយ បានដឹងថា មានអង្ករគ្រប់គ្រាន់សម្រាប់ចិញ្ចឹមអ្នកទោសទាំងអស់ដែលកំពុងតែស្លាប់ដោយសារអត់អាហារ និង កំពុងតែព្យាយាមរស់ដោយហូបសត្វល្អិតជាចំណីអាហារក៏ដោយ[២៧៤] ឌុចបែរជាសម្រេចបញ្ជូនអង្ករទាំងនោះទៅឱ្យគណៈអធិន្ត្រ្តីយ៍វិញ[២៧៥] ដែលនេះគឺផ្ទុយទៅនឹងការកាត់បន្ថយភាពស្រែកឃ្លានដ៏ធ្ងន់ធ្ងរនៅក្នុងមន្ទីរឃុំឃាំងរបស់គាត់។

៨៤. លោកបណ្ឌិត ឆែនដ្លឺរ បានផ្តល់សក្ខីកម្មថាអ្នកទោសទាំងអស់"ត្រូវបានធ្វើបាបទាំងផ្នែករាងកាយ, ស្មារតី និងផ្លូវចិត្ត តាំងពីពេលអ្នកទោសទាំងនោះមកដល់កន្លែងឃុំឃាំងតំបូងម្ល៉េះ"។[២៧៦] ស្ថានភាពក្នុងគុកគឺត្រូវបានរៀបចំឡើងយ៉ាងច្បាស់លាស់ ដើម្បីបំបាក់ភាពរឹងទទឹងរបស់អ្នកទោសសឹងតែមុនពេលពួកគេត្រូវបានយកទៅសួរចម្លើយទៅទៀត និង ដើម្បីបង្កើតជាលក្ខខណ្ឌមួយឱ្យមានការ"ចុះញ៉មទាំងស្រុង"។[២៧៧] ប្រព័ន្ធបំបាក់អ្នកទោសដូចគ្នាដែរតាមរយៈស្ថានភាពព្រៃផ្សៃនៃការឃុំឃាំងគឺនៅមន្ទីរ

---

[២៧៤] ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៤។

[២៧៥] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៨-២០។

[២៧៦] ប្រតិចារឹក ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៤២។

[២៧៧] សម្លេងពីមន្ទីរ ស-២១ ទំព័រ ៣៨។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៨៨។ (នៅក្នុងសវិការ ឆែនដ្លឺរ បានយល់ស្របថា កង្វះអនាម័យ ការដាក់ខ្នោះ និងការវាយដំនៅក្នុងគុក គឺត្រូវបានរៀបចំឡើងដើម្បីបំបាក់ភាពរឹងទទឹងរបស់អ្នកទោស និងដើម្បីឱ្យពួកគេចុះញ៉ម។)

[២៧៨] ប្រតិចារឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ ទំព័រ ២២។

ម-១៣ ក្រោមការដឹកនាំរបស់ឌុច។[២៧៨] ឌុចមិនត្រឹមតែបានបង្កើតនូវប្រព័ន្ធនៃភាពឃោរឃៅដាច់ខាតនេះទេ ថែមទាំងចូលរួមដោយផ្ទាល់ក្នុងការដាក់ទោសយ៉ាងព្រៃផ្សៃមកលើអ្នកទោស។ ប៊ូ ម៉េង បានប្រាប់នៅក្នុងសវនាការអំពីរឿងគួរឱ្យតក់ស្លុតមួយ ដែលឌុចឱ្យអ្នកទោសវាយគ្នាទៅវិញទៅមក។[២៧៩] ការអនុវត្តធ្វើទារុណកម្មដោយផ្ទាល់[២៨០] នៅមន្ទីរស-២១ដោយឌុចនេះ គឺជាការអនុវត្តបន្តបន្ទាប់ដែលឌុចអនុវត្តតាមនៅមន្ទីរម-១៣ផងដែរ។[២៨១] ភាពគ្មានមេត្តា និងគ្មានប្រណីទាំងស្រុងរបស់ឌុច នៅមន្ទីរស-២១ ក៏ត្រូវបានកត់ត្រាជាឯកសារនៅក្នុងសេចក្តីលំអិតដ៏រន្ធត់នៃ"របាយការណ៍កោសល្យវិច័យចិត្តសាស្ត្រ" ដែលនៅក្រោមជំពូក "ឧទាហរណ៍នៃកង្វះការយល់ចិត្តអ្នកដទៃរបស់ឌុច"។[២៨២]

### ៣. ឌុចលើកទឹកចិត្តបុគ្គលិកនៅមន្ទីរស-២១ឱ្យសាហាវឃោរឃៅតាមដែលអាចធ្វើទៅបាន

[២៧៩] ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣៧-៣៨។ សូមមើលផងដែរ របាយការណ៍ចិត្តសាស្ត្រ ទំព័រ ៥៤។

[២៨០] សូមមើល ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ទំព័រ ១២០។ ("ខ្ញុំឃើញគាត់ធ្វើអ៊ីចឹងនៅក្នុងឆ្នាំ៧៧ នៅពេលដែលអ្នកទោសត្រូវបាននាំចូលមក ដោយសារតែខ្ញុំដឹងថា គាត់ត្រូវការចម្លើយសារភាពដើម្បីបញ្ជូនទៅអង្គការ (...)ខ្ញុំឃើញតែម្តងទេ នៅពេលនោះខ្ញុំនៅក្បែរម៉ូតូ។ ខ្ញុំកំពុងតែជិះកង់ ហើយឃើញគាត់វាយអ្នកទោសម្នាក់នៅខាងមុខទួលស្លែង។ កន្លែងដែលខ្ញុំធ្វើការក៏នៅកន្លែងដូចគ្នាហ្នឹងដែរ ដូច្នេះខ្ញុំក៏មើលឃើញ (...) គាត់ធ្វើទារុណកម្មអ្នកទោសដោយវាយទីងរំពាត់ផ្តៅ។ ខ្ញុំជិះកាត់ហើយក៏មើលឃើញទៅ។")

[២៨១] ប្រតិចារឹក ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ ១២។

[២៨២] របាយការណ៍ចិត្តសាស្ត្រ ទំព័រ ៤៩-៥២។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៨៩-៩០ (សម្រាប់សក្ខីកម្មរបស់លោកបណ្ឌិត ដេវីដ ឆេនដ្លឺរ ស្តីពីបញ្ហានេះ)។

[២៨៣] ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១០៦។

៨៥. អ្នកយាមទាំងអស់គឺបង្ហាញនូវភាពទោទន់ទៅរកភាពកាចសាហាវ និងសប្បាយរីករាយពេលឃើញគេឈឺចាប់ ហើយជាញឹកញាប់តែងតែសប្បាយនឹងសមត្ថភាពរបស់ពួកគេក្នុងការធ្វើទារុណកម្ម។ ជាឧទាហរណ៍ក្នុងករណី ធុយ[២៨៣] ដែលយោងទៅតាម ឌុច "គឺមានចេតនា និងទិន្នាការទោទន់ទៅរកការធ្វើទារុណកម្មបែបធមិក្តៅ"។[២៨៤] អ្នកយាមម្នាក់ទៀតឈ្មោះ ប្រាក់ ណន ដែលស្រដៀងគ្នាផងដែរមាន "ទិន្នាការទៅរកការធ្វើទារុណកម្មធមិក្តៅ ហើយភាគច្រើនប្រើប្រាស់តែទារុណកម្មធមិក្តៅប៉ុណ្ណោះ"។[២៨៥] ឌុច បានដឹងយ៉ាងច្បាស់ពីសារជាតិដ៏ឃោរឃៅរបស់អ្នកយាមទាំងនោះ ប៉ុន្តែមិនបានដាក់ពិន័យ ឬដកអ្នកយាមទាំងនោះចេញពីមុខតំណែងរបស់ពួកគេនោះទេ។[២៨៦] ប្រាក់ ខន បានផ្តល់សក្ខីកម្មថា ឌុចមានវត្តមាននៅទីងកន្លែងនៅពេលដែលអ្នកសួរចម្លើយ៥នាក់វាយធ្វើបាបអ្នកទោសនារីម្នាក់រហូតដល់សន្លប់បាត់បង់ស្មារតី។[២៨៧]

៨៦. ម្យ៉ាងវិញទៀត នៅពេលឌុចបានដឹងថាអ្នកទោសត្រូវបានយកទៅឆក់ប្រដាប់ភេទ ឌុចនៅតែមិនចាត់វិធានការណ៍អ្វីទាំងអស់។ [ការមិនចាត់វិធានការណ៍] នេះមិនមែនដោយសារតែឌុចមានអារម្មណ៍អាណិតអាសូរចំពោះអ្នកទោស ឬស្អប់ទង្វើនោះទេ ប៉ុន្តែគឺចេញពីការបារម្ភចំពោះការមិនអាចរកនរណាផ្សេងទៀតមកបន្តការសួរចម្លើយ។[២៨៨] នៅពេលអ្នកយាមម្នាក់ត្រូវបានរកឃើញថាបានរំលោភអ្នកទោស

---

[២៨៤] ប្រតិចារឹត ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៦។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ទំព័រ ១៥។

[២៨៥] ប្រតិចារឹត ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៦។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ទំព័រ ១៥។

[២៨៦] ប្រតិចារឹត ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ២១។

[២៨៧] សូមមើល ឧទាហរណ៍ ប្រតិចារឹត ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ២៣-២៤។ ប្រតិចារឹត ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៨២-៨៣ សម្រាប់ការបញ្ជាក់បន្ថែម: ប្រតិចារឹត ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៦៥, ៧៥-៧៦។

[២៨៨] ប្រតិចារឹត ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១១០។

[២៨៩] ប្រតិចារឹត ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៤២។

ស្រីម្នាក់ អ្នកយាមនោះមិនត្រូវបានពិន័យឬព្យួរការងារអ្វីនោះទេ តែគ្រាន់តែ"មិនអាចអនុញ្ញាតឱ្យសួរចម្លើយអ្នកទោសស្រីទៀតប៉ុណ្ណោះ"។[២៧៩] ជាការពិតណាស់ នៅពេលឌុចត្រូវបានអង្គជំនុំជម្រះជម្រុញឱ្យពន្យល់ពីមូលហេតុដែលមិនមានអ្នកយាមណាម្នាក់នៅមន្ទីរស-២១ ត្រូវបានដកចេញពីមុខតំណែង ឬពិន័យចំពោះការបង្កការឈឺចាប់ដែលមិនចាំបាច់មកលើខ្លួនអ្នកទោស ឌុចបានឆ្លើយយ៉ាងច្បាស់ថា ការធ្វើទារុណកម្មហួសហេតុ មិនមែនជា"ទោសកំហុស ឬគុណវិបត្តិដើម្បីដកចេញពីតំណែង"ទេ លើកលែងតែករណីដែលអ្នកទោសស្លាប់ដោយសារមុខរបួសនៅមុនពេលផ្តល់ចម្លើយសារភាពប៉ុណ្ណោះ។[២៨០]

៨៧. ដូច្នេះ ដូចអ្វីដែលឌុចទទួលស្គាល់ គឺថាគាត់បានលើកទឹកចិត្តឱ្យអ្នកយាមបន្តការប្រព្រឹត្តអំពើឃោរឃៅ [ទៅកាន់អ្នកទោស] ដោយអនុញ្ញាតឱ្យពួកអ្នកយាមទាំងនោះអនុវត្តន៍ដោយគ្មានទោស។[២៨១] ដូចលោកបណ្ឌិត ឌឿរីដ ឆែនដ្លឺរ ដែលបានកត់សម្គាល់ថា "បុគ្គលិកស-២១ ដូចគ្នានឹងមនុស្សមួយចំនួនត្រូវបានសិក្សានៅក្នុងរបបហ្វូឡូខូស (...) នៅពេលទង្វើរបស់ពួកគេក្លាយទៅជាទម្លាប់ នៅពេលពួកគេមិនត្រូវបានពិន័យ ហើយនៅពេលនោះហើយដែលពួកគេប្រព្រឹត្តកាន់តែខ្លាំងទៅៗ យើងឃើញមានហេតុការណ៍ដូចគ្នានេះផងដែរនៅក្នុងបដិវត្តន៍វប្បធម៌ក្នុងចំណោមពួកឆ្មាំក្រហម។ ពួកគេមិនបញ្ឈប់ទង្វើទាំងនោះទេ ផ្ទុយទៅវិញពួកគេនឹងអនុវត្តន៍អំពើនោះជាទូទៅយ៉ាងសស្រាក់សស្រាំទៀត"។[២៨២]

### ៤. ឌុចចាត់ទុកអ្នកទោសដូចសត្វធាតុ

៨៨. ឌុច ប្រព្រឹត្តអាក្បកិរិយាមកលើអ្នកទោសដោយ "គ្មានត្រាប្រណី"[២៨៣] នេះដោយសារតែឌុចចាត់ទុកអ្នកទោសដែលឆ្លងកាត់ទ្វារមន្ទីរស-២១ ជាសត្វដែលត្រូវតែយកមកសម្លាប់។ លោកបណ្ឌិត ឌឿរីដ ឆែនដ្លឺរ បានពន្យល់ថា "មនុស្សទាំងនេះនៅពេលដែលចូលដល់ក្នុងឡាន គឺត្រូវចាត់ទុកថាជា

---

[២៨០] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១៧-១៨។

[២៨១] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៩ ទំព័រ១៧ (ឌុច : "លោក មេធាវី, លោកនិយាយថាខ្ញុំជំរុញឱ្យពួកគេប្រព្រឹត្តអំពើរង់សាហាវឃោរឃៅទាំងនោះ]។ ខ្ញុំមិនដែលធ្វើដូច្នេះ។ ប៉ុន្តែ វាជាការពិតដែលខ្ញុំទុកចិត្តវា ហើយផ្តល់ការណែនាំ និងដំបូន្មានទៅវាតិចឬច្រើន ដើម្បីឱ្យវាដឹង របៀបនៃការធ្វើទារុណកម្មនិងបន្តការធ្វើទារុណកម្ម")។

[២៨២] ប្រតិចារឹក ថ្ងៃទី៦ ខែសីហា ឆ្នាំ ២០០៩ ទំព័រ៧៥។

[២៨៣] ប្រតិចារឹក ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ៨៩-៩០។

សម្រាម។ ពួកគេមិនមែនជាមនុស្សទេ"។[២៩៤] ជាក់ស្តែង សូម្បីតែអ្នកយាមគុកក៏ត្រូវបានណែនាំអោយប្រព្រឹត្តទៅលើអ្នកទោស ដូចជាសត្វធាតុដែរ។ ប្រាក់ ខន បានបញ្ជាក់ថា "នៅមន្ទីរស-២១ មានតែឌុច ម្នាក់គត់ដែលអប់រំស្មារតីរបស់យើង ឱ្យប្រឆាំងនឹងពួកខ្មាំង ហើយពួកយើងត្រូវតែដាច់ខាត់អំពីរឿងនេះ ហើយយើងត្រូវចាត់ទុកអ្នកទោសជាសត្វធាតុ"។[២៩៥] ឌុចបានបញ្ជាក់យ៉ាងច្បាស់ទៅកាន់អង្គជំនុំជម្រះ នៅពេលដែលគាត់ពណ៌នាមន្ទីស-២១ថា មិនត្រឹមតែជាគុកទេ តែលើសពីនោះទៀត ".....ជាកន្លែងទុកមនុស្សសម្រាប់យកទៅសម្លាប់"។[២៩៦] "ពួកគេគ្រាន់តែជាប្រជាជនបញ្ញើសម្រាប់សម្លាប់ប៉ុណ្ណោះ យើងក៏អាចនិយាយបានថាវាជាកន្លែងសម្លាប់មនុស្សដែរ"។[២៩៧]

៨៩. សូម្បីតែអ្នកទោសដែលរស់រានមានជីវិតពីមន្ទីរស-២១ផ្ទាល់ ក៏បញ្ជាក់អំពីការពិតដែលថា អ្នកទោសមិនត្រូវបានគេចាត់ទុកជាមនុស្សទេ នៅពេលនាំចូលមន្ទីរស-២១។ ដូចដែលលោក វ៉ាន់ ណាត និយាយទាំងរន្ធត់ថាៈ "ខ្ញុំបាត់បង់សេចក្តីថ្លៃថ្នូរអស់ហើយ ដោយសារតែស្ថានភាពរវាងអ្នកទោស និង អ្នកយាមខុសគ្នាឆ្ងាយពេក។ វាហាក់ដូចជាមនុស្សត្រូវបានគេប្រៀបទៅនឹងសត្វធាតុទៅហើយ។ បើទោះបីជាសត្វក៏ គេឱ្យចំនីអាហារគ្រប់គ្រាន់ដែរ (....) ចំណែកយើងហូបអាហារនៅក្បែរសាកសព ហើយយើងមិនខ្វល់ទេ ពីព្រោះថាពួកយើងដូចជាសត្វធាតុអញ្ចឹង ហើយគេធ្វើបែបនេះទៅគ្រប់ៗគ្នាតែម្តង"។[២៩៨]

---

[២៩៤] ប្រតិចារឹត ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ៨៩-៩០។ សូមមើលផងដែរ ប្រតិចារឹក ៦ សីហា ២០០៩ នៅទំព័រ៩២ ("នៅខណៈពេលដែលមកដល់ [ស-២១] ពួកគេត្រូវបានគេចាត់ទុកថាបានចាកចេញពីពិភពមនុស្សដែលមិនបានប្រព្រឹត្តខុសអ្វីទាល់តែសោះ")។ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ទំព័រ៩០ (ឌុចៈ "ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងទៅលើមនុស្សដែលគេស្គាល់ថាជាមនុស្សស្លាប់រួចទៅហើយ")។

[២៩៥] ប្រតិចារឹត ថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០០៩ ទំព័រ២៤-២៥។

[២៩៦] ប្រតិចារឹត ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ១៩។

[២៩៧] ប្រតិចារឹត ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៨៦។ សូមមើល ប្រតិចារឹត ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ១១-១២ (សំដៅទៅ"សម្លេងពីមន្ទីរស-២១") ទំព័រទី៤០ (លោកបណ្ឌិត ដេវីដ ឆេនដ្លឺរ សំដៅទៅមន្ទីរស-២១ ជា "បន្ទប់ទៅកាន់សេចក្តីស្លាប់")។

[២៩៨] ប្រតិចារឹត ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ២០-២៣។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ២២-២៣, ៣៧-៣៨, ៤៨, ៦២, ៧៦ (ត្រង់ចំណុច ដែល លោក ប៊ូ ម៉េង បកស្រាយដូចគ្នាដែរ ថា

E159/7

៩០. នៅក្នុងតុលាការ ឌុចអះអាងថាគាត់ជាមនុស្សកំសាក ហើយភាពកំសាកនោះបានរារាំងមិនឱ្យគាត់ដើរត្រួតពិនិត្យអ្នកទោសនៅក្នុងបន្ទប់របស់ពួកគេ ដែលកំពុងតែរងទុក្ខវេទនា ដោយសារជម្ងឺ ទារុណកម្ម និងការទទួលទានអាហារមិនគ្រាប់គ្រាន់ នៅក្រោមការគ្រប់គ្រងរបស់គាត់ទេ។[២៩៩] ការដោះសារនេះមិនអាចលាក់ការពិតបានទេ។ ឌុចមិនបានទៅពិនិត្យមើលអ្នកទោស ដោយសារថាគាត់មិនបានចាត់ទុកអ្នកទោសទាំងនោះជាមនុស្សទេ[៣០០] ពួកគេគឺជាសត្វធាតុដែលនឹងត្រូវសម្លាប់ឬក៏ប្រើជាជីសម្រាប់ដាក់ស្រែ។[៣០១]

## ឃ. ឌុច បានបន្ថែមទៅលើភាពជ្រុលនិយមរបស់ថ្នាក់លើដោយបង្កើតឱ្យមានចម្លើយសារភាពដ៏មានប្រសិទ្ធិភាពដើម្បីបង្កើតម៉ាស៊ីនសួរចម្លើយ

៩១. បើទោះបីជាស-២១ជាកន្លែងដែលការធ្វើទារុណកម្មសាហាវព្រៃផ្សៃនិងការសម្លាប់កើតឡើងក៏ដោយ វាគឺជាកន្លែងដែលបង្កើតឡើងជាពិសេសដើម្បីសួរចម្លើយ។[៣០២] នេះគឺជា"ហេតុផលនៃការបង្កើត"ស-២១ ពោលគឺដើម្បីបំពេញកិច្ចការ"ប្រឆាំងនឹងចារកិច្ច"។[៣០៣] ផ្អែកលើភស្តុតាងនៅក្នុងពេលសវនាការ វាច្បាស់ណាស់ថា ចម្លើយសារភាពជាច្រើនដែលទទួលបានគឺមានតែនៅស-២១

---

គាត់មានអារម្មណ៍ដូចជា សត្វធាតុអ៊ីចឹងដែរ។ គាត់បានឃើញមនុស្សធ្លាក់ខ្លួនឈឺ ហើយដៃជើងត្រូវបានគេចងនិងលើសែង ដូចជាសត្វជ្រូកអ៊ីចឹង)។

[២៩៩] ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៩១។

[៣០០] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ២៣។ រាល់ពេលដែលឌុចផ្តល់សក្ខីកម្មទាក់ទងទៅនឹងការពិតដែលថាគាត់ មិនដែលទៅមើលបន្ទប់របស់អ្នកទោសទេ ក្រៅពីបន្ទប់មិត្តភក្តិនិងលោកគ្រូរបស់គាត់។ បើទោះបីជា៣០ឆ្នាំក្រោយមក ពួកគេទាំងនោះមិនសំខាន់ក៏ដោយ។

[៣០១] ប្រតិចារឹត ថ្ងៃទី០១ ខែកក្កដា ឆ្នាណំ២០០៩ ទំព័រ៤៤។ សូមមើល ទំព័រ៦៤ ("គាត់និយាយថា បើសិនជាគាត់មិនអាចគូរគំនូរឱ្យដូចនឹងរូប ប៉ុល ពត ទេ ខ្ញុំនឹងក្លាយទៅជាជីមនុស្សហើយ។ ហើយ ខ្ញុំមិនយល់ច្បាស់ទេថាតើខ្ញុំនឹងត្រូវគេប្រើឱ្យទៅធ្វើជីឬក៏ខ្ញុំនឹងត្រូវគេយកទៅធ្វើជីដាក់ស្រែ")។

[៣០២] ប្រតិចារឹត ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ៥៦ (លោកបណ្ឌិត ដេវីដ ឆេនឌ្លឺរ អ្វីដែលកើតមានឡើងនៅស-២១នោះគឺការសួរចម្លើយ)។ ការសួរចម្លើយគឺជាកិច្ចការដ៏សំខាន់មួយនៅកន្លែងនោះ។

[៣០៣] ប្រតិចារឹត ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ទំព័រ៣១។

ប៉ុណ្ណោះ។[៣០៤] គ្មានភស្តុតាងនៅក្នុងបញ្ជីឯកសារ ដែលបញ្ជាក់ថាចម្លើយសារភាពទាំងនោះមកពីកន្លែងផ្សេងឡើយ។ គ្មានចម្លើយសារភាពច្រើនបែបនោះ ធ្វើឡើងនៅមន្ទីរសន្តិសុខដទៃទេ។ ទោះជាយ៉ាងណា ឌុច ខ្លួនឯងផ្ទាល់បាននិយាយថា គាត់បានជួបប្រទះរឿងបែបនេះតែម្តងគត់។[៣០៥] តែតាមពិត ឌុច ហាក់ដូចជាមានមោទនភាពចំពោះការដែលថា ប្រព័ន្ធគាត់បង្កើតឡើងដើម្បីយកចម្លើយសារភាព និង ស្វែងរក "ខ្មាំង" គឺជាលក្ខណៈពិសេសរបស់ស-២១។[៣០៦]

## ១. គោលបំណងនៃការសួរចម្លើយ

៩២. ឌុច ក្នុងនាមជាប្រធានមន្ទីរស-២១ បានរៀបចំ និង អនុវត្តម៉ាស៊ីនសួរចម្លើយមានប្រសិទ្ធិភាពយ៉ាងព្រៃផ្សៃ[៣០៧] ដែលមានគោលបំណងតែមួយគត់ក្នុងការយកចម្លើយសារភាពបញ្ជាក់ថាការចាប់ខ្លួនគឺត្រឹមត្រូវ[៣០៨] ព្រមទាំងរកឱ្យឃើញខ្សែបណ្តាញធំថ្មីរបស់"ជនក្បត់ និង ខ្មាំង"។[៣០៩] ប្រព័ន្ធសួរចម្លើយរបស់ឌុច ត្រូវបានរៀបចំឡើងដើម្បី ទីមួយ បញ្ជាក់ថា ការសង្ស័យដែលនាំទៅដល់ការចាប់ខ្លួនគឺជារឿងត្រឹមត្រូវ និង ទីពីរ ផ្តល់ភស្តុតាងបន្ថែម ឬ "បញ្ជី"អ្នកដែលគេឆ្លើយដាក់ ហើយដែលតាមរយៈនេះ

---

[៣០៤] ប្រតិចារឹត ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ទំព័រទី១៣-១៤។ សូមមើលផងដែរ ប្រតិចារឹត ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ ទំព័រ ២៣ (បណ្ឌិតឆែនឌ្លឺរ: "ខ្ញុំច្បាស់ថាបណ្ណសារនៅស-២១ គឺវាមានលក្ខណៈពិស្តារ ច្រើនជាងមន្ទីរផ្សេងៗទៀត នៅក្នុងជួរសន្តិបាល (....) ខ្ញុំមិនមានគំនិតថា ទំហំឯកសារនោះមានប៉ុនណាទោះទេ។ ប៉ុន្តែ ខ្ញុំគិតថា បណ្ណសារទាំងអស់នេះ ដូចជារបស់មជ្ឈិមបក្សនោះ គឺមិនមានលក្ខណៈពិស្តារ ទូលំទូលាយដូចដែលមាននៅក្នុងបណ្ណសាររបស់ទួលស្លែងទេ។ អ៊ីចឹងឯកសារដែលយើងមាន យើងធ្វើការនោះ គឺជាឯកសារដែលមានលក្ខណៈរសើប គឺវា គិតថាវាមានរាប់ពាន់ៗទំព័រ រាប់រយទំព័រដែលគេបានចង ក្រងនៅក្នុង ស-២១)។ ប្រតិចារឹត ២៨ ឧសភា ២០០៩, ទំព័រ ១៥ (បណ្ឌិតអេចឆៃស្បិន: "ប៉ុន្តែ ដោយផ្អែកលើភស្តុតាងទាំងនេះ វាច្បាស់ណាស់សម្រាប់ខ្ញុំ ដែលថា ការសួរចម្លើយ និង ដំណើការយកចម្លើយសារភាពនៅស-២១ គឺលម្អិតឆ្ងាយជាងនៅតាមបណ្តាមន្ទីរឃុំឃាំងផ្សេងៗដែលខ្ញុំស្គាល់ (....) ដូច្នេះ មានចម្លើយសារភាពនៅស-២១ខ្លះ ដែលត្រូវបានយកក្នុងរយៈពេលយ៉ាងយូរ ជាច្រើនខែ ចម្លើយសារភាពខ្លះ មានច្រើនជាង១០០០ទំព័រ។ មិនមានមន្ទីរសន្តិសុខណាដែលអាចធ្វើការប្រៀបធៀបបានទេ")។

[៣០៥] ប្រតិចារឹត ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ៩៣។

[៣០៦] ប្រតិចារឹត ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ទំព័រ ៩១។

[៣០៧] ប្រតិចារឹត ២៧ មេសា ២០០៩, ទំព័រ១៣ (បណ្ឌិត ឆែនឌ្លឺរ: "ស-២១ប្រហែលជាស្ថាប័នដែលមានប្រសិទ្ធិភាពបំផុតនៅទូទាំងប្រទេស" "ស្ថាប័នមួយក្នុងចំណោមស្ថាប័នសំខាន់បំផុត")។ សូមមើល ប្រតិចារឹត ២៧ ឧសភា ២០០៩, ទំព័រ៦៩ (បណ្ឌិត អេចឆៃស្បិន: "នៅក្នុងការយល់ឃើញរបស់ខ្ញុំ ស-២១មានលក្ខណៈពិសេសជាងគេនៅក្នុងចំណោមមន្ទីរសន្តិសុខទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ")។

[៣០៨] ប្រតិចារឹត ២២ មិថុនា ២០០៩, ទំព័រ១៩ (ឌុច: "បំណងខ្ញុំចំពោះអ្នកសួរចម្លើយរបស់ខ្ញុំគឺសួររកខ្សែបណ្តាញ...")។

[៣០៩] ប្រតិចារឹត ៨ មិថុនា ២០០៩, ទំព័រ១១០។

00400036

E159/7

បានធ្វើឱ្យភាពមិនទុកចិត្តរបស់ថ្នាក់ដឹកនាំខាងលើកាន់តែកើនខ្លាំងឡើង។ បន្ថែមជាងនេះទៅទៀត ឌុចបានធានាថា ចម្លើយសារភាពត្រូវបាន"សម្រួច"ដើម្បីប្រឌិតមូលហេតុសម្រាប់ការចាប់ខ្លួននរណាម្នាក់ដែលត្រូវការចាប់ខ្លួន។[៣១០] ម៉ាស៊ីនសម្លាប់មនុស្សនេះមាន"សារៈសំខាន់ជាងគេក្នុងការបំពេញគោល-បំណងមជ្ឈិមបក្ស ក្នុងការគ្រប់គ្រងខ្លាំង"។[៣១១]

៩៣. នៅក្នុងការសម្រេចគោលបំណងទាំងនេះ ឌុចបានហ្វឹកហ្វឺនអ្នកក្រោមបង្គាប់របស់ខ្លួនពីរបៀបសួរចម្លើយដែលគាត់ចង់បាន។[៣១២] ឌុចមិនមែនជាអ្នកថ្មីទេ ក្នុងការរៀបចំវិធីសួរចម្លើយនៅតាមមន្ទីរសន្តិសុខ។ តាមការពិត មូលហេតុមួយដែលឌុចត្រូវតម្លើងតំណែងឱ្យទៅជាប្រធានមន្ទីរស-២១ ជំនួសណាត គឺដោយសារតែជំនាញដ៏ប៉ិនប្រសព្វក្នុងបង្កើត និង ប្រើប្រាស់យន្តការសួរចម្លើយនិងធ្វើទារុណកម្មមានប្រសិទ្ធិភាព។[៣១៣] ឌុចមិនខ្វល់អំពីការពិតនៅក្នុងចម្លើយសារភាពនោះទេ ជាការពិតបទពិសោធន៍នៅមន្ទីរម-១៣[៣១៤] បង្រៀនគាត់ថា ចម្លើយសារភាពបានដោយការបង្ខំជាញឹកញាប់ផ្តល់នូវលទ្ធផលមិនសមហេតុផល។[៣១៥] ឌុចបង្រៀនអ្នកសួរចម្លើយឱ្យមើលឃើញអ្នកទោសថាជាខ្មាំង ដើម្បី

---

[៣១០] សូមមើល ឧទាហរណ៍ ប្រតិចារឹត ១៨ ឧសភា ២០០៩, ទំព័រ៥៣។ របាយការណ៍ចិត្តសាស្រ្ត, ទំព័រ៤៣ ("ចម្លើយសារភាពនេះទទួលបាន តាមរយៈ"ការរៀបចំ"ដើម្បីឱ្យសមគ្នាទៅនឹងការសង្ស័យ។ ជនរងគ្រោះត្រូវរំពឹងថានឹងធ្វើតាមទ្រឹស្តីរបស់ចៅហ្វាយ។ ពួកគេធ្វើប្រតិបត្តិការណ៍នៅក្នុងប្រព័ន្ធមួយដែលមិនឡូហ្សិក")។ ប្រតិចារឹត ៨ មិថុនា ២០០៩, ទំព័រ៩ (ឌុចៈ "ដូច្នេះ សម្រាប់អ្នកត្រូវបញ្ជូនទៅមន្ទីរស-២១ បើទោះបីជាចំណោត់ថ្នាក់បទឧក្រិដ្ឋជាការខុសសីលធម៌ ឬមានផែនការ ឬ ជាខ្មាំងក៏ដោយ មិនមានចំណោត់ថ្នាក់បែបនោះទេ។ ដីកាបណោទទួលបានចម្លើយសារភាព នោះជាការស្រេច")។

[៣១១] ប្រតិចារឹត ៦ សីហា ២០០៩, ទំព័រ២៣។

[៣១២] ប្រតិចារឹត ២១ កក្កដា ២០០៩, ទំព័រ១៨-១៩ (ប្រាក់ ខនៈ "ពេលយកចម្លើយសារភាព យើងខ្ញុំត្រូវគេណែនាំយ៉ាងដាច់ខាតឱ្យសួររកពតិមានអំពីខ្សែរបស់អ្នកទោស")។

[៣១៣] ប្រតិចារឹត ៨ មិថុនា ២០០៩, ទំព័រ៣៧។

[៣១៤] ប្រតិចារឹត ៨ មិថុនា ២០០៩, ទំព័រ១០៦។

[៣១៥] ប្រតិចារឹត ២៣ មិថុនា ២០០៩, ទំព័រ១៦ (ឌុចៈ "ចម្លើយសារភាពរបស់សៀត ឆៃ ហៅ ទុំ ដូច្នេះ បន្ទាប់ពីការសួរចម្លើយដោយទុយ គាត់សារភាពថា គាត់បានរំលោភកូនស្រីខ្លួនឯង។ ខ្ញុំយល់ថានេះគឺហួសហេតុពេក[មិនពិត]")។ សូមមើល របាយការណ៍ចិត្តសាស្រ្ត, ទំព័រ៤៣ (ឌុចៈ "នៅពេលសួរចម្លើយ អ្នកទោសតែងតែចង្អុលឈ្មោះមនុស្សទៀត ដោយសារមិនអាចទ្រាំទ្រនឹងទារុណកម្មបាន")។ ប្រតិចារិត ៦ សីហា ២០០៩, ទំព័រ៤៣ (បណ្ឌិត ឆែនឌ្លឺរៈ "ខ្ញុំគិតថា ចុងចោទនិយាយត្រឹមត្រូវណាស់ដែលនិយាយនៅពេលនេះថា គាត់បានប្រកាសថា រឿងនោះ[រឿងដែលថាចម្លើយសារភាពមិនមានការពិត]

E159/7

ជួយសម្រួលដល់ការសើរើរកខ្មែរឃៈខ្មាំង។[៣១៦] អ្នកយាមដែលសួរចម្លើយគឺមិនខ្វល់អំពីបទចោទប្រកាន់មកលើអ្នកទោសទេ។ ពួកគេគ្រាន់តែដឹងថា ទាំងនេះជាបទចោទប្រកាន់ ដែលត្រូវតែឱ្យអ្នកទោសឆ្លើយបញ្ជាក់។[៣១៧] បើតាមបណ្ឌិត ឆែនដ្ហ៊រ ឌុចប្រហែលជាមនុស្សតែម្នាក់គត់នៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ដែលដឹងពីទំហំនៃការប្រឌិតរបស់ចម្លើយសារភាពនៅមន្ទីរស-២១នៅពេលនោះ។[៣១៨] អ្នករួចជីវិតពីមន្ទីរស-២១ ជុំ ម៉ី បានពន្យល់ថា ទារុណកម្មត្រូវបញ្ឈប់តែពេលណាដែលគាត់ឱ្យចម្លើយ"ត្រឹមត្រូវ"តាមអ្វីដែលអ្នកសួរចម្លើយចង់បានប៉ុណ្ណោះ។[៣១៩] អ្នករួចជីវិតម្នាក់ទៀត ប៊ូ ម៉េង បានបន្ថែមថា គាត់ប្រាកដជាចុះហត្ថលេខាលើចម្លើយសារភាព បើទោះបីជាគាត់ដឹងនៅក្នុងចិត្តថា គាត់មិនមែនធ្វើដូចនៅក្នុងចម្លើយសារភាពនោះក៏ដោយ។[៣២០]

---

ពិតជាកើតឡើងមែន ប៉ុន្តែ ប្រសិនបើសំដីបែបនេះដឹងដល់ថ្នាក់លើ ខ្ញុំគិតថា តំណែង និង ជីវិតរបស់គាត់ប្រហែលជាអាចមានគ្រោះថ្នាក់ដែរ")។

[៣១៦] សូមមើល ឧទាហរណ៍ ប្រតិចារឹក ៨ សីហា ២០០៩, ទំព័រ៤៤ (ឌុចៈ "ដូច្នេះ ខ្ញុំបាននិយាយជាមួយកម្មាភិបាលគ្រប់ៗគ្នាឱ្យមើលឃើញអ្នកបញ្ជូនចូលថាជាខ្មាំង។ បើមិនដូច្នោះទេ យើងនឹងមានទស្សនៈផ្ទុយពីបក្ស ហើយយើងនឹងបង្កបញ្ហាឱ្យខ្លួនឯងមិនខាន")។ សូមមើល ប្រតិចារឹក ៨ សីហា ២០០៩, ទំព័រ១០៥។ របាយការណ៍ចិត្តសាស្ត្រ, ទំព័រ៤៣ (ឌុចៈ "ចំពោះអ្នកដែលត្រូវចាប់ខ្លួនដោយបក្ស ពួកគេត្រូវចាត់ទុកថាជាខ្មាំង ត្រូវសួរយកចម្លើយ")។ ប្រតិចារិត ២២ កក្កដា ២០០៩, ទំព័រ២៤-២៥ (ប្រាក់ ខនៈ "នៅស-២១ មានតែឌុចទេដែលបំពាក់បំប៉នគោលជំហររបស់យើង គោលជំហរដាច់ខាតប្រឆាំងខ្មាំងរបស់យើង និងថា យើងត្រូវតែយកចិត្តទុកដាក់ និង ត្រូវចាត់ទុកខ្មាំងជាសត្វ ដូច្នេះ ទើបយើងអាចយកចម្លើយពីខ្មាំងបាន")។

[៣១៧] ប្រតិចារឹក ២២ កក្កដា ២០០៩, ទំព័រ២៩។ សូមមើលផងដែរ ប្រតិចារឹត ២៣ មេសា ២០០៩ ទំព័រ ៣៣ (ឌុចបញ្ជាក់ច្បាស់ណាស់ថា គាត់ត្រូវតែ"បំពាក់បំប៉នពួកគេឱ្យដាច់ខាត បានសួរចម្លើយ")។ ប្រតិចារឹត ៥ សីហា ២០០៩ ទំព័រ៩១។

[៣១៨] ប្រតិចារឹត ៦ សីហា ២០០៩, ទំព័រ៤៣ (បណ្ឌិត ឆែនដ្ហ៊រៈ ខ្ញុំគិតថា ចុងចោទនិយាយត្រឹមត្រូវហោសដែលនិយាយនៅពេលនេះថា គាត់បានប្រកាសថា រឿងនោះរឿងដែលថាចម្លើយសារភាពមិនមានការពិតពិតជាកើតឡើងមែន ប៉ុន្តែ ប្រសិនបើសំដីបែបនេះដឹងដល់ថ្នាក់លើ ខ្ញុំគិតថា តំណែង និង ជីវិតរបស់គាត់ប្រហែលជាអាចមានគ្រោះថ្នាក់ដែរ)។

[៣១៩] ប្រតិចារឹត ៣០ មិថុនា ២០០៩, ទំព័រ២៩ (ជុំ ម៉ីៈ ពួកគេឈប់សួរចម្លើយខ្ញុំ ដោយសារខ្ញុំសារភាពថា ខ្ញុំចូលសេអ៊ីអា និងកាហ្សេបេ។ វាដោយសារតែចម្លើយសារភាពរបស់ខ្ញុំ)។

[៣២០] ប្រតិចារឹត ១ កក្កដា ២០០៩, ទំព័រ៨៥ (ប៊ូ ម៉េងៈ "ជាការពិតណាស់ ខ្ញុំចុះហត្ថលេខាលើចម្លើយសារភាពនោះមែន ប៉ុន្តែក្នុងចិត្ត ខ្ញុំមិនយល់ស្របនឹងចម្លើយសារភាពនោះទេ")។

៩៤. ប្រព័ន្ធសួរចម្លើយបង្កើតដោយឌុច ដំណើរការបានយ៉ាងល្អ។ ដូចដែលបណ្ឌិតឆែនដ្ល័របានបញ្ជាក់ថា "ចម្លើយសារភាព និង ក្បាលម៉ាស៊ីនទាំងមូលទាញយកចម្លើយសារភាព ត្រូវបានអនុញ្ញាតឱ្យមានប្រតិបត្តិការណ៍យ៉ាងស្អិតស្អែរ ក្នុងករណីខ្លះ មិនខ្វល់អំពីភាពត្រឹមត្រូវ និង ផលប្រយោជន៍ ពតិមានល្អទេ...."។[៣២១]

## ២. ចំណាររបស់ឌុច និង បញ្ជីឈ្មោះ បង្កើតនៅពេលសួរចម្លើយតែឯង បានធ្វើឱ្យភាពមិនទុកចិត្តរបស់ថ្នាក់ដឹកនាំខាងលើកាន់តែកើនឡើងៗ

៩៥. ឌុចធ្វើការដូចជាមនុស្សងប់ងល់នឹងការងារពេលចារលើចម្លើយសារភាព។[៣២២] បណ្ឌិត ឆែនដ្ល័រ បានផ្តល់សក្ខីកម្មថា ចំណាររបស់ឌុច ហាក់បីដូចជាល្អឥតខ្ចោះ នៅលើចម្លើយសារភាពរាប់រយ "ចំណារទាំងនេះ ជាញឹកញាប់ កែតម្រូវ និង រិះគន់លើអ្វីដែលអ្នកទោសបានសារភាព។ ចំណារទាំងនេះបង្គាប់ឱ្យវាយ និង ធ្វើទារុណកម្ម។ ចំណារទាំងនេះជម្រុញអ្នកសួរចម្លើយជីកកកាយការពិតដែលអ្នកទោសលាក់។ ឌុចបានសង្ខេបចម្លើយសារភាពរាប់សិប ចង្អុលបង្ហាញអំពីខ្សែរយៈដែលគាត់គិតថាជាប់ពាក់ព័ន្ធនឹងអ្នកមុន ព្រមទាំងបញ្ជាក់ខ្សែរយៈថ្មីដែលត្រូវសួរនាំ"។[៣២៣] ជាងនេះទៅទៀត ចំណេះដឹងផ្ទៃក្នុងជាពិសេសរបស់ឌុច អាចធ្វើឱ្យគាត់វិភាគចម្លើយសារភាព តាមរយៈចំណារផ្សេងៗដើម្បីឱ្យត្រូវគ្នាទៅនឹងបំណងប្រាថ្នារបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ដល់កម្រិតមួយដែលមិនអាចកើតមានទេនៅតាមមន្ទីរសន្តិសុខផ្សេងៗ។ ម៉ម ណៃ ដែលជាអតីតអ្នកយាមមន្ទីរស-២១ បានពន្យល់ថា "តាមអ្វីដែលគាត់សង្កេត ប្រហែលជាបន្ទាប់ពីមើលចម្លើយរួច វិភាគលើចម្លើយនោះ មើលថាត្រូវសួរបន្តទៀតទេ ឬ ចម្លើយនោះត្រូវបញ្ជូនបន្ត ហើយប្រសិនបើត្រូវសួរម្តងទៀត ឌុចចារឱ្យសួរម្តងទៀតឡើងវិញ"។[៣២៤]

---

[៣២១] ប្រតិចារឹក ៦ សីហា ២០០៩, ទំព័រ៤៣។

[៣២២] ប្រតិចារឹក ២២ មិថុនា ២០០៩, ទំព័រ៥៤ (ឌុចបាននិយាយថា បើតាមការប៉ាន់ស្មានរបស់គាត់ គាត់បានពិនិត្យមើលប្រមាណ២សែនទំព័រចម្លើយសារភាព)។ សូមមើលផងដែរនូវ ប្រតិចារឹក ៨ មិថុនា ២០០៩, ទំព័រ ៩៤។ ប្រតិចារឹក ២២ មិថុនា ២០០៩, ទំព័រ ៦១ និង ប្រតិចារឹក ២ កញ្ញា ២០០៩, ទំព័រ ៦៥។

[៣២៣] សម្លេងពីមន្ទីរស-២១, ទំព័រ ២២។

[៣២៤] ប្រតិចារឹក ១៥ កក្កដា ២០០៩, ទំព័រ ៤៤-៤៥។ ប្រតិចារឹក ២១ កក្កដា ២០០៩ ទំព័រ២៨-២៩, ៦៥ (ប្រាក់ ខន: "ចំពោះចម្លើយសារភាពដែលមិនពេញលេញ ចំណារសរសេរថា "សមមិត្តត្រូវសួរបន្ថែមត្រង់ចំណុចនេះ ជាឧទាហរណ៍សួរអំពីខ្សែក្បត់"")។ ដូច្នេះ វាអាស្រ័យលើចំណារលើចម្លើយសារភាព នៅលើរបាយការណ៍ដែលខ្ញុំផ្ញើរ (...) (ឌុច) ចង់តាមដានបន្តបញ្ហានេះ ដូច្នេះហើយខ្ញុំត្រូវជីកកកាយឬសគល់ដើម្បីរកប្រភពអ្នកទោសនោះ របស់ខ្សែនោះ។ សូមមើល ទំព័រ៦៥។

៩៦. ឌុច មិនត្រឹមតែផ្តល់ចំណារជាលាយលក្ខណ៍អក្សរណែនាំអ្នកឃាមប៉ុណ្ណោះទេ ថែមទាំងហៅអ្នកសួរចម្លើយមកណែនាំ[៣២៥] អំពីវិធីសួរចម្លើយថែមទៀត។[៣២៦] ប្រាក់ ខន ពន្យល់ថា នៅពេលឌុចពិនិត្យមើលលើចម្លើយសារភាពមួយ ហើយចង់ឱ្យគាត់ "ស្រាវជ្រាវបន្ត" នេះមានន័យថា គាត់ត្រូវ "ឧទាហរណ៍ សួរចម្លើយឱ្យបានហ្មត់ចត់ និង ជិតដល់ជាងមុន ដើម្បីរកខ្សែរយៈ"។[៣២៧]

៩៧. បន្ថែមលើចម្លើយសារភាពអំពីបុគ្គលអ្នកទោស ឌុចនឹងតម្រូវឱ្យអ្នកទោសប្រាប់ឈ្មោះអ្នកចូលរួមសកម្មភាពប្រឆាំងនឹងខ្មែរក្រហម។[៣២៨] អ្នកទោសត្រូវបង្ខំចិត្តផ្តល់បញ្ជីឈ្មោះមនុស្ស[៣២៩] ដែលក្រោយមក

---

ប្រតិចារឹត ៤ សីហា ២០០៩, ទំព័រ២៩-៣០: ម្សាច មាន: "បន្ទាប់ពីវាយបញ្ចូលចម្លើយសារភាពរួច ចម្លើយសារភាពទាំងនេះត្រូវបញ្ជូនទៅឌុច ដើម្បីពិនិត្យ និង ស្វែងរកខ្សែក្បត់ ដោយផ្អែកលើចម្លើយសារភាពទាំងនោះ"។

[៣២៥] ប្រតិចារឹត ២៨ ឧសភា ២០០៩, ទំព័រ ២០, បណ្ឌិត អេចឆែស្សិន បានផ្តល់សក្ខីកម្មថា ប្រព័ន្ធសរសេរចំណារ របស់ឌុច "ជាលទ្ធផលនៃវិធីធ្វើការផ្ទាល់ខ្លួនរបស់ជនជាប់ចោទ។ តាមរយៈមុខជំនាញ ជនជាប់ចោទជាគ្រូបង្រៀន ហើយដូច្នេះជនជាប់ចោទស៊ាំទៅនឹងចារលើក្រដាសលំហាត់កូនសិស្ស។ ការប៉ាន់ស្មានរបស់ខ្ញុំគឺថា ជនជាប់ចោទបន្តការអនុវត្តនេះនៅក្នុងមុខជំនាញថ្មីរបស់គាត់ជាអ្នកសួរចម្លើយ"។ សូមមើលផងដែរឡូវ ប្រតិចារឹត ២៨ ឧសភា ២០០៩, ទំព័រ២១-២២ដែរ អំពីប្រភេទផ្សេងៗនៃចំណារទាំងនោះ។ ប្រតិចារឹត ២ កញ្ញា ២០០៩, ទំព័រ៦៧។ (ឌុច ហាក់បីដូចជាសារភាពថា គាត់ជាអ្នកចាប់ផ្តើមប្រព័ន្ធសរសេរចំណារនេះនៅមន្ទីរស-២១ បើទោះបីជាចម្លើយរបស់គាត់ពុំសូវច្បាស់លាស់ក៏ដោយ។ ឌុច: "នៅផ្នែកទីពីរនៃការវិវឌ្ឍន៍នេះ ចំពោះអ្នកដែលណាតគិតថាខ្ញុំស្គាល់ ណាតបញ្ជូនចម្លើយសារភាពទាំងនោះមកឱ្យខ្ញុំចារពីលើ ហើយបន្ទាប់ពីទទួលបាន ណាតបានសរសេរចំណារលើនោះបន្ថែមទៀត")។

[៣២៦] ប្រតិចារឹត ២២ កក្កដា ២០០៩, ទំព័រ ៤៥-៤៦, (ប្រាក់ ខន: "... ថា ម្នាក់នេះនៅក្នុងខ្សែនោះ នៅក្នុងភូមិភាគនោះ ដូច្នេះសួរយកចម្លើយដើម្បីស្រាវជ្រាវបន្ត")។

[៣២៧] ប្រតិចារឹត ២២ កក្កដា ២០០៩, ទំព័រ ៤៥-៤៦, ប្រាក់ ខន: "... ថា ម្នាក់នេះនៅក្នុងខ្សែនោះ នៅក្នុងភូមិភាគនោះ ដូច្នេះសួរយកចម្លើយដើម្បីស្រាវជ្រាវបន្ត"។

[៣២៨] ប្រតិចារឹត ៨ មិថុនា ២០០៩, ទំព័រ ៨០។

[៣២៩] សូមមើល ឧទាហរណ៍ ប្រតិចារឹត ១៨ ឧសភា ២០០៩, ទំព័រ ៥៦, (បណ្ឌិត អេចឆែស្សិន: "... ថា របៀបស-២១សរសេរចម្លើយ សារភាពគឺថា អ្នកទោសត្រូវបង្ខំឱ្យសារភាពពីសកម្មភាពក្បត់។ ដូច្នេះនៅក្នុងចម្លើយសារភាពនោះត្រូវឱ្យឈ្មោះមនុស្សដែល ចូលរួម។ ឈ្មោះទាំងនោះនឹងត្រូវចាប់ខ្លួន ដោយសារអ្នកទោសមុនឆ្លើយដាក់ខ្លួន ពីព្រោះជាធម្មតានៅពេលមនុស្សម្នាក់ត្រូវចាប់ខ្លួន អ្នកនោះត្រូវតែចូលរួមជាមួយមនុស្សផ្សេងទៀតដើម្បីប្រព្រឹត្តអំពើក្បត់ ដោយសារជននោះមិនអាចធ្វើសកម្មភាពតែម្នាក់ឯងបានទេ។ ដូច្នេះហើយបានជាមានឈ្មោះកាន់តែច្រើននៅក្នុងចម្លើយសារភាពទាំងនោះ")។ សូមមើលផងដែរ ប្រតិចារឹត ៨ មិថុនា ២០០៩, ទំព័រ ៨៧-៩០។ សូមមើលប្រតិចារឹត ១៥ កក្កដា ២០០៩, ទំព័រ ៤៦ (ម៉ម ណៃ: "អ្វីដែលខ្ញុំនិយាយគឺជាការពិត។ បញ្ជីឈ្មោះអ្នកទោសដែលធ្វើឡើងដោយអ្នកសួរចម្លើយគឺជាឈ្មោះរបស់អ្នកដែលគាឆ្លើយដាក់ទៅក្នុងចម្លើយសារភាព"។ បណ្ឌិត ឆែនដ្ល័របានអះអាងស្រដៀងគ្នានេះអំពីបញ្ជីនេះ)។ ប្រតិចារឹត ២៨ ឧសភា

ត្រូវចាប់ខ្លួនដែរ និង បញ្ជូនទៅមន្ទីរស-២១។[៣៣០] បន្ថែមទៅលើបញ្ជីឈ្មោះដែលឱ្យដោយអ្នកទោស ឌុច ក៏បានឱ្យអ្នកសួរចម្លើយចងក្រងបញ្ជីឈ្មោះផ្សេងទៀត ដោយផ្អែកលើចម្លើយសារភាពដែលបានពីអ្នកទោស។[៣៣១] បណ្ឌិត អេចឆែស៊្សិន បានផ្ដល់សក្ខីកម្មថា អាចមានបញ្ជីឈ្មោះខ្មាំងផ្ញើទៅមន្ទីរស-២១ ដល់ទៅរាប់ពាន់។[៣៣២] ការបង្កើតប្រព័ន្ធល្អិតល្អន់នេះឯងដែលបានទាក់ទាញចំណាប់អារម្មណ៍របស់មេដឹកនាំថ្នាក់លើ បង្កការមិនទុកចិត្តកាន់តែខ្លាំង ដែលធ្វើឱ្យឌុចជាអ្នកបង្កើតប្រព័ន្ធនេះត្រូវតម្លើងតំណែងជាប្រធានមន្ទីរស-២១។[៣៣៣]

៩៨. ការបង្កើតបញ្ជីឈ្មោះដ៏អសោចនេះមិនមែនដោយសារបញ្ជារបស់ថ្នាក់ដឹកនាំខាងលើទេ។ ផ្ទុយទៅវិញ ឌុចជាមេគំនិតនៃការអនុវត្តបែបនេះ តាមរយៈការប្រើប្រាស់ស្វ័យតភាពរបស់គាត់។[៣៣៤] ការច្នៃប្រឌិតរបស់ឌុច និង ការប្រើប្រាស់យ៉ាងល្អតខ្ចោះនូវម៉ាស៊ីនសម្លាប់មនុស្សនេះដែលធ្វើឱ្យគាត់ត្រូវតែង

---

២០០៩ ទំព័រ១៨ (បណ្ឌិត អេចឆែស៊្សិនៈ "នៅក្នុងបណ្ណសារស-២១ យើងរកឃើញបញ្ជីឈ្មោះអ្នកទោសស្នើឡើងដោយអ្នកសួរចម្លើយ និង បុគ្គលិកស-២១ ផ្សេងទៀតតាមរយៈការវិភាគលើចម្លើយសារភាពរបស់ជនរងគ្រោះ។ ដូច្នេះ នេះជាបញ្ជីមួយប្រភេទទៀត ដែលជាបញ្ជីធ្វើឡើងដោយបុគ្គលិក មិនមែនដោយជនរងគ្រោះទេ")។

[៣៣០] ប្រតិចារឹត ២៨ ឧសភា ២០០៩ ទំព័រ៧៩ (បណ្ឌិត អេចឆែស៊្សិនៈ "នៅក្នុងបណ្ណសារស-២១ យើងរកឃើញបញ្ជីឈ្មោះអ្នកទោសស្នើឡើងដោយអ្នកសួរចម្លើយ និង បុគ្គលិកស-២១ ផ្សេងទៀតតាមរយៈការវិភាគលើចម្លើយសារភាពរបស់ជនរងគ្រោះ។ ដូច្នេះ នេះជាបញ្ជីមួយប្រភេទទៀតដែលជាបញ្ជីធ្វើឡើងដោយបុគ្គលិក មិនមែនដោយជនរងគ្រោះទេ")។ ប្រតិចារឹត ២២ កក្កដា ២០០៩, ទំព័រ ៤៥-៤៦។

[៣៣១] ប្រតិចារឹត ២២ កក្កដា ២០០៩, ទំព័រ ៤៥-៤៦។ ប្រតិចារឹត ២៨ ឧសភា ២០០៩ ទំព័រ៩១ (បន្ទាប់មកបញ្ជីទាំងនេះត្រូវយកទៅចាប់ជនក្បត់ថ្មី ហើយវិធីនេះប្រើប្រាស់ជាបន្តទៀត។ ដូច្នេះអ្នកឃើញនូវការកើនឡើងចំនួនជនក្បត់ដែលគេចោទ និង ចំនួនជនរងគ្រោះដែលត្រូវបោសសម្អាត។ ជាចំណែកខ្លះ វាដោយសារតែបំណងប្រាថ្នារបស់ជនជាប់ចោទក្នុងការបំពេញកិច្ចការនេះដែលធ្វើឱ្យវិធីសាស្ត្រនេះបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះចំនួនច្រើនដល់ម្លឹង។ នេះជាហេតុផលដែលខ្ញុំលើកឡើងដើម្បីឆ្លើយតបនឹងសំណួរនេះថា ម្យ៉ាង គោលនយោបាយរបស់គណៈកម្មការមជ្ឈិមពិតជារួមចំណែកបង្ករសោកនាដកម្មនេះ ប៉ុន្តែទន្ទឹមនោះដែរ ការកែច្នៃ ការច្នៃប្រឌិត និង ចំណង់របស់កម្មាភិបាលអនុវត្តគោលនយោបាយទាំងនោះ ក៏បានរួមចំណែកយ៉ាងខ្លាំងដល់ទំហំនៃសោកនាដកម្មនេះដែរ")។

[៣៣២] ប្រតិចារឹត ២៨ ឧសភា ២០០៩, ទំព័រ ១៩។

[៣៣៣] ប្រតិចារឹត ២៨ ឧសភា ២០០៩, ទំព័រ ១៩។ សូមមើល ប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ ៨៧ (បណ្ឌិត ឆែនឌ្លឺរបានបញ្ជាក់ថា ការយល់ឃើញរបស់បណ្ឌិត អេចឆែស៊្សិន ជា "ការសន្និដ្ឋានសមហេតុសមផល")។

[៣៣៤] សូមមើល ប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ ១៨។

E159/7

តាំងជាប្រធានមន្ទីរស-២១ ដោយថ្នាក់ដឹកនាំខាងលើ ។[៣៣៥] ជាក់ស្តែង ចំណុចសំខាន់មួយដែលនាំទៅដល់ការតម្លើងតំណែងរបស់ឌុច គឺការអនុវត្តយ៉ាងជោគជ័យ មានប្រសិទ្ធិភាព និង មានធនធាន នូវបច្ចេកទេសធ្វើទារុណកម្ម និង ការសួរចម្លើយ ។[៣៣៦]

### ៣. ការកើនឡើងនូវភាពមិនទុកចិត្តបង្កើតឡើងដោយឌុច បាននាំទៅដល់ការចាប់ខ្លួន និង សម្លាប់"ខ្មាំងនិងជនក្បត់"កាន់តែច្រើននៅមន្ទីរស-២១

៩៥. នៅពេលទទួលបាន និង ចំណារលើចម្លើយសារភាពតាមការពេញចិត្តរបស់ឌុចរួច បញ្ជីឈ្មោះត្រូវបញ្ជូនឡើងលើទៅកាន់លេខាភូមិភាគ ។[៣៣៧] បញ្ជីដែលធ្វើឡើងដោយឌុចបានបញ្ចុះបញ្ចូលដល់ថ្នាក់ដឹកនាំខាងលើឱ្យជឿថា មានគម្រោងក្បត់យ៉ាងធំប្រឆាំងនឹងពួកគេ[៣៣៨] ដែលតាមរយៈនេះបានបង្កឱ្យមានការចាប់ខ្លួន និង ការបោសសម្អាតដែលមានការកើនឡើងយ៉ាងខ្លាំង បន្ទាប់ពីឌុចចាប់ផ្តើមដំណើរការនេះ ។[៣៣៩] ឌុចតែម្នាក់ឯងជាអ្នកបង្កនូវវដ្តដ៏ឃោរឃៅនៃការចាប់ខ្លួន យកចម្លើយសារភាព និង ការស្លាប់ ។[៣៤០]

---

[៣៣៥] ប្រតិចារឹក ៦ សីហា ២០០៩ ទំព័រ ៨៧ ។

[៣៣៦] ប្រតិចារឹក ៨ មិថុនា ២០០៩ ទំព័រ ៣៧ ។

[៣៣៧] ប្រតិចារឹក ៨ មិថុនា ២០០៩ ទំព័រ ៨៤ ។

[៣៣៨] ប្រតិចារឹក ២៨ ឧសភា ២០០៩ ទំព័រ ២៨ (បណ្ឌិត អេចឆែស្ស៊ិនៈ "ខ្ញុំជឿថា ខ្លឹមសារនៅក្នុងចម្លើយសារភាព ពីមន្ទីរស-២១ដែលធ្វើឱ្យថ្នាក់ដឹកនាំខាងលើជឿជាក់ថាមានគម្រោងក្បត់ប្រឆាំងនឹងពួកគេដោយថ្នាក់ដឹកនាំទ័ពមួយចំនួន") ។ ប្រតិចារឹក ២ កញ្ញា ២០០៩. ទំព័រ ៦៣ (ដោយយោងទៅលើសៀវភៅរបស់អេលី ហ្សាបែត ប៊ែកយ័រ ដែលនិយាយថា "ដោយគ្រប់គ្រងលើចម្លើយសារភាពរបស់ជនរងគ្រោះ ដែលនៅពេលនោះជាភស្តុតាងនៃឧក្រិដ្ឋកម្ម [ឌុច] ជាបណ្តើៗអាចធ្វើឱ្យធ្វើឱ្យថ្នាក់ដឹកនាំខាងលើជឿ និង ចង្អុលទៅខ្មាំងផ្សេងទៀត") ។

[៣៣៩] ប្រតិចារឹក ២ កញ្ញា ២០០៩. ទំព័រ ៨២ ។

[៣៤០] ប្រតិចារឹក ២៧ ឧសភា ២០០៩. ទំព័រ ៨១ ។ ប្រតិចារឹក ២៨ ឧសភា ២០០៩. ទំព័រ ២៨-២៩ (បណ្ឌិត អេចឆែស្ស៊ិន បានពន្យល់ពីរបៀបដែលភាពមិនទុកចិត្ត និង ប្រព័ន្ធបញ្ជីឈ្មោះអ្នកទោស បានធ្វើឱ្យការបោសសម្អាត កើនឡើង) ។ សូមមើល ប្រតិចារឹក ៦ សីហា ២០០៩ ទំព័រ ១១៤ (បណ្ឌិតឆែនដ្លើរៈ "ខ្ញុំចង់និយាយថា អ្វីៗគ្រប់យ៉ាងមិនអាច គ្រប់គ្រងបានទេ ។ ទន្ទឹមនឹងពេលដែលកន្លែងនោះចាប់ផ្តើមបែកខ្ញែក ចំនួនខ្មាំងកាន់តែកើនឡើងខ្លាំង ការមិនទុកចិត្តគ្នាកាន់តែ ខ្លាំងឡើង ទំនាយបានក្លាយជាការពិត ព្រោះបើមានមនុស្សមានកំហុសច្រើន ដូចដែលនិយាយជាភាសាខ្មែរថា "ការរក្សាការសម្ងាត់"

E159/7

១០០. ដូច្នេះ វាមិនមែនជាការចៃដន្យនោះទេដែលថា ចំនួនមនុស្សត្រូវចាប់ខ្លួន និង បញ្ជូនទៅមន្ទីរស-២១ ចាប់ផ្ដើមកើនឡើងនៅក្នុងខែសីហា ឆ្នាំ១៩៧៦ និង ចាប់ផ្ដើមធ្លាក់ចុះវិញនៅបន្ទាប់ពីខែមិថុនា ១៩៧៨។[៣៤១] ជាក់ស្ដែង ចំនួនមនុស្សត្រូវចាប់ខ្លួនបានធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងអំឡុងពេលដែលឌុច មិនបានពិនិត្យមើលចម្លើយសារភាព[៣៤២] ដែលនេះបញ្ជាក់ឱ្យឃើញពីតួនាទីសំខាន់របស់ឌុចនៅក្នុងមន្ទីរឃុំឃាំងនេះ។ អ្នកយាមគុកមិនតិចជាង៤នាក់ទេដែលផ្ដល់សក្ខីកម្មថា ការចង្អុល"ជនក្បត់" និង ខ្សែរយៈជាមូលហេតុផ្ទាល់នាំទៅដល់ការផ្ទេរអ្នកទោសទៅមន្ទីរស-២១។[៣៤៣] បណ្ឌិតអេចផែស្សិនក៏បានពន្យល់យ៉ាងច្បាស់ផងដែរអំពីផលប៉ះពាល់ដោយផ្ទាល់ រវាងប្រព័ន្ធដែលបង្កើតឡើងដោយឌុចនៅស-២១ និង ការចាប់ខ្លួនទ្រង់ទ្រាយធំបន្ទាប់ពីនោះ។[៣៤៤]

១០១. បើទោះបីជាមានភស្តុតាងផ្ទុយជាច្រើនបែបណាក៏ដោយ ក៏ឌុចនៅបន្តអះអាងថា ការងារនៅស-២១របស់គាត់ មិនមានផលប៉ះពាល់ដោយផ្ទាល់ចំពោះការកើនឡើងនូវការចាប់ខ្លួនដែលធ្វើឡើងបន្ទាប់ពីការអនុវត្តប្រព័ន្ធសួរចម្លើយ និង ចំណារទេ។[៣៤៥] ឌុចបានអះអាងថា គាត់គ្រាន់តែអនុវត្តអ្វីដែលបញ្ជា

---

ចេះតែហូរចូលមន្ទីរស-២១ នោះប្រាកដណាស់ទំហំនៃការក្បត់គឺធំធេងណាស់ ហើយប្រាកដណាស់ អ្នកឯងប្រាកដជាបន្តធ្វើបបនោះទៀតមិនខាន")។

[៣៤១] ប្រតិចារឹត ២២ មិថុនា ២០០៩, ទំព័រ ៦៦-៦៧ និង សូមមើល "បញ្ជីអ្នកទោសស-២១រួមរបស់ការិយាល័យសហព្រះរាជអជ្ញារ: ឧបសម្ព័ន្ធ និង តារាង: តារាង៣"។

[៣៤២] "បញ្ជីអ្នកទោសស-២១រួមរបស់ការិយាល័យ សហព្រះរាជអជ្ញារ: ឧបសម្ព័ន្ធ និង តារាង: តារាង៣"។ ឆៃនដ្ល័របានបញ្ជាក់បន្ថែមលើតារាងរៀបចំដោយសហព្រះរាជអជ្ញារ និង ការណ៍ដែលថា ការបោសសម្អាតបានថយចុះនៅក្នុងឆ្នាំ១៩៧៨: ប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ ២០-២២។

[៣៤៣] ប្រតិចារឹត ២៨ កក្កដា ២០០៩ ទំព័រ ៦៥-៦៦ (សួស ធី: "ឧទាហរណ៍ ប្រសិនបើអ្នកទោសរត់រួច អ្នកយាមនឹងត្រូវចាប់ខ្លួន និង ធ្វើទារុណកម្ម។ ធ្វើទារុណកម្មកាន់តែខ្លាំង ចង្អុលទៅអ្នកផ្សេងកាន់តែខ្លាំង ធ្វើឱ្យការចាប់ខ្លួនកាន់តែច្រើនដែរ។ វាស្មុគស្មាញពេក...")។ ប្រតិចារឹត ១៦ កក្កដា ២០០៩ ទំព័រ ៤១-៤២ (ហ៊ឹម ហ៊ុយ បានរៀបរាប់អំពីរបៀបដែលកងពល៧០៣ ត្រូវចាប់ខ្លួនជាបន្តបន្ទាប់បញ្ជូនទៅស-២១)។ ប្រតិចារឹត ១៥ កក្កដា ២០០៩ ទំព័រ ៤៦ (ម៉ម ណៃ ពន្យល់ពីដំណើរការចាប់ខ្លួន បន្ទាប់ពីការបង្កើតបញ្ជីឈ្មោះដោយអ្នកសួរចម្លើយមក)។ សូមមើល ប្រតិចារឹត ២២ កក្កដា ២០០៩ ទំព័រ ៤៧ (ប្រាក់ ខន)។

[៣៤៤] ប្រតិចារឹត ១៨ ឧសភា ២០០៩ ទំព័រ ៥៦។ ប្រតិចារឹត ១៩ ឧសភា ២០០៩ ទំព័រ ៧-៨, ប្រតិចារឹត ២៨ ឧសភា ២០០៩, ទំព័រ ២៨, ៥១។

[៣៤៥] សូមមើល ឧទារណ៍ ប្រតិចារឹត ៨ មិថុនា ២០០៩ ទំព័រ ១៨ (ឌុច: "...មូលដែលគេសម្រេចចាប់ខ្លួនមនុស្សអំណាចគឺស្ថិតនៅលើមនុស្សទាំងបួនក្រុមនោះ។ មិនមានអ្នកផ្សេងមានអំណាចទេ។ ខ្ញុំនិយាយអំពីមនុស្សបួនក្រុម មិនមែន

ដោយថ្នាក់ដឹកនាំខាងលើប៉ុណ្ណោះ ហើយគ្មានអំណាចអ្វីនឹងចាប់នរណាម្នាក់ដោយខ្លួនគាត់ទេ។[៣៤៦] ឌុច ថែមទាំងនិយាយថា គាត់"គ្មានបំណងចាប់មនុស្សបញ្ជូនទៅស-២១ទេ"។[៣៤៧] ឌុចអះអាងថា បើទោះបីជាគាត់បានបញ្ជាឱ្យអ្នកក្រោមបង្គាប់ស្វែងរកខ្សែខ្មាំងទាំងអស់ក៏ដោយ គាត់ធ្វើយ៉ាងនេះគឺដើម្បីតែ"កំណត់[ខ្មាំង] ឱ្យច្បាស់លាស់តែប៉ុណ្ណោះ និង មិនមែនដើម្បីឱ្យគេចាប់ខ្លួនអ្នកទាំងនោះទេ"។[៣៤៨]

១០២. ទោះយ៉ាងណាក៏ដោយ នៅពេលឌុចត្រូវប្រឈមមុខទៅនឹងចម្លើយសារភាពណាមួយ ឌុចត្រូវបង្ខំចិត្តសារភាពថា គាត់និយាយមិនពិត និងថា គាត់ពិតជាបានស្នើសុំឱ្យគណៈអចិន្ត្រៃយ៍ចាប់មនុស្សមែន។[៣៤៩] ម្តងនោះ សំណើរបស់គាត់រួមមានការចាប់ខ្លួនច្រើនជាង១០០នាក់[៣៥០] និង ថែរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយថ្នាក់លើ ដើម្បីធ្វើឱ្យមានការចាប់ខ្លួននេះ។[៣៥១] ឌុចដឹងយ៉ាងច្បាស់ណាស់ថា ការចាប់

---

មនុស្សប្អូននាក់ទេ។ សូម្បីតែរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មមិនមានអំណាចនេះទេ។ ប្រសិនបើត្រូវសម្រេចដោយមនុស្សបួនក្រុមនេះ គេត្រូវតែចាប់។ ដូច្នេះ ខ្ញុំនៅស-២១មានការលំបាកក្នុងការពន្យល់អំពីមធ្យោបាយដែលអាចបដិសេធនឹសេចក្តីសម្រេចបែបនេះ")។ ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ៤៧។

[៣៤៦] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ៤២, ៤៦, ៦៩ (ឌុចៈ "គោលការណ៍ចែងថា ស-២១គ្មានអំណាចចាប់មនុស្សទេ ខ្ញុំត្រូវតែអនុវត្តតាមនេះ ហើយខ្ញុំបានអនុវត្តរបៀបនេះតាំងពេលនៅម-១៣ម្លេះ")។

[៣៤៧] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ១០។

[៣៤៨] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ៧។

[៣៤៩] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ១០។

[៣៥០] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ១២។ សូមមើលផងដែរ ប្រតិចារឹត ១៦ កក្កដា ២០០៩, ទំព័រ ២៩-៣០ (ហ៊ឹម ហ៊ុយ បានរៀបរាប់ប្រាប់ពីឧទាហរណ៍ផ្សេងទៀតអំពីការចាប់ខ្លួនដោយបុគ្គលិកស-២១ៈ "ចំពោះការចាប់ខ្លួនប៉ង់ យើងត្រូវបានណែនាំឱ្យចាប់ខ្លួនមនុស្សសំខាន់ម្នាក់ ម្នាក់នោះគឺប៉ង់ ហើយយើងត្រូវគេណែនាំប្រាប់ពេលវេលាជាក់លាក់ម្នាក់នោះមកដល់។ ដូច្នេះ យើងលាក់ខ្លួន ហើយនៅពេលប៉ង់ជិះម៉ូតូមកដល់ផ្ទះ យើងមកអង្គុយជាមួយ រួចចាប់ខ្លួនតែម្តង (...) តួនាទី(របស់ឌុច)មានតួនាទីសំខាន់។ គាត់គ្រប់គ្រងយើងពេលធ្វើការចាប់ខ្លួន ហើយយើងត្រូវតែអនុវត្តការណែនាំនេះឱ្យបានជោគជ័យ (...) នៅពេលចាប់ខ្លួន គាត់មិនមានវត្តមាននៅក្បែរកន្លែងចាប់ខ្លួននោះទេ។ ក្រុមរបស់ខ្ញុំជាអ្នកធ្វើការចាប់ខ្លួនដោយសារថាគាត់ស្គាល់គេគ្រប់គ្នា ដូច្នេះប្រសិនបើពួកគេឃើញគាត់ គេនឹងដឹងថាពួកគេត្រូវចាប់ខ្លួន")។ សូមមើល ប្រតិចារឹត ១៨ ឧសភា ២០០៩ ទំព័រ៤៧-៤៨ (ឌុចនិយាយអំពីកិច្ចប្រជុំបើកចំហរមួយរបស់សេនាធិការ និយាយពីការចាប់ខ្លួននៅក្នុងកងពល១៧០ និង ២៩០)។

[៣៥១] ប្រតិចារឹត ២១ ឧសភា ២០០៩ ទំព័រ ៥៩ (បណ្ឌិតអេចឆៃស៊្មិនៈ "យោងតាមឯកសារនេះ មនុស្សម្នាក់ទៀតដែលចូលរួមក្នុងកិច្ចប្រជុំគឺសុន សេន (...)។ ដូច្នេះ ជនជាប់ចោទនេះធ្វើទំនាក់ទំនងទៅថ្នាក់កំពូលរបស់បក្សកុម្មុយនិស្តកម្ពុជា និងបន្ទាប់មក ដាក់ចុះតាមខ្សែបណ្តោយតាមរយៈសុន សេន ទៅកងពលផ្សេងៗដើម្បីជួយសម្រួលដល់ការរៀបចំផែនការ និង

ខ្លួនមនុស្សនៅក្នុងបញ្ជីរបស់គាត់ មានន័យថា ពួកគេនឹងត្រូវបញ្ជូនទៅស-២១ ដោយមានគោលដៅតែមួយគត់គឺយកចម្លើយសារភាព និងបន្ទាប់មកត្រូវ "កម្ទេច"។[៣៥២] ជាងនេះទៅទៀត ឌុចបានប្រើឱ្យបុគ្គលិករបស់គាត់ចេញពីមន្ទីរស-២១ទៅចាប់ខ្លួនមនុស្សនៅតាមអង្គភាពផ្សេងៗ។[៣៥៣] ឌុចនឹងបន្តជួយដោយផ្ទាល់រៀបចំគម្រោងបោសសម្អាតយ៉ាងធំ។[៣៥៤] ដូច្នេះ វាច្បាស់ណាស់តាមរយៈភស្តុតាងផ្តល់ជូនទៅពេលសវនាការថា ប្រព័ន្ធល្អិតល្អន់ក្នុងការសួរចម្លើយ យកចម្លើយសារភាពវិភាគ និង ចារលើចម្លើយសារភាព និង ចុងក្រោយបំផុត ការបង្កើតបញ្ជីឈ្មោះខ្មាំងដោយឌុច ជាកត្តាផ្ទាល់នាំទៅដល់ការចាប់ខ្លួន និង "កម្ទេច" "ជនក្បត់" និង ក្រុមគ្រួសាររបស់គេយ៉ាងច្រើននៅស-២១។[៣៥៥]

---

ធ្វើនូវអ្វីដែលក្លាយជាការបោសសម្អាតយ៉ាងធំនៅក្នុងជួរកងទ័ពដែលជាប់ពាក់ព័ន្ធជាមួយចាន់ ចក្រី (...) លោកព្រះរាជអាជ្ញារ សម្រាប់ខ្ញុំ វាច្បាស់ណាស់ថា ប្រតិបត្តិការនេះត្រូវធ្វើឡើងក្រោមអំណាចផ្ទាល់របស់មជ្ឈិមបក្ស ដែលអនុញ្ញាតឱ្យមានទំនាក់ទំនងបែបនេះរវាងស-២១ និង អង្គភាពមុខសញ្ញាដែលត្រូវអនុវត្តការបោសសម្អាតដែលគ្រោងនេះ")។

[៣៥២] របាយការណ៍កោសល្យវិច័យចិត្តសាស្ត្រ, ទំព័រ៤៣ (ឌុចៈ "នៅពេលសួរចម្លើយ អ្នកទោសត្រូវតែឱ្យឈ្មោះមនុស្ស ព្រោះពួកគេមិនអាចទ្រាំទ្រនឹងទារុណកម្មបាន។ អ្នកដែលគេចង្អុលឈ្មោះដាក់នេះនឹងត្រូវសម្លាប់ជាលក្ខណៈប្រព័ន្ធ"។ កត់សម្គាល់ដោយចិត្តវិទូផងដែរៈ "គេអាចគិតថា មន្ទីរស-២១ ជាម៉ាស៊ីន សម្រាប់ផលិតពលិកម្មរបស់មនុស្ស ដើម្បីចិញ្ចឹមប្រព័ន្ធដែលបិតបេរមួយ។ លក្ខណៈពិសេសនៃប្រភេទប្រព្ធទាំងនេះគឺគ្មានទីបញ្ចប់ និង ត្រូវតែចាប់ផ្តើមឡើងវិញជានិច្ច។ នេះគឺវាអាចជានាទីរបស់ "ការជាប់ទាក់ទងគ្នានៃការក្បត់"។ ចំណុចទាក់ទងនឹងការពិតគឺមានសារៈសំខាន់តិចតួចប៉ុណ្ណោះ គឺភាពសមជាពិត ដែលមានសារៈសំខាន់ជាងតថភាព។ គេត្រូវចិញ្ចឹមអង្គការដោយពលិកម្មជាបន្តបន្ទាប់")។

[៣៥៣] ប្រតិចារឹត ១៩ ឧសភា ២០០៩, ទំព័រ ៥៦ (បណ្ឌិតអេចឆែស្ស៊ិនៈ "ជនជាប់ចោទបានរៀបរាប់ប្រាប់សហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់ក៏ម្តងដែរ ដែលកងកម្លាំងរបស់គាត់បានចាកចេញពីមន្ទីរស-២១ទៅចាប់ខ្លួនអ្នកទោសនៅអង្គភាពផ្សេង។ ខ្ញុំជឿថា ប្រហែលជាមានរឿងបែបនេះកើតឡើងច្រើនជាងអ្វីដែលជនជាប់ចោទបានប្រាប់យើង")។

[៣៥៤] ប្រតិចារឹត ២១ ឧសភា ២០០៩ ទំព័រ ៥៩ (បណ្ឌិតអេចឆែស្ស៊ិនៈ "ដូច្នេះ ជនជាប់ចោទនេះធ្វើទំនាក់ទំនងទៅថ្នាក់កំពូលរបស់បក្សកុម្មុយនិស្តកម្ពុជា និង បន្ទាប់មក ដាក់ចុះតាមខ្សែបណ្តោយតាមរយៈសុន សេន ទៅកងពលផ្សេងៗ ដើម្បីជួយសម្រួលដល់ការរៀចផែនការ និង ធ្វើនូវអ្វីដែលក្លាយជាការបោសសម្អាត យ៉ាងធំនៅក្នុងជួរកងទ័ព")។ ប្រតិចារឹត ១៨ ឧសភា ២០០៩, ទំព័រ ៤៧-៤៨ (ឌុចបានបញ្ជាក់បន្ថែមត្រង់ចំណុចនេះ)។

[៣៥៥] ប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ ១២-១៣ (បណ្ឌិតឆែនដ្លឺរៈ "ប៉ុន្តែ ការកំណត់ខ្មាំងនេះ បើនិយាយឱ្យចំទៅ គឺការសង្ស័យទៅលើមនុស្សដែលគេបាននាំយកមកស-២១ គឺជាការងាររបស់អ្នកសួរចម្លើយ ហើយដែលគេធ្វើការក្រោមការដឹកនាំរបស់ជនជាប់ចោទ។ នេះហើយជាការកំណត់ខ្មាំងជាក់លាក់នោះ គឺវាចេញពីអត្ថបទ ឬក៏ឯកសារផ្សេងដែលមិនសូវមានសារប្រយោជន៍ក្នុងពេលនេះទេ ក្នុងការកំណត់ទីតាំងខ្មាំង)។ សូមមើល ប្រតិចារឹត ៦ សីហា ២០០៩, ទំព័រ២៤ដែរ។

E159/7

## ខ. ឌុចជាកម្មាភិបាលខ្មែរក្រហមដែលព្រមធ្វើអ្វីទាំងអស់ដើម្បីថែរក្សាអំណាចនៅ ស-២១

១០៣. សវនាការចំពោះមុខអង្គជំនុំជម្រះបានបង្ហាញដោយគ្មានការសង្ស័យថា ឌុចគឺមានការផ្ចិតផ្ចង់ណាស់នៅក្នុងសកម្មភាពខ្លួន និង ជានិច្ចកាលចង់កាន់តែធ្វើឱ្យល្អជាងមុន។ លក្ខណៈនេះលេចចេញច្បាស់នៅពេលគាត់កាន់តំណែងជាប្រធានស-២១ តាមរយៈបំណងជាប្រចាំរបស់គាត់"ចង់ផ្គាប់ចិត្តថ្នាក់លើ"។[៣៥៦] ឌុចបានជម្រុញឱ្យអ្នកក្រោមបង្គាប់ធ្វើការកាន់តែមុះមុតជាងមុន ការធ្វើចំណាររបស់គាត់គឺធ្វើឡើងដោយមានគំនិតយកចិត្តថ្នាក់លើ ហើយជាទូទៅ គាត់អាចបំពេញតាមការចង់បានរបស់ថ្នាក់លើគាត់។[៣៥៧] ជាងនេះទៅទៀត ឌុចបានសារភាពថា គាត់បានគិតគូរជាប្រចាំពីរបៀបបង្កើតតួនាទីរបស់ស-២១[៣៥៨] និងថា គាត់គិតខ្លួនគាត់ថាជាអ្នក"ស្មោះត្រង់ និង ស្ម័គ្រស្មោះណាស់"[៣៥៩] ទៅនឹងថ្នាក់លើរបស់គាត់៖ គាត់ប្តេជ្ញាធ្វើជាបុគ្គលម្នាក់ដែលបំពេញកិច្ចការឱ្យបានល្អ។[៣៦០] ប៉ុន្តែ ជាអកុសលសម្រាប់អ្នកទោស និង ក្រុមគ្រួសាររបស់ពួកគេ វាច្បាស់ណាស់ថា ឌុចមិនអាចបំពេញតាមការចង់បានរបស់ពួកគេទេ។[៣៦១]

១០៤. ប៉ុន្តែ ឌុចក៏បានអះអាងផងដែរថា គាត់មិនដែលចង់ធ្វើជាប្រធានស-២១ទេ និងថា គាត់មិនចូលចិត្តការងារនេះទេ។ ជាញឹកញាប់ គាត់បានរៀបរាប់អារម្មណ៍របស់គាត់ថា "អស់សង្ឃឹម"[៣៦២] ឬ "ធ្លាក់ទឹកចិត្ត"[៣៦៣] ដល់កម្រិតមួយដែលគាត់មិនអាចដើរបាន។[៣៦៤]ម្តងហើយម្តងទៀត ឌុចបានអះអាងថា មិនមានជម្រើសផ្សេងក្រៅពីអនុវត្តមាគ៌ានយោបាយបក្ស[៣៦៥] និងថា គាត់ធ្វើការនៅមន្ទីរស-២១

---

[៣៥៦] ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ២២។

[៣៥៧] ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ២២។

[៣៥៨] ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ២៤។

[៣៥៩] ប្រតិចារឹត ៨ មិថុនា ២០០៩ ទំព័រ ១០១-១០២។

[៣៦០] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ៧៩។

[៣៦១] ប្រតិចារឹត ៦ សីហា ២០០៩, ទំព័រ ២៣ (បណ្តឹតឆែនដ្លីរបានយល់ស្របថា ក្រោយការដឹកនាំរបស់ឌុច បណ្ណសារនៅស-២១ ត្រូវបានទុកដាក់តាមរបៀបមួយយ៉ាងល្អិតល្អន់ជាពិសេស)។

[៣៦២] ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ១៣។

[៣៦៣] ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ១៣។

[៣៦៤] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ៧១-៧២។

[៣៦៥] ប្រតិចារឹត ២ កញ្ញា ២០០៩ ទំព័រ ៧៣, ៧៧។

គឺដើម្បីចៀសវាងការចាប់ខ្លួន និង កម្ទេច ។[៣៦៦] ឌុចអះអាងថា គាត់បានព្យាយាមរកវិធីដើម្បីឱ្យបានចេញពីដំណែងនេះ ប៉ុន្តែមិនបានជោគជ័យ ។[៣៦៧] ដូច្នេះ វាច្បាស់ណាស់ថា ឥឡូវនេះពេលដែលគាត់ត្រូវគេកាត់ទោស ឌុចព្យាយាមធ្វើឱ្យគេមើលឃើញគាត់ថាជាប្រធានស-២១ដែលមិនគាត់មិនពេញចិត្តធ្វើទេ ហើយដែលកិច្ចការស-២១នេះបង្ខំឱ្យគាត់ចូលរួមនៅក្នុងប្រព័ន្ធគ្រប់គ្រងនេះ ជាជាងមើលឃើញថាគាត់ប្រកាន់យកគោលជំហរដែលកាន់នៅពេលនោះ ។[៣៦៨]

### ១. មិនមែនការងារតម្រូវឱ្យឌុចត្រូវតែធ្វើនោះទេ៖ ប៉ុន្តែ ឌុចជាអ្នកបង្កើតការងារនោះ

១០៥. ឌុចអះអាងថា គាត់មិនស្ម័គ្រចិត្តកាន់តំណែងជាប្រធានស-២១ទេ ។ ភស្តុតាងបានបង្ហាញឱ្យឃើញពីរូបភាពផ្ទុយពីនេះទៅវិញ ។ បើទោះបីជាគ្រប់គ្រងមន្ទីរឃុំឃាំងណាមួយក៏ដោយនៅក្នុងរបបខ្មែរក្រហមជាការងារគួរឱ្យរន្ធត់ ឌុចធ្វើការងាររន្ធត់នេះឱ្យកាន់តែសាហាវឃោរឃៅទៀត ដោយសារតែអត្តចរិករបស់គាត់ ។[៣៦៩] បណ្ឌិតអេចឆែស្សិនបានរៀបរាប់ថាឌុចជា "អ្នកកែច្នៃម្នាក់ ជាអ្នកច្នៃប្រឌិតម្នាក់ ជាអ្នកបង្កើតម្នាក់ និង ជាអ្នកកាន់ស្លាប័នម្នាក់..."នៃប្រព័ន្ធសួរចម្លើយ បង្កើតជាបញ្ជីជនក្បត់ បង្ហាញថាឌុចមានលក្ខណៈបែបនេះរួចហើយ តាំងពីមុនពេលក្លាយជាប្រធានមន្ទីរស-២១ម្ល៉េះ ។[៣៧០] ឌុចបានប្រើប្រាស់គោលគំនិត "ជនក្បត់" និង បង្កើតផែនការបោសសម្អាត តាំងពីពេលគាត់នៅជាប្រធានមន្ទីរម-១៣

---

[៣៦៦] ប្រតិចារឹត ២២ មិថុនា ២០០៩ ទំព័រ ៨៥ ។

[៣៦៧] ប្រតិចារឹត ២ កញ្ញា ២០០៩ ទំព័រ ៦៨-៦៩ ។

[៣៦៨] ប្រតិចារឹត ១ កក្កដា ២០០៩, ទំព័រ ៩១ (ឌុច៖ "ខ្ញុំចង់បញ្ជាក់ម្តងទៀតថា ឧក្រិដ្ឋកម្មនេះធ្ងន់ធ្ងរណាស់ បើទោះបីជាធ្វើឡើងដោយថ្នាកលើក៏ដោយ ។ ប៉ុន្តែ សមាជិកបក្សគឺជាផ្នែកមួយនៃដំណើការនេះនៅទូទាំងប្រទេស ដោយសារមនុស្សច្រើនជាងមួយលាននាក់ត្រូវគេសម្លាប់ ហើយខ្ញុំទទួលខុសត្រូវខាងផ្នែកស្មារតីចំពោះឧក្រិដ្ឋកម្មទាំងអស់ បើទោះបីជាប្រព្រឹត្តឡើងដោយថ្នាក់លើក៏ដោយ ។ ខ្ញុំទទួលខុសត្រូវចំពោះមុខច្បាប់ ហើយឥឡូវនេះ ខ្ញុំចង់ឱ្យអង្គជំនុំជម្រះកាត់ទោសខ្ញុំតែម្នាក់ឯង ហើយខ្ញុំមិនចង់ឱ្យថ្នាក់ក្រោមបង្គាប់ត្រូវកាត់ទោសដែរនោះទេ") ។

[៣៦៩] របាយការណ៍ចិត្តសាស្ត្រ ទំព័រ ៣៣ ("ឌុចធ្វើការនៅក្នុងប្រព័ន្ធដែលមានជម្រើសតែពីរ ។ នេះមានន័យថា សម្រាប់គាត់ អ្នកមានតែ "ស្របតាម" ឬ "ប្រឆាំង") ។ សូមមើលផងដែរនូវ ប្រតិចារឹត ៨ មេសា ២០០៩ ទំព័រ១០០ (ហ្វ្រង់ស្វ័រ ប៊ីហ្សូ៖ "ការចងចាំ ដែលខ្ញុំចាំបានពីមនុស្សវ័យជំទង់ដែលបូជាជីវិតដើម្បីបុព្វហេតុមួយ និង គោលបំណងមួយដែលមានមូលដ្ឋានគំនិតដែលថា បទល្មើសមិនត្រឹមតែជារឿងស្របច្បាប់ទេ ថែមទាំងសមតែប្រព្រឹត្តទៀតផង") ។

[៣៧០] ប្រតិចារឹត ២៨ ឧសភា ២០០៩ ទំព័រ៩១ ។

ក្នុងឆ្នាំ១៩៧២។[៣៧១] ប្រតិបត្តិការណ៍ស-២១របស់ឌុចត្រូវបានបង្កើតរួចទៅហើយ ។[៣៧២] ឌុចមិនត្រឹមតែមានបទពិសោធន៍ទេ ថែមទាំងមានមោទនភាពថែមទៀតអំពីជោគជ័យរបស់គាត់ក្នុងនាមជាអ្នករៀបចំម៉ាស៊ីនសួរចម្លើយយ៉ាងមានប្រសិទ្ធិភាព ។[៣៧៣] ឌុចទទួលបានជោគជ័យក្នុងការដោះស្រាយបញ្ហា និងទទួលបានតំណែងជា "ប្រធាន" ដើម្បីឱ្យត្រូវទៅតាមគំនិតរបស់គាត់ ពោលគឺម៉ាស៊ីនគ្រោះថ្នាក់មួយដែលបង្កើតនូវចំនួនអតិបរមានៃ "ជនក្បត់ និង ខ្មាំង" ។

## ២. ឌុចជាមនុស្សជឿខុបហួសហេតុនៅលើមនោគមន៍វិជ្ជាខ្មែរក្រហម

១០៦. ចំណង់ និង ជំនឿរបស់ឌុចទៅលើមនោគមន៍វិជ្ជាជ្រុលនិយមរបស់ខ្មែរក្រហមកើតឡើងតាំងពីយូរមុនពេលដែលខ្មែរក្រហមកាន់អំណាច និង ស្ថិតនៅយូរទៀតក្រោយពេលរបបខ្មែរក្រហមដួលរលំ ។[៣៧៤] ឌុចបានចូលរួមយ៉ាងជ្រៅរួចហើយ ពេលដែលគាត់ធ្វើជាប្រធានមន្ទីរម-១៣ ។[៣៧៥] ដោយសារតែនៅមន្ទីរម-១៣នេះឯង ដែលឌុចបានរកឃើញបំណងប្រាថ្នាពិតប្រាកដ និង លក្ខណៈសម្បត្តិរបស់គាត់ ដែលធ្វើឱ្យគាត់ក្លាយជាប្រធានមន្ទីរស-២១[៣៧៦] និង ចុងក្រោយបំផុត ព្រមទទួលអនុវត្ត

---

[៣៧១] សម្លេងពីមន្ទីរស-២១, ទំព័រ ២១-២២ ។

[៣៧២] សម្លេងពីមន្ទីរស-២១, ទំព័រ ២១-២២ ។ សូមមើលផងដែរ របាយការណ៍ចិត្តសាស្ត្រ, ទំព័រ៣៣ ("ជាឧទាហរណ៍ គាត់បានបង្ហំឱ្យបីហ្ស៊ូសរសេរប្រវត្តិរូបមួយចំនួនរហូតដល់ការពិតជាក់ស្តែង "ត្រូវគ្នានឹង" គោលការណ៍ ឬ "មនោគមវិជ្ជា" ។ គាត់ចាត់ទុកភាពប្លែក, ភាពមិនដូចគ្នា, លក្ខណៈពិសេស, ភាពទីទៃគ្នា និង ពហុភាព ជាការគម្រាមកំហែងដល់គុណភាពគំនិតរបស់គាត់ ។ សម្រាប់គាត់ ជនកម្ពុជាដែលមានការយល់ឃើញខុសពីគាត់គឺជាជនក្បត់, មនុស្សកុហក") ។

[៣៧៣] ប្រតិចារឹក ២៧ មេសា ២០០៩, ទំព័រ៩១ (ឌុច: "ទីមួយ ខ្ញុំគ្រាន់បើជាងណាគេខាងសួរចម្លើយ ។ ខ្ញុំបង្រៀនមនុស្សឱ្យសួរចម្លើយ ។ ខ្ញុំធ្វើការគ្រាន់បើជាង ។ នេះជាការពិត ។ ខ្ញុំមិនប្រកែកទេ") ។

[៣៧៤] ប្រតិចារឹក ២ កញ្ញា ២០០៩, ទំព័រ៨២ (នៅពេលសួរអំពីមូលហេតុដែលឌុចចាកចេញពីបក្សទាល់តែនៅច្រើនឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ចម្លើយរបស់គាត់បង្ហាញពីហេតុផលនៃជម្រើសរបស់គាត់នៅក្នុងជីវិត: "ដាក់ជើងក្រោយឱ្យស៊ុបសិន សឹមលើកជើងមួយទៀត ឈានទៅមុខ ។ ដូច្នេះ ដើម្បីនឹងចេញកើត វាទាល់តែមានលក្ខណៈសត្យានុម័តដែលអាចឱ្យយើងចេញបាន" ។

[៣៧៥] ប្រតិចារឹក ៦ មេសា ២០០៩ ទំព័រ ២០ ។ ឌុច ការិយាល័យសហចៅក្រមស៊ើប, ឯកសារយកចម្លើយជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ, Procès-verbal d'interrogatoire, ២៩ មេសា ២០០៨, ឯកសារលេខ D70, ទំព័រ៣ ។

[៣៧៦] ប្រតិចារឹក ១៨ ឧសភា ២០០៩ ទំព័រ ៥១, ៨៣ ។

សូម្បីតែគោលនយោបាយឃោរឃៅបំផុតរបស់ខ្មែរក្រហម ពោលគឺការកម្ទេចកូនង៉ា និង ក្មេងៗ។[៣៧៧] ឌុចបន្តអប់រំបុគ្គលិកថែមទៀតនូវអ្វីដែលគាត់ទទួលបានបទពិសោធន៍ពីការដឹកនាំនៅម-១៣ ពោលគឺ បង្រៀនអ្នកសួរចម្លើយឃោរឃៅ និង មានប្រសិទ្ធិភាព។[៣៧៨]

១០៧. ជំនឿយ៉ាងជ្រាលជ្រៅមិនអាចប្រកែកបានទៅក្នុងបដិវត្តខ្មែរក្រហម គឺជាកត្តាសំខាន់បញ្ជាក់ពីសកម្មភាពទីមួយៗដែលគាត់ធ្វើ។[៣៧៩] ឌុចគោរពបញ្ជាតាមរបៀបជ្រុលនិយមមួយ ដោយសារអត្តចរិករបស់គាត់ចូលចិត្តភាពឥតខ្ចោះ និង ដោយសារគាត់ពិតជាជឿជាក់ក្នុងបុព្វហេតុនោះមែន។[៣៨០] ឌុចមិនមែនក្លាយជាប្រធានស-២១ដោយមិនស្ម័គ្រចិត្ត ឬដោយសារគាត់ភ័យខ្លាចនោះទេ។[៣៨១] ឌុចជាអ្នកប្រកាន់គំនិតដាច់ខាតពិតប្រាកដម្នាក់។

១០៨. តាមពិត សេចក្ដីសន្និដ្ឋានរបស់ចិត្តវិទូនៅក្នុងរបាយការណ៍វាយតម្លៃឌុចមុនពេលជំនុំជម្រះចង្អុលបង្ហាញថា ឌុចអាចដើរតួនាទីសំខាន់មានប្រសិទ្ធិភាពជាប្រធានមន្ទីរស-២១ ដោយសារតែគាត់ខ្វះខាតការយល់ចិត្តអ្នកដទៃ នេះជាអត្តចរិកមួយដែលចិត្តវិទូរកឃើញថាមានតាំងពីមុនពេលគាត់គ្រប់គ្រងនៅស-២១ម្លេះ។[៣៨២] សូម្បីតែ៣០ឆ្នាំក្រោយក៏ដោយ ឌុចជួនកាលត្រឡប់ទៅប្រើប្រាស់ការគិត

---

[៣៧៧] ប្រតិចារឹក ៨ មិថុនា ២០០៩ ទំព័រ ១៩-២០។

[៣៧៨] ប្រតិចារឹក ២៧ មេសា ២០០៩ ទំព័រ ៩០ (ឌុច: "លក្ខណៈដែលស-២១បន្តអនុវត្តពីម-១៣ និង ការអប់រំ និង បង្រៀនយុទ្ធជន តាមទិសដៅឧក្រិដ្ឋកម្ម និង ភាពសាហាវឃោរឃៅ វាមានលក្ខណៈដូចគ្នា។ ទីពីរ វិធីសួរចម្លើយដោយប្រើទារុណកម្ម និង ការព្យាយាមបញ្ចុះបញ្ចូលពួកគេ និង ចូលចិត្តពួកគេ គឺជាការអនុវត្តបន្តពីម-១៣")។

[៣៧៩] របាយការណ៍ចិត្តសាស្ត្រ, ទំព័រ ៦៥ ("[ឌុច] ជ្រើសយកជម្រើសដែលគាត់សម្រេចយក ដោយសារគាត់គិតថាជារឿងត្រឹមត្រូវនៅពេលនោះ។ គាត់ជឿយ៉ាងស៊ុបទៅក្នុងទស្សនៈវិជ្ជានៅពីក្រោយរបបកុម្មុយនិស្ត។ គាត់បន្តជឿជាក់ក្នុងរបបកុម្មុយនិស្តអស់រយៈពេលយូរគួរសម រួមទាំងពេលគាត់នៅជាប្រធានមន្ទីរស-២១ផង")។

[៣៨០] របាយការណ៍ចិត្តសាស្ត្រ, ទំព័រ ៣០, ៣២ ("... ជម្រើសដែលគាត់ជ្រើសរើសគឺជាជម្រើសដែលគាត់គិតថាត្រឹមត្រូវនៅពេលនោះ។ គាត់ជាអ្នកចូលរួមស្ម័គ្រចិត្តម្នាក់។ បើទោះបីជាគាត់ជាមនុស្សមានឥទ្ធិពល និង ងាយទទួលរងឥទ្ធិពលក៏ដោយ គាត់ព្រមទទួលយកវិធានជាមូលដ្ឋាននៃប្រព័ន្ធមនោគមន៍វិជ្ជាដែលគាត់ធ្វើការជាមួយ.... ការគោរពតាមបញ្ជាមិនមែនជាហេតុផលនៃសកម្មភាពរបស់គាត់ទេ ប៉ុន្តែជាផលវិបាកចេញពីនោះមក...")។

[៣៨១] របាយការណ៍ចិត្តសាស្ត្រ, ទំព័រ ៦៤។

[៣៨២] របាយការណ៍ចិត្តសាស្ត្រ, ទំព័រ ៤៩ ("ការវិភាគផ្នែកចិត្តសាស្ត្រលើអត្តចរិតរបស់ឌុចបង្ហាញឱ្យឃើញពីវត្តមាននៃ "ការខ្វះខាតការយល់ចិត្តអ្នកដទៃ"។ ការខ្វះខាតការយល់ចិត្តអ្នកដទៃនេះមានតាំងពីមុនដំណើរ "បោកបញ្ឆោត" របស់ខ្មែរក្រហម និង "ការចូលប្រឡូក" ក្នុងវប្បធម៌នេះម្លេះ។ ដំណើការបោកបញ្ឆោតនេះបង្ករជាអត្តចរិត និង ធ្វើឱ្យប៉ះពាល់ដល់

តាមរបៀបខ្មែរក្រហម និង ប្រើពាក្យតាមរបៀបខ្មែរក្រហម នៅពេលនិយាយជាមួយអ្នកចិត្តសាស្ត្រ ជំនាញអំពីរបបកម្ពុជាប្រជាធិបតេយ្យ។[៣៨៣]

## ៣. ឌុចស្រឡាញ់ការងារជាប្រធានស-២១ និង អំណាចនេះ

១០៩. មិនមានភស្តុតាងណាមួយលេចឡើងនៅពេលសវនាការដែលគាំទ្រដល់ការអះអាងរបស់ឌុចដែលថា គាត់ស្អប់កិច្ចការជាប្រធានស-២១ទេ ឬថា គាត់ឈឺចាប់ជាសម្ងាត់ដោយសារការងារនេះ។[៣៨៤] ឌុចខ្លួនឯងបានអះអាងថា គាត់យល់ស្របអស់ពីចិត្តពីថ្លើមជាមួយគោលនយោបាយខ្មែរក្រហមដែលថា ខ្មាំងទាំងអស់ឃុំនៅស-២១ ត្រូវកម្ទេចចោល។[៣៨៥] ឌុចថែមទាំងមិនបាននឹកដល់ថា គាត់គួរតែលើក

---

ភាពមិនយល់ចិត្តអ្នកដទៃរបស់គាត់។ ទោះយ៉ាងណាក៏ដោយ នេះគ្រាន់តែបន្ថែមទៅលើផ្លូវចិត្តរបស់គាត់ដែលកើតមានមុនពេលចូលរួមដំណើការបោកបញ្ឆោតនេះប៉ុណ្ណោះ")។

[៣៨៣] របាយការណ៍ចិត្តសាស្ត្រ, ទំព័រ ៤៤ ("នៅក្នុងដំណាក់កាលស៊ើបអង្កេតនេះ គាត់ត្រឡប់ទៅប្រើប្រាស់គំនិតតាមរបៀបខ្មែរក្រហម ដែលតាមរយៈនោះ គាត់បានវិភាគចម្លើយសារភាពយ៉ាងល្អិតល្អន់ ដឹកនាំការសួរចម្លើយខ្លះ និង ផ្តល់ការណែនាំដល់អ្នកក្រោមបង្គាប់។ គំនិតរបស់គាត់គឺរៀបចំតាមឡូហ្សិកនៃការសួរចម្លើយ...")។ សូមមើលផងដែរ របាយការណ៍ចិត្តសាស្ត្រ, ទំព័រ៩២ដែរ។

[៣៨៤] ប្រតិចារឹត ១ កក្កដា ២០០៩, ទំព័រ ៣៧-៣៨ (នេះមិនមែនជាអ្វីដែលសាក្សីផ្តល់សក្ខីកម្មបាននិយាយនោះទេ។ ឧទាហរណ៍ ប៊ូ ម៉េង ផ្តល់សក្ខីកម្មថា "...ទឹកមុខធម្មតា។ ប្រសិនបើគាត់ចង់សើច គាត់សើច។ ជួនកាល គាត់ញញឹម...")។ ប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ ៦៤-៦៥ (បណ្ឌិតឆែនឡឺរ: "ខ្ញុំមិនបានឃើញនៅក្នុងឯកសារជាភស្តុតាងទេ ដែលបញ្ជាក់ថា គាត់មានវិប្បដិសារីខ្លាំង សោកស្តាយខ្លាំង ដោយគាត់ដឹងពីអំពើកំហុសរៀងរាល់ថ្ងៃ ពីមួយថ្ងៃទៅមួយថ្ងៃក្នុងកាលនោះ។ អញ្ចឹងហើយយើងមើលឃើញថា គឺជាភាពលើសលប់ដែលបានធ្វើចំពោះគ្រប់ចម្លើយសារភាពមួយចំនួននោះ និង តាមរយៈសក្ខីកម្មរបស់អ្នករួចរស់ជីវិត")។ ប្រតិចារឹត ៨ មិថុនា ២០០៩ ទំព័រ ២០ (ឌុចគ្រាន់តែនិយាយថា ជួនកាល គាត់មានអារម្មណ៍"ទុក្ខសោក")។

[៣៨៥] ប្រតិចារឹត ៨ មិថុនា ២០០៩ ទំព័រ ៦ (ឌុច: "ដូច្នេះ ខ្ញុំទទួលបញ្ជាឱ្យដោះលែងតែមនុស្សបីនាក់នេះ ហើយអ្នកផ្សេងទៀតត្រូវតែកម្ទេច។ នោះគឺជាគោលនយោបាយបក្សកុម្មុយនិស្តកម្ពុជាអនុវត្តនៅស-២១... [ប៉ុល ពត] និយាយថា ស-២១មិនត្រូវការសួរសំណួរច្រើនទេ។ មនុស្សបញ្ជូនមកឱ្យឌុចឯង ឌុចឯងត្រូវតែទុកពួកគេ។ ដូច្នេះ ខ្ញុំសប្បាយចិត្ត។ ខ្ញុំគិតថា "អូហ៎! វាជាការល្អសម្រាប់ស-២១"។ ហើយខ្ញុំមិននិយាយថា វាជាគ្រោះថ្នាក់ ឬ ជាឧក្រិដ្ឋកម្មនៅក្នុងការសម្លាប់អ្នកទាំងនោះទេ")។

លែងឱ្យអ្នកទោសចុងក្រោយនៅស-២១ នៅពេលនាំគ្នាចាកចេញពីមន្ទីរឃុំឃាំង។ ប៉ុន្តែ គាត់បានកម្ទេចអ្នកទាំងអស់នោះចោល នៅពេលវេលាចុងក្រោយនោះ។[៣៨៦]

១១០. បើទោះបីជាឌុចបានអះអាងថាបានបាត់បង់នូវការប្ដេជ្ញាចិត្តនៅក្នុងឆ្នាំ១៩៧៨ ដោយគាត់ដេកច្រើននៅពេលនោះក៏ដោយ ភស្តុតាងបង្ហាញនូវព្រឹត្តការណ៍ផ្ទុយពីនេះទៅវិញ។ ឌុចសកម្មយ៉ាងខ្លាំងនៅក្នុងឆ្នាំ១៩៧៨ ផ្ដល់វគ្គបង្រៀនយ៉ាងច្រើនដល់អ្នកសួរចម្លើយឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដើម្បីបំពេញតាមសេចក្ដីត្រូវការរបស់បក្ស។[៣៨៧] ពេលនោះគឺនៅឆ្នាំ១៩៧៨ មិនមែនមុនឆ្នាំនោះទេ ដែលកាលនោះ ឌុច តាមរយៈខ្លួនគាត់ផ្ទាល់ ឬ តាមរយៈអ្នកក្រោមបង្គាប់របស់គាត់ ប៉ុន[៣៨៨] បានសរសេរ "ផែនការចុងក្រោយ" ហើយតាមរយៈបណ្ឌិតឆៃនដ្ឋ័រ ផែនការណ៍ចុងក្រោយនេះជា"ស្នាដៃឯក"របស់ឌុចពោលគឺ"ការព្យាយាមរបស់គាត់ក្នុងការសរុបបញ្ចូលគ្នានូវអ្វីដែលគាត់បានឃើញ និង បានបកស្រាយថាជាភស្តុតាង .... ដែលជាការបកស្រាយពិតសមរម្យចំពោះទិន្នន័យគាត់មាន"។[៣៨៩]

១១១. ឌុចបានឡើងជាប្រធានស-២១ ជាពិសេសដោយសារតែគាត់ចង់។ គាត់ជឿជាក់ចំពោះអ្វីដែលគាត់បានធ្វើ និង ឧត្ដមគតិដែលខ្មែរក្រហមបានផ្សព្វផ្សាយ ធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីផ្គាប់ចិត្តថ្នាក់ដឹកនាំខាងលើ។[៣៩០] ហួសពីការចង់ផ្គាប់ចិត្តថ្នាក់លើទៅទៀតនោះ ឌុចចង់ធ្វើឱ្យជំនឿបដិវត្តរបស់គាត់ទៅជាការពិត បើទោះបីជាគាត់យល់យ៉ាងច្បាស់តាំងពីពេលចាប់ផ្ដើមនៅម-១៣ម្លេះថា "ការសម្លាប់មនុស្ស

---

[៣៨៦] ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ១២ (ឌុចៈ "ហើយចំណុចទីពីរ ចំពោះអ្នកទោសនៅសល់ដែលខ្ញុំទទួលបញ្ជាឱ្យកម្ទេច បញ្ជានោះនៅថ្ងៃទី២ ហើយថាខ្ញុំត្រូវតែកម្ទេច បញ្ជានោះចេញនៅ ថ្ងៃទី២ ឬ យ៉ាងយូរបំផុតថ្ងៃទី៣ ខែមករា ហើយនៅសល់អ្នកទោសតែបួននាក់ប៉ុណ្ណោះដែលត្រូវសួរ និង ខ្ញុំគិតថា អ្នកទោស ប្រហែល១៤ ឬ ១៥នាក់ដែលទុកឱ្យនៅរស់ដោយសារបានផ្ដល់ជាសេវាបម្រើដល់ស-២១។ ដូច្នេះ មានបុគ្គលិកតែប្រមាណ៣នាក់ប៉ុណ្ណោះដែលរត់គេចជាមួយខ្ញុំពេលខ្ញុំរត់។ នេះជាហេតុការណ៍នៅពេលនោះ។ ខ្ញុំមិនគិតថា កម្ពុជាប្រជាធិបតេយ្យចាញ់នោះទេ និងថា អ្នកទោសនៅសល់ត្រូវតែដោះលែង ដើម្បីឱ្យសមតាមអារម្មណ៍ ឬ ស្មារតីរបស់ខ្ញុំ។ នេះជាចម្លើយរបស់ខ្ញុំ")។

[៣៨៧] ប្រតិចារឹត ៨ មិថុនា ២០០៩ ទំព័រ ៥៤, ៧៧ (ឌុចមានអារម្មណ៍ល្អហោស់នៅពេលជួបជាមួយ ប៉ុល ពត ពេលបង្រៀន)។

[៣៨៨] ប្រតិចារឹត ៦ មិថុនា ២០០៩ ទំព័រ ១១៤-១១៥។

[៣៨៩] ប្រតិចារឹត ៦ មិថុនា ២០០៩ ទំព័រ ៨៨។

[៣៩០] ប្រតិចារឹត ២៧ មេសា ២០០៩ ទំព័រ ៩១។ សូមមើលប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ៥០ (បណ្ឌិតឆៃនដ្ឋ័រៈ "ចំណេះជាលាយលក្ខណ៍អក្សរពណ៌ក្រហម...បង្ហាញឱ្យឃើញពីអ្វីដែលមិនអាចរៀបរាប់ក្រៅពីការបំពេញការងារវិជ្ជាជីវៈល្អ")។

E159/7

គ្មានហេតុផលគឺជាឧក្រិដ្ឋកម្ម"។[៣៩១] ឌុចគោរពតាមមាគ៌ាបក្សយ៉ាងខ្ជាប់ខ្ជួន ហើយគាត់គ្មានបញ្ហាលំបាកក្នុងការបរិហារអ្នកជាការគម្រាមកំហែងដល់បដិវត្តទេ។[៣៩២]

១១២. បណ្ឌិតឆែនដ្ល័របានពន្យល់ថា វាច្បាស់ណាស់ថា ឌុចជឿជាក់ចំពោះអ្វីដែលគាត់បានធ្វើ និងដឹងថា នោះជាអ្វីដែលគាត់ចង់ធ្វើ "គាត់មិនត្រឹមតែអនុវត្តនូវអ្វីដែលគាត់ព្រមទទួលធ្វើនោះទេ ប៉ុន្តែ គាត់ធ្វើអ្វីដែលគាត់ចង់ធ្វើ"។ ទាំងនេះគឺជូនគ្នា ដោយសារថា អ្នកឯងមិនមែនឯករាជ្យម្ចាស់ការពីបក្សទេ។ អ្នកឯង និង បក្ស គឺជាកម្លាំងតែមួយ"។[៣៩៣] ជំនឿនយោបាយជ្រុលនិយមនេះហើយធ្វើឱ្យឌុចបង្រៀនប្រាប់បុគ្គលិករបស់គាត់ថា ខ្មែរក្រហម"គួរតែសម្លាប់ទាំងអស់ ទុកតែមនុស្ស៤លាននាក់"[៣៩៤] និងថា "គ្រប់គ្នានឹងត្រូវកម្ទេច ឬ សម្លាប់"។[៣៩៥] ដើម្បីសម្រួលដល់មាគ៌ាជ្រុលនិយមរបស់បក្សនេះ ឌុចនឹងបង្រៀនអ្នកក្រោមបង្គាប់ឱ្យ"ប្រើអាវុធឱ្យបានញឹកញាប់ ដើម្បីឱ្យវាមុត"។[៣៩៦] ឌុចធានាថា ការបង្រៀន

---

[៣៩១] ប្រតិចារឹក ២ កញ្ញា ២០០៩ ទំព័រ ៦៧-៦៨។

[៣៩២] ជាឧទាហរណ៍ សូមមើល ប្រតិចារឹក ១៥ កក្កដា ២០០៩ ទំព័រ ៤៨-៤៩ (ម៉ម ណៃៈ "វាដូចជាឆាយ គឹមហួ ហៅ ហុក ដែលនិយាយថា ប្រេងអាមេរិកល្អជាងប្រេងចិន។ ឌុចបាននិយាយប្រាប់ខ្ញុំថា គាត់បានរាយការណ៍ទៅគណៈកម្មាធិការមជ្ឈិម (...) ឌុចបានទៅលេងផ្ទះរបស់ហុក។ ហុកមានសេចក្តីក្លាហាន និយាយយ៉ាងស្មោះត្រង់ជាមួយអ្នកស្គាល់គាត់។ ឌុចរហ័សរាយការណ៍ណាស់ ដូចនៅក្នុងករណីរបស់ខ្ញុំ នៅពេលកម្មាភិបាលវរសេនាធំម្នាក់បានចង្អុលដាក់ខ្ញុំថា ខ្ញុំធ្លាប់ទៅលេងផ្ទះឪពុកមារបស់គាត់ និងថា ឪពុកមាគាត់បានចោទថាខ្ញុំជាខ្មែរសេរី។ គ្រាន់តែប៉ុណ្ណោះ ឌុចចង់រាយការណ៍ទៅមជ្ឈិមបក្ស។ ឌុចរហ័សរាយការណ៍ណាស់")។

[៣៩៣] ប្រតិចារឹក ៦ សីហា ២០០៩ ទំព័រ ១០៩។

[៣៩៤] ប្រតិចារឹក ២០ កក្កដា ២០០៩ ទំព័រ ៣៣។ សូមមើល ប្រតិចារឹក ៦ សីហា ២០០៩ ទំព័រ ៦១ (ហ៊ឹម ហ៊ុយៈ "ឌុចនិយាយថា ត្រូវសម្លាប់ចោលទាំងអស់ ទុកតែមនុស្ស៤លាននាក់ទេ ហើយក្រោយមក គាត់និយាយថា គ្រប់គ្នាត្រូវតែកម្ទេចទាំងអស់។ ហើយពាក្យនេះ ខ្ញុំនឹងចាំជារៀងរហូត")។ ប្រតិចារឹក ៦ សីហា ២០០៩ ទំព័រ ៩១។ ប្រតិចារឹក ១០ កក្កដា ២០០៩ ទំព័រ ៣៤-៣៥ (ការបូជាស្មោះស្ម័គ្រជ្រុលហួសហេតុដូចគ្នានេះឯងដែលនាំឌុចប្រើប្រាស់វិធានការណ៍តឹងរឹងបំផុតចំពោះបុគ្គលិកនៅស-២១)។

[៣៩៥] សូមមើល ប្រតិចារឹក ២០ កក្កដា ២០០៩, ទំព័រ ៦១ (ហ៊ឹម ហ៊ុយ ពន្យល់ថា គាត់បានបកស្រាយការណែនាំរបស់ឌុចថាមានន័យថា មនុស្សទាំងអស់ត្រូវតែសម្លាប់ មិនមែនត្រឹមតែអ្នកនៅស-២១នោះទេ)។

[៣៩៦] ប្រតិចារឹក ៨ មិថុនា ២០០៩ ទំព័រ ៤៦, ៥០, ១០ (ឌុចៈ "ដូច្នេះ យើងត្រូវដុះខាត់គោលជំហរជាប្រចាំ ហើយសម្រាប់អង្គភាពពិសេស មានប្រធានក្រុមជាអ្នកដុះខាត់គោលជំហរហ្នឹង។ នោះជាគោលការណ៍ធម្មតាក្នុងការបំពេញការងារ")។

E159/7

បុគ្គលិករបស់គាត់គឺរៀបចំដើម្បីធានាថា អ្នកសួរចម្លើយធ្វើការបានរហ័ស និង មានប្រសិទ្ធិភាពតាមដែលអាចធ្វើទៅបាន តាមរបៀបមួយដែលគាត់ហៅថា វិធី "វាយរហ័ស/ជោគជ័យរហ័ស" ។[៣៩៧]

១១៣. មិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលឌុចជាសមាជិកខ្មែរក្រហមម្នាក់ក្នុងចំណោមមនុស្សតិចតួចបំផុតដែលអាចថែរក្សាតំណែងជាថ្នាក់ដឹកនាំនៅមន្ទីរឃុំឃាំងអស់រយៈពេល៨ឆ្នាំ ដោយមិនត្រូវបានបោសសម្អាត ។[៣៩៨] គាត់ក៏ជាមនុស្សម្នាក់នៅក្នុងចំណោមអ្នកមានបុព្វសិទ្ធិពិសេសមួយចំនួនតូចដែលត្រូវគេចង្អុលដាក់នៅក្នុងចម្លើយសារភាពនៅស-២១ដែរ[៣៩៩] ហើយក៏មានសមាជិកគ្រួសារត្រូវនាំមកមន្ទីរស-២១ ឬមន្ទីរឃុំឃាំងផ្សេងទៀត ដោយមិនត្រូវបានចាប់ខ្លួន ឬត្រូវជាប់ជំពាក់ ។[៤០០] នេះជាគោលជំហរមួយដែលផ្ទុយទៅនឹងមាតិាបក្ស ។

## ៤. ឌុចនឹងធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីថែរក្សាអំណាច និង បុព្វសិទ្ធិ

១១៤. ឌុចព្រមទទួលយកតំណែងរបស់គាត់ និង បំពេញការងារពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដោយសារមូលហេតុពីរយ៉ាង: (១) ថែរក្សាអំណាច និង (២) ថែរក្សាបុព្វសិទ្ធិដែលទទួលបានពីតំណែងនោះ ដូចជាឡានហ្ស៊ីប និង ម៉ូតូ,[៤០១] និរសា និង ស្បៀង,[៤០២] ផ្ទះពីរជាន់ និង ការិយាល័យឯកជន,[៤០៣] និង ទូរស័ព្ទពីរខ្សែ ។[៤០៤] ដើម្បីថែរក្សាអំណាចរបស់គាត់ ឌុច ជាលក្ខណៈប្រព័ន្ធ និង យ៉ាងឃោរឃៅ បានកម្ចាត់

---

[៣៩៧] សូមមើល ប្រតិចារឹក ៨ មិថុនា ២០០៩, ទំព័រ ៥០, ៥២ ។ ប្រតិចារឹក ២៣ មិថុនា ២០០៩ ទំព័រ ២៤ ។

[៣៩៨] ប្រតិចារឹក ២៨ ឧសភា ២០០៩ ទំព័រ ៣៦ ។

[៣៩៩] ប្រតិចារឹក ២៣ មិថុនា ២០០៩ ទំព័រ ២៥-២៦ (ជនជាប់ចោទបាននិយាយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា វ៉ន វ៉េត និង កែ គឹមហួត បានចង្អុលឈ្មោះគាត់នៅក្នុងចម្លើយសារភាពរបស់ពួកគេនៅស-២១ ។ នៅក្នុងតុលាការ ឌុចបានយល់ស្របថា វ៉ន វ៉េត ពិតជាបានចង្អុលឈ្មោះគាត់មែន និង បាននិយាយថា គាត់នៅរស់ជីវិតដោយសារតែគាត់ "ស្មោះត្រង់ និង ស្មោះត្រង់ "ចំពោះថ្នាក់ដឹកនាំកំពូល) ។

[៤០០] ប្រតិចារឹក ២ កញ្ញា ២០០៩ ទំព័រ ៧០-៧១ ។

[៤០១] ប្រតិចារឹក ២ កញ្ញា ២០០៩ ទំព័រ ៤៨ ។

[៤០២] សូមមើល ប្រតិចារឹក ២ កញ្ញា ២០០៩ ទំព័រ ៤៩ ។

[៤០៣] សូមមើល ប្រតិចារឹក ២ កញ្ញា ២០០៩ ទំព័រ ៥១ ។

[៤០៤] សូមមើល ប្រតិចារឹក ២ កញ្ញា ២០០៩ ទំព័រ ៥១ ។

អ្នកដែលបង្កជាការគម្រាមកំហែងចំពោះគាត់៖ កងពល៧០៣។[៤០៥] ប្រាក់ ខន អះអាងបញ្ជាក់ពីអ្វីដែលគាត់បាននិយាយនៅចំពោះមុខសហចៅក្រមស៊ើប ពោលគឺថា គាត់សង្ស័យថា ឌុចចង់សម្លាប់សមាជិក ៧០៣ទាំងអស់ ដោយខ្លាចបាត់បង់តំណែងរបស់គាត់ជាប្រធានស-២១។[៤០៦] ឌុចមិនបានបញ្ឈប់ត្រឹម ៧០៣ទេ៖ បន្ទាប់ពីកម្ទេចជិតអស់មនុស្សទាំងនេះនៅស-២១មក ឌុចតាមចាប់ហ៊ ដែលជាថ្នាក់លើរបស់ពួកគេទៀត ពេលរត់ពីភ្នំពេញនៅក្នុងឆ្នាំ១៩៧៩។ បើយោងតាមប្រាក់ ខន និង ហ៊ឹម ហ៊ុយ ឌុច ធ្វើដោយផ្ទាល់ ឬតាមរយៈអ្នកក្រោមបង្គាប់ បានបាញ់ហ៊ពេលរត់ទៅអមលាំង នៅពេលវៀតណាមចូលមកដល់។[៤០៧] ប៉ុន្តែ ឌុចបានធានាថា មនុស្ស "របស់គាត់" មិនត្រូវបានបោសសម្អាតនៅស-២១ទេ។

១១៥. ឥរិយាបថនេះប្រាកដជាមិនមែនជាឥរិយាបថរបស់អ្នកដែលស្អប់កិច្ចការរបស់ខ្លួន ដែលស្អប់ខ្ពើមគោលនយោបាយកំពុងអនុវត្ត និងដែលគ្រាន់តែគោរពតាមបញ្ជាជ្រុលហួសហេតុ និង ចង់បំពេញការងារ។ ផ្ទុយទៅវិញ នេះជាសកម្មភាពរបស់អ្នកប្រកាន់គំនិតដាច់ខាត ដែលជឿជាក់ទាំងស្រុងទៅលើបដិវត្ត និង សុខចិត្តធ្វើសកម្មភាពយ៉ាងមុះមុតដើម្បីធានាអំណាច និង បុព្វសិទ្ធិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

---

[៤០៥] ប្រតិចារឹក ១៦ កក្កដា ២០០៩ ទំព័រ ៩៣-៩៤ (ហ៊ឹម ហ៊ុយ៖ "ខ្ញុំដឹងរឿងនេះពីតាហ៊។ តាហ៊ប្រាប់ខ្ញុំថា គាត់ប៉ះសំដីជាមួយឌុចបីដងចំពោះមនុស្សរបស់គាត់ ព្រោះគាត់និយាយថា គាត់គាំទ្រ៧០៣ ប៉ុន្តែឌុចអត់គាំទ្រ... ការប៉ះគ្នានេះចាប់ផ្តើមមុនពេលបុគ្គលិកស-២១ត្រូវចាប់ខ្លួន... មូលហេតុដែលខ្ញុំនិយាយនេះ ដោយសារតាហ៊និយាយថា ឌុចចោទគាត់លម្អៀងចំពោះកម្លាំង៧០៣នៅស-២១។ ក្រោយមក មនុស្ស៧០៣ត្រូវចាប់ខ្លួន និង ចង្អុលទៅមនុស្ស៧០៣ផ្សេងទៀតដែលធ្វើការនៅស-២១។ បន្ទាប់មក មនុស្ស៧០៣នៅទួលស្លែងត្រូវចាប់ខ្លួនជាបន្តបន្ទាប់... ខ្ញុំមិនដឹងថា ពួកគេត្រូវធ្វើបាបយ៉ាងម៉េចទេ។ អ្វីដែលខ្ញុំដឹងគឺថា មនុស្សបាត់ខ្លួនជាបន្តបន្ទាប់ ហើយខ្ញុំមិនដឹងមានរឿងអ្វីកើតឡើងចំពោះពួកគេទេ មូលហេតុដែលត្រូវចាប់ខ្លួន។") ។ (បន្ថែមការសង្កត់សម្លេង)។ សូមមើលផងដែរ ប្រតិចារឹត ២១ កក្កដា ២០០៩ ទំព័រ៣៦ (ប្រាក់ ខន៖ "នៅខាងក្រៅ អត់មានការបែកបាក់អីធំដុំទេ ប៉ុន្តែ ក្រោយមក មានការចាប់ខ្លួនអ្នកតំណែងធំៗនៅក្នុងកងពល ហើយនៅក្នុងក្រុមសួរចម្លើយរបស់ខ្ញុំ មានតែខ្ញុំទេដែលនៅរស់ អ្នក៧០៣ផ្សេងទៀតត្រូវចាប់ខ្លួនយ៉ុំអស់។ ខ្ញុំចង់និយាយថា មានតែខ្ញុំទេដែលនៅសល់ ឬ នៅរស់")។ ប្រតិចារឹត ២២ កក្កដា ២០០៩ ទំព័រ៥០ (ប្រាក់ ខន៖ "អ្នកដែលត្រូវចាប់ខ្លួនដាក់ស-២១ទួលស្លែង អ្នកដែលធ្វើការនៅកន្លែងនោះក្នុងក្រុមសួរចម្លើយ និងការពារ ប្រភពពួកគេគឺមកពី៧០៣ពីដំបូង។ ខ្ញុំប៉ាន់ស្មានថាប្រហែល ៣០០នាក់ មិនតិចជាង៣០០នាក់ទេ រួមទាំងអ្នកនៅក្នុងក្រុមសួរចម្លើយ និង ការពារ....")។

[៤០៦] ប្រតិចារឹត ២២ កក្កដា ២០០៩ ទំព័រ ៥១-៥២។ សូមមើលផងដែរ ប្រតិចារឹត ២៧ មេសា ២០០៩, ទំព័រ ៧៧ (ឌុចធ្វើយ៉ាងហោចមិនឱ្យមនុស្សរបស់គាត់ត្រូវបោសសម្អាតនៅស-២១)។

[៤០៧] សូមមើល ប្រតិចារឹត ២២ កក្កដា ២០០៩, ទំព័រ ៥១-៥២។ ប្រតិចារឹត ២០ កក្កដា ២០០៩ ទំព័រ ២៨-២៩។

១១៦. អត្តចរិត និង ប្រវត្តិរបស់ឌុច គឺជាមូលហេតុដែលគណៈអចិន្ត្រៃយ៍តែងតាំងគាត់ជាប្រធានស-២១ នៅពេលដែលសម្រេចធ្វើការបោសសម្អាតនៅក្នុងជួរ។[៤០៨] គណៈអចិន្ត្រៃយ៍ត្រូវការអ្នកដែលពួកគេទុកចិត្តក្នុងការបំពេញមាគ៌ាបក្សដ៏សំខាន់នេះ ដែលមិនត្រឹមតែ"ចាប់មនុស្សខុសប៉ុណ្ណោះទេ" ថែមទាំង "សម្លាប់មនុស្សខុសទៀតផង"។[៤០៩] មនុស្សម្នាក់នេះគឺឌុច។ ភស្តុតាងបង្ហាញដោយគ្មានការសង្ស័យថា ឌុចជាអ្នករៀបចំការអនុវត្តនៅស-២១ ដែលបង្កើតអារុំមានប្រសិទ្ធិភាពរបស់របបនោះក្នុងការស្វែងរកខ្មែរ"ខ្មាំង" និង "ជនក្បត់"។[៤១០] បក្សត្រូវការអ្នកដឹកនាំម្នាក់ដែលមិនខ្លាចបំពេញសកម្មភាពនៅក្នុងកាលៈទេសៈមិននឹកស្មានដល់ដូចអ្នកកាន់តំណែងមុនឌុច, ណាត។ ដូចឌុចខ្លួនឯងបាននិយាយថា "បក្សមិនទុកចិត្តណាត ប៉ុន្តែ បក្សទុកចិត្តខ្ញុំ។ មេខ្ញុំ សុន សេន នៅពេលណាតចេញទៅ គាត់និយាយថា ណាត សំបូរតោក់ទិច និង ពោរពេញដោយល្បិចកល។ ហើយគេទុកចិត្តខ្ញុំដោយសារខ្ញុំស្មោះត្រង់..."។[៤១១]

១១៧. អចន្ត្រៃយ៍ពិតជាត្រឹមត្រូវណាស់ដែលទុកចិត្តឌុច ដោយសារគាត់នៅតែស្ម័គ្រស្មោះនឹងបដិវត្តរហូតដល់យូរឆ្នាំបន្ទាប់ពីកម្ពុជាប្រជាធិបតេយ្យដួលរលំ បើទោះបីជាគាត់មាន"វិប្បដិសារី"ក៏ដោយ។[៤១២] អ្នកចិត្តវិទ្យាជំនាញបានបន្តកត់សំគាល់នៅក្នុងរបាយការណ៍របស់ពួកគេថា "វិប្បដិសារី"ដែលឌុចបាន

---

[៤០៨] ប្រតិចារឹត ២៣ មិថុនា ២០០៩ ទំព័រ ៤៥ (ឌុចៈ "ព្រឹត្តិការណ៍ទីបី នៅក្នុងខែមិនា ១៩៧៦ អង្គការដកណាតពីស-២១ ដោយសម្អាងលើតម្រូវការការងារចាំបាច់។ គាត់ត្រូវដកនៅក្នុងខែមិនា។ ព្រឹត្តិការណ៍ទីបួន ជាព្រឹត្តិការណ៍សំខាន់បំផុតដែលប៉ុល ពត បានសម្រេចនូវបញ្ហាមួយចំនួននៅថ្ងៃទី៣០ មិនា ១៩៧៦។ .... នៅខែមេសា ថ្ងៃទី១៩ ថ្ងៃទី២០ ថ្ងៃទី២១ អចិន្ត្រៃយ៍ធ្វើកិច្ចប្រជុំចំនួនបីថ្ងៃ ហើយប៉ុល ពត បានព្យាយាមព្យួរគាត់ពីដំណែង")។ សូមមើល ប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ៤៥ (បណ្ឌិតឆែនដ្ល័រពន្យល់ពីរបៀបភាពមិនទុកចិត្តគ្នាកើនឡើងខ្លាំងបន្ទាប់ពីខែមេសា ១៩៧៦ ដែលចាំបាច់តម្រូវឱ្យមានកន្លែងសួរចម្លើយដើម្បីស្វែងរកខ្មែរក្បត់)។

[៤០៩] ប្រតិចារឹត ៦ សីហា ២០០៩ ទំព័រ២៨។

[៤១០] សូមមើល ប្រតិចារឹត ៦ សីហា ២០០៩. ទំព័រ ៧០ (បណ្ឌិតឆែនដ្ល័រៈ "ឌុចជាអ្នកគ្រប់គ្រងស-២១ដ៏មានមោទនភាពសស្រាក់សស្រាំ ដែលបង្កើតបច្ចេកទេស និង វិធីសាស្ត្រគ្រប់គ្រងពីគ្មានអ្វីសោះ... មិនធ្លាប់មានកន្លែងបែបនេះទេពីមុនមក... គាត់មាន គំនិតច្នៃប្រឌិតណាស់ ដូចដែលគេនិយាយថា កែលម្អជានិច្ច")។

[៤១១] ប្រតិចារឹត ២៧ មេសា ២០០៩ ទំព័រ ៩១។

[៤១២] សូមមើល ប្រតិចារឹត ២៧ មេសា ២០០៩, ទំព័រ ១១០។ សូមមើល របាយការណ៍ចិត្តសាស្ត្រ ទំព័រ៥១ (បន្ទាប់ពីឆ្នាំ១៩៩០ ឌុចបានរំខានដល់ការពិភាក្សារបស់គ្រូៗមួយទាក់ទងនឹងខ្មែរក្រហម ហើយគាត់ទះពុះ "ប្រសិនបើមិនដឹងពីខ្មែរក្រហមមិនគួរនិយាយទេ")។ *សំណុំរឿងកាំង ហ្កេកអ៊ាវ,* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង. The Lost Executioner: A Story of the Khmer Rouge, ឯកសារលេខ E160.1, page 251.

បញ្ចេញនៅទួលស្លែងកាលពីឆ្នាំ២០០៨ នៅចំពោះមុខជនរងគ្រោះគឺមិនស្មោះត្រង់ទេ: "តាមការវិភាគសំដីនេះបង្ហាញថា គាត់មិនមានវិប្បដិសារីចំពោះការសម្លាប់ជនរងគ្រោះទេ ប៉ុន្តែ វិប្បដិសារីចំពោះទារុណកម្ម និង អំពើអមនុស្សធម៌មុនពេលពួកគេស្លាប់។ ឌុចនិយាយពី"ជនរងគ្រោះដែលភ័ព្វអាក្រក់" ហាក់បីដូចជាមានអ្វីដែលគេអាចហៅបានថា ជនរងគ្រោះ"ភ័ព្វល្អ"អញ្ចឹង។[៤១៣]

១១៨. ដោយដោះសារ ឌុចបានផ្តល់សក្ខីកម្មថា ប្រសិនបើគាត់មិនធ្វើ អ្នកដទៃម្នាក់ទៀតនឹងមកបំពេញការងារគាត់ដដែល[៤១៤] ចង់បង្កប់នូវអត្ថន័យថា អ្នកផ្សេងនោះនៅតែឃោរឃៅដូចគាត់ដែរ។ ជាអកុសលសម្រាប់ជនរងគ្រោះ ភស្តុតាងនៅក្នុងតុលាការ និង ដែលត្រូវបានសង្ខេបនៅក្នុងសារណានេះ បង្ហាញឱ្យឃើញថា នេះមិនមែនជាការពិតទេ។

---

[៤១៣] របាយការណ៍ចិត្តសាស្ត្រ ទំព័រ៥១។ សូមមើលផងដែរ របាយការណ៍ចិត្តសាស្ត្រ ទំព័រ ៤៩-៥២ ("ឧទាហរណ៍អំពីកង្វះខាតការអាណិតអាសូរដល់អ្នកដទៃ" ជាមួយនឹងឧទាហរណ៍ជាច្រើនអំពីកង្វះខាតទាំងស្រុងនូវការអាណិតអាសូរនេះរបស់ឌុច នៅឆ្នាំ២០០៨ នៅពេលធ្វើបទសម្ភាសន៍)។

[៤១៤] ប្រតិចារឹក ៨ មេសា ២០០៩ ទំព័រ ៣២-៣៣។

## VI. សំណងជំងឺចិត្ត

១១៩. កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះនៃសាលាដំបូងបានចេញ*សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណងជំងឺចិត្ត និង អំពីការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ជាលាយលក្ខណ៍អក្សរ* ដែលក្នុងនោះ អង្គជំនុំជម្រះបានណែនាំភាគីឱ្យបញ្ជាក់បន្ថែមអំពីពាក្យសុំទារសំណងជម្ងឺចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសារណាបញ្ចប់របស់ពួកគេ[៤១៥] បន្ថែមទៅលើការដាក់ជូនសារណាអំពី "ទម្រង់នៃសំណងជម្ងឺចិត្តជារួម និង ផ្លូវចិត្ត [ដែលដើមបណ្តឹងរដ្ឋប្បវេណី] ចង់បាន គួរតែត្រូវផ្តល់ឱ្យក្នុងករណីដែលរកឃើញថាជនជាប់ចោទមានទោស"។[៤១៦]

១២០. កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូននូវសេចក្តីសន្និដ្ឋាន រួមមួយចុះហត្ថលេខាដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំង៤ក្រុមដែលបានបញ្ជាក់ពីទម្រង់នៃសំណងជម្ងឺចិត្ត ដែលពួកគេបានស្នើសុំពីសំណាក់ចុងចោទ ព្រមទាំងរបៀបដែលការស្នើសុំនោះអាចសម្រេចទៅបាន។[៤១៧] ដូច្នេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ អនុម័តយកសារណាដើមបណ្តឹងរដ្ឋប្បវេណីរួមនេះ (ក្រោយពីនេះហៅថា "សារណារួម") បញ្ចូលទាំងស្រុងក្នុងសារណាសន្និដ្ឋានបញ្ចប់នេះ។ តាមរយៈការវិភាគយ៉ាងហ្មត់ចត់នៅក្នុងសារណារួមនោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ សូមផ្តល់អំណះអំណាងត្រឹមតែទាក់ទងនឹងសំណើរសុំសំណងជម្ងឺចិត្តជាក់លាក់ ដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដែលនេះមិនមែនជាបញ្ជីលម្អិតឥតចន្លោះអំពីសំណងជម្ងឺចិត្តរួម និង ផ្លូវចិត្ត ដែលអាច ឬ គួរតែផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០១។

### ក. ការទាមទារជាក់លាក់សម្រាប់សំណងជំងឺចិត្ត

[៤១៥] *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណងជំងឺចិត្ត និង ស្តីអំពីការដាក់សារណាជាលាយលក្ខអក្សរបញ្ចប់, ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០៩, E159, វាក្យខណ្ឌ ៥។

[៤១៦] សុំមើល *សំណុំរឿងកាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សេចក្តីណែនាំអំពីសវនាការទាក់ទងនឹងសំណងជំងឺចិត្ត និង ស្តីអំពីការដាក់សារណាជាលាយលក្ខអក្សរបញ្ចប់, ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០៩, E159 វាក្យខណ្ឌ ១។

[៤១៧] *សំណុំរឿងកាំង ហ្គេកអ៊ាវ* ០០១/១៨-០៧-២០០៧-អ.វ.ត.ក/សាលាដំបូង, សារណារួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសំណងជំងឺចិត្ត, ១៤ កញ្ញា ២០០៩ (បន្ទាប់ពីនេះហៅថា "សារណារួមអំពីសំណងជម្ងឺចិត្ត")។

១២១. ដូចដែលបានបញ្ជាក់នៅក្នុងសារណារួម កាតព្វកិច្ចរបស់អង្គជំនុំជម្រះគឺត្រូវប្រគល់ "សំណងជារួម និងសំណងជំងឺចិត្ត"ដែលត្រូវទទួលខុសត្រូវដោយជនជាប់ចោទ។[៤១៨] មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ សុំដាក់នូវសំណើរជាក់លាក់ដូចខាងក្រោម ទាក់ទងទៅនឹងសំណងផ្លូវជំងឺចិត្ត បន្ថែមពីលើ និងមានបញ្ជាក់រួចហើយ នូវការស្នើសុំដែលមានលម្អិតនៅក្នុងសារណារួម។[៤១៩]

**ការទទួលស្គាល់**

១. ជាសំណើរដំបូង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១ ស្នើសុំឱ្យអង្គជំនុំជម្រះទទួលស្គាល់នៅក្នុងសាលក្រមចុងក្រោយ នូវសិទ្ធិទទួលបានសំណងជំងឺចិត្ត និងសិទ្ធិស្វែងរកការពិត។[៤២០]

**កិច្ចការផ្សព្វផ្សាយ**

២. ការផ្សព្វផ្សាយអំពីការរកឃើញរបស់តុលាការ តាមរយៈការចុះផ្សព្វផ្សាយដោយផ្ទាល់ និងតាមការប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដូចជា ការបោះពុម្ពផ្សាយជាក្រដាស ទូរទស្សន៍ និងវិទ្យុ។[៤២១]

**ការពិនិត្យព្យាបាលសុខភាពផ្លូវកាយនិងផ្លូវចិត្ត**

---

[៤១៨] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ២៣(១១)។ សុំមើល សារណារួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងទៅនឹងសំណងជម្ងឺចិត្ត, វាក្យខណ្ឌ ២-៣។

[៤១៩] សុំមើល សារណារួមទាក់ទងទៅនឹងសំណងជម្ងឺចិត្ត, វាក្យខណ្ឌ ១១-៣០។

[៤២០] G.A. Res. A/RED/60/147, គោលការណ៍ និង ការណែនាំជាមូលដ្ឋានស្ដីអំពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងជម្ងឺចិត្តសម្រាប់ជនរងគ្រោះនៃអំពើបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្ស និង ច្បាប់មនុស្សធម៌អន្តរជាតិ, ២១ មិនា ២០០៦ [បន្ទាប់ពីនេះហៅកាត់ថា "គោលការណ៍ជាមូលដ្ឋាន (Basic Principles)"]. ។ ដោយយោងទៅតាមគោលការណ៍មូលដ្ឋាន និងសេចក្ដីណែនាំផ្សេងដែលបង្កើតឡើងជាដំបូងដោយលោក Cherif Bassiouni និង Theo van Boven ការដោះស្រាយផ្លូវច្បាប់ចំពោះការបំពានធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ គួរតែមានបញ្ចូល"សំណងជំងឺចិត្តគ្រប់គ្រាន់ មានប្រសិទ្ធភាពនិង ទាន់ពេលវេលា ចំពោះព្យសនកម្មដែលកើតឡើង"។ សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ ១១។ ដូចគ្នានេះដែរ សំណងជំងឺចិត្តគួតែ"សមាមាត្រទៅនឹងការបំពារបំពានធ្ងន់ធ្ងរ និងព្យសនកម្មដែលជនរងគ្រោះបានឆ្លងកាត់"។ សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ១៥។

[៤២១] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ១២-១៦។

៣. ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ បានបញ្ជាក់ថា គេមើលឃើញថាការពិនិត្យព្យាបាលសុខភាពដល់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់ពួកគេ មានសារៈសំខាន់ណាស់ ដោយសារថាពួកគេកាន់តែមានវ័យចំណាស់ ហើយសេវាថែទាំសុខភាពនៅតាមកន្លែង ពួកគេរស់នៅមិនមានបទដ្ឋានត្រឹមត្រូវទេ។ សេវាថែទាំសុខភាពនោះ ដែលមានបញ្ចូលសេវាសាធារណៈ សេវាថែទាំសុខភាពផ្លូវចិត្ត និងការអប់រំសុខភាព ជាធម្មតាមិនមានទេ ដោយយោងទៅតាមទីតាំង និងការចំណាយ ។[៤២២]

៤. ការផ្តល់សេវាថែទាំសុខភាពផ្លូវចិត្តដល់ជនគ្រោះ ដោយជួយពួកគាត់ប្រឈមមុខ និងដោះស្រាយបញ្ហាផ្លូវចិត្ត និងអំពើបំពាបំពានដែលបង្កឡើងដោយខ្មែរក្រហម ជាពិសេសដោយសារការបាត់បង់អ្នកដែលជាទីស្រលាញ់របស់ពួកគេនៅមន្ទីរស-២១។[៤២៣]

៥. វត្តមានរបស់អង្គការចិត្តសង្គមអន្តរវប្បធមិ ដែលកំពុងតែផ្តល់ការមើលថែទាំសុខភាពផ្លូវចិត្តដល់ជនរងគ្រោះ និងសាក្សីជាច្រើនដោយមិនគិតប្រាក់នោះ គួរតែទទួលបាននូវការគាំទ្រ និងពង្រឹងបន្ថែមតាមរយៈជាការផ្តល់សំណងជម្ងឺចិត្ត ហើយពិសេសដោយសារតែរចនាសម្ព័ន្ធមានស្រាប់របស់អង្គការនេះអាចផ្តល់ជំនួយក្នុងករណីបន្ទាន់បាន ។[៤២៤]

៦. ការឈឺចាប់ពីអតីតកាលទាំងផ្លូវកាយនិងផ្លូវចិត្ត អាចបង្កជាផលប៉ះពាល់យូរអង្វែងដល់ផ្លូវកាយរបស់ជនរងគ្រោះ ដូច្នេះ តម្រូវឱ្យមានការចាំបាច់ផ្តល់សេវាសុខភាពមិនយកកំរៃដល់ជនរងគ្រោះជាទូទៅ និង ជាពិសេស ស-២១។ ការផ្តល់សេវាសុខភាពនេះ គួរតែបញ្ចូលទាំងសាហ៊ុយធ្វើដំណើរទៅកាន់មន្ទីរពេទ្យនោះផង ។[៤២៥]

**កម្មវិធីសិក្សាអប់រំ**

៧. មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ សូមស្នើសុំដោយក្តីគោរព ឱ្យមានការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ជាងមុន អប់រំសង្គមកម្ពុជានៅក្នុងការសិក្សាអំពីការរំលោភបំពានទៅលើសិទ្ធិមនុស្ស

---

[៤២២] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ ១៧។ សូមមើល របាយការណ៍ស្ថិតិរបស់អង្គភាពជនរងគ្រោះ, ឯកសារនេះមាននៅក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

[៤២៣] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ១៨-១៩ ។

[៤២៤] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ២០។

[៤២៥] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ២១។

អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ការចងក្រងឯកសារប្រវត្តិសាស្ត្រ"ពិត" នៅក្នុងរបបខ្មែរក្រហម អាចធ្វើការចងក្រងជាសៀវភៅបោះពុម្ព ដើម្បីបម្រើដល់គោលបំណងប្រវត្តិសាស្ត្រ។ ទម្រង់ណាមួយនៃសំណងជំងឺចិត្តអាចផ្តល់ទៅបៀវត្សរ៍ និងការហ្វឹកហ្វឺនគ្រូបង្រៀន កសាងសាលា រៀបចំកម្មវិធីសិក្សា បោះពុម្ពឯកសារសម្រាប់សិក្សា និងការហ្វឹកហ្វឺនជាបន្តបន្ទាប់សម្រាប់ អ្នកមូលដ្ឋានអំពីកម្មវិធីអប់រំសិទ្ធិ។[៤២៦]

៨. ខ្មែរក្រហមបានបផ្លិចបំផ្លាញយ៉ាងមិនគួរឱ្យជឿនូវការអភិវឌ្ឍន៍ផ្នែកសិក្សា និង វិជ្ជាជីវៈរបស់ជនរងគ្រោះ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ស្នើសុំដោយក្តីគោរព នូវជំនួយក្នុងការបង្កើតជាមូលនិធិអាហារូបករណ៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរាប់បញ្ចូលដូចជាការបង្រៀនវិជ្ជាជីវៈ ប្រាក់កម្ចីសម្រាប់អាជីវកម្មខ្នាតតូច វគ្គហ្វឹកហ្វឺនពីជំនាញធ្វើអាជីវកម្ម ដើម្បីធានាថា មនុស្សជំនាន់ក្រោយទទួលបានមធ្យោបាយល្អបំផុតក្នុងការរីកលូតលាស់ ទាំងក្នុងកម្រិតវិជ្ជាជីវៈ និងសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ។

**កន្លែងចងចាំ**

៩. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ស្នើសុំឱ្យមានការកសាងជាបូជនីយដ្ឋានសម្រាប់សាច់ញាតិរបស់ពួកគេ ដែលជាជនរងគ្រោះនៅមន្ទីរស-២១។[៤២៧]

១០. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ស្នើសុំឱ្យមានការសាងបូជនីយដ្ឋាននៅមន្ទីរស-២១ ជើងឯក និង នៅព្រៃស។ ការស្នើសុំនេះក៏មានរាប់បញ្ចូលទាំងការធ្វើស្លាកឈ្មោះ ដែលមានចារឈ្មោះជនរងគ្រោះទាំងអស់ ផ្តល់ឱកាសដល់ពួកគេក្នុងការរៀបរាប់រឿងរ៉ាវទៅសាធារណៈជន ព្រមទាំងរូបសំណាកតំណាងឱ្យការឈឺចាប់របស់ជនរងគ្រោះ។[៤២៨]

---

[៤២៦] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ ២៣-២៥។ សុំមើល Jaya Ramji ខាងលើលេខ ៣ ទំព័រ ៣៧០។

[៤២៧] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌ២៦-២៧។

[៤២៨] សូមមើល គោលការណ៍ជាមូលដ្ឋាន, វាក្យខណ្ឌទី២៨។ ទម្រង់ស្នើសុំផ្សេងទៀតទាក់ទងនឹងកន្លែងចងចាំ មានដូចជាការឆ្លាក់ឈ្មោះជនរងគ្រោះនៅលើចេតិយ ឬស្លាកចងចាំនៅស-២១ ផ្សព្វផ្សាយឈ្មោះជនរងគ្រោះទៅកាន់មជ្ឈដ្ឋានសិក្សានាសារមន្ទីរចល័តពីមួយដែលមានរូបថតនិងរឿងរ៉ាវរបស់ជនរងគ្រោះ ដែលអាចផ្សព្វផ្សាយទៅកាន់ប្រជាជនកម្ពុជាមិនអាចធ្វើដំណើរមកទីក្រុងភ្នំពេញ. ការកសាងរូបសំណាក់ចងចាំមួយនៅមន្ទីរស-២១ ជើងឯក និងព្រៃស. ការដាក់តាំងឈ្មោះ

E159/7

១១. ក្រៅពីបូជនីដ្ឋានឬ កំរូបសំណាកនៅមន្ទីរស-២១ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ស្នើសុំឱ្យមានការកសាងវត្តអារាម ឬ របងវត្តដើម្បីផ្តល់ជាកិត្តិយសដល់អ្នកជាទីស្រលាញ់របស់ពួកគេ។[៤២៩] ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនមិនរស់នៅជិតទីក្រុងភ្នំពេញទេ ហើយបើមានវត្តអារាម ឬ របងវត្តនៅក្នុងសហគមន៍របស់ពួកគេ បន្ថែមពីលើការសាងសង់បូជនីយដ្ឋាននៅមន្ទីរស-២១ គឺប្រាកដជានឹងបំពេញនូវតម្រូវការរបស់ពួកគេ។

២. ទោះបីជាសព្វថ្ងៃមាន"ថ្ងៃជ័យជំនះ" ប្រារព្ធធ្វើឡើងនៅថ្ងៃទី៧ ខែមករា ដើម្បីរំឭកដល់ការដួលរលំរបបខ្មែរក្រហមក៏ដោយ ថ្ងៃនេះត្រូវបានគេផ្តោតជាសំខាន់ទៅលើជោគជ័យផ្នែកនយោបាយជាជាងការរំឭកអំពីទុក្ខវេទនា និង ការឈឺចាប់ទទួលរងគ្រោះដោយជនរងគ្រោះ។ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំឱ្យមានថ្ងៃចងចាំថ្នាក់ជាតិមួយ ដើម្បីជាការចងចាំដល់ជនរងគ្រោះដែលស្លាប់និងរងទុក្ខវេទនាដោយសារស្នាដៃខ្មែរក្រហម។

**ផ្សេងៗ**

១២. ការលោតត្រដាងទាំងស្រុងនិងស្មោះត្រង់ពីទ្រព្យសម្បត្តិក្នុងនាមជាជនជាប់ចោទ។

### ខ. ភាតព្វកិច្ចរដ្ឋនៅក្រោមច្បាប់អន្តរជាតិ

---

ដើមបណ្តឹងរដ្ឋប្បវេណីនៅស-២១ និងការដាក់ឈ្មោះស្ថាប័នសំខាន់ៗ ដូចជា មន្ទីរពេទ្យដោយប្រើប្រាស់ឈ្មោះជនរងគ្រោះរាប់មិនអស់នៅមន្ទីរស-២១។

[៤២៩] មានវត្តអារាមមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលជាកន្លែងចងចាំដល់អ្នកដែលស្លាប់នៅក្នុងសម័យខ្មែរក្រហម។ ជាឧទាហរណ៍ វត្តក្តីដូងគឺជាកន្លែងដែលមានរណ្តៅសាកសពរួម ដែលសាកសពជាច្រើនត្រូវបានកប់នៅចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដោយសាររបបខ្មែរក្រហម។ ឆ្អឹងរបស់ជនរងគ្រោះស្ថិតនៅក្នុងចេតិយខាងក្រោមវត្ត សុំមើលគេហទំព័រតុលាការខ្មែរក្រហម "បូជនីដ្ឋានវត្តក្តីដូង: វាលពិឃាតរបស់របបខ្មែរក្រហម" ដែលអាចចូលមើលនៅលើ http://www.krtrial.info/showarticle.php?language=english&action=showarticle&art_id=2918&needback=1

E159/7

១២២. មានចែងច្បាស់លាស់នៅក្នុងច្បាប់ណាស់ថា ការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបាននាំឱ្យមានសិទ្ធិទទួលបានសំណងជម្ងឺចិត្តដល់ជនរងគ្រោះនៅក្នុងឧក្រិដ្ឋកម្មទាំងនោះ ។[៤៣០] ការអនុវត្តជាក់ស្តែងនិងការប្រតិបត្តិក្នុងការផ្តល់សំណង ជាធម្មតា គឺធ្លាក់ទៅជាការទទួលខុសត្រូវរបស់រដ្ឋ ។ ជាក់ស្តែងការអនុវត្តរបស់រដ្ឋបានផ្លោះទៅរកការទទួលយកការកាតព្វកិច្ចទូទៅ[៤៣១] ក្នុងការផ្តល់ជាសំណងថាជាគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ។[៤៣២] ការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈការស្ម័គ្រចិត្តរបស់រដ្ឋក្នុងការបង្កើតកម្ម

---

[៤៣០] *សូមមើល ជាឧទាហរណ៍ សំណុំរឿងទាក់ទងនឹងជម្លោះប្រដាប់អាវុធនៅក្នុងប្រទេសកុងហ្គោ (សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនិង អ៊ុយហ្គាន់ដា)*, សាលក្រមនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៥។ របាយការណ៍ I.C.J ឆ្នាំ២០០៥។ សូមមើល សេចក្តីប្រកាសជាសកលពីសិទ្ធិមនុស្ស មាត្រា ៨។ កាតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា២។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃការរើសអើងពូជសាសន៍ មាត្រា៦។ អនុសញ្ញាប្រឆាំងនិងការធ្វើទារុណកម្ម និងការប្រព្រឹត្តអំពើអមនុស្សធម៌ឬការប្រព្រឹត្តមិនសមរម្យ ឬការដាក់ទណ្ឌកម្ម មាត្រា១៤។ លក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧៥។ គោលការណ៍ជាមូលដ្ឋាន, នៅវាក្យខណ្ឌ ១៩-២៣។

[៤៣១] ដូចដែលបានលើកឡើងដោយគណៈកម្មាសិទ្ធិមនុស្ស កាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់សំណងជម្ងឺចិត្តដល់បុគ្គលដែលសិទ្ធិរបស់ពួកគេមានចែងនៅក្នុងអនុសញ្ញាត្រូវបានរំលោភបំពាន គឺជាធាតុមួយនៃការដោះស្រាយក្នុងស្រុកតាមផ្លូវច្បាប់មួយដ៏មានប្រសិទ្ធិភាព: "ដោយគ្មានសំណងផ្តល់ទៅកាន់បុគ្គលដែលសិទ្ធិរបស់ពួកគេនៅក្នុងអនុសញ្ញាបានរំលោភបំពាន កាតព្វកិច្ចក្នុងការផ្តល់នូវដំណោះស្រាយមានប្រសិទ្ធិភាព [....] គឺមិនត្រូវបានអនុញ្ញាតទេ"។ យោបល់ទូទៅ (General comment N° 31 (2004)) ស្តីអំពីលក្ខណៈនៃកាតព្វកិច្ចច្បាប់ទូទៅដែលដាក់ឱ្យរដ្ឋសមាជិករបស់កតិកាសញ្ញាអនុវត្តៈ ២៦ ឧសភា ២០០៤។ កតិកាសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ICCPR/C/21/Rev.1/Add.13 (General Comments) ។

[៤៣២] គោលការណ៍ជាមូលដ្ឋាន, នៅវាក្យខណ្ឌ១៦ ។

វិធីសំណងរដ្ឋបាលសម្រាប់ជនរងគ្រោះទេ[៤៣៣] មិនត្រឹមតែជាឯកសារតុលាការ និងសូម្បីតែក្នុងករណីដែលតុលាការពិសេសគ្មានអាណត្តិច្បាស់ក្នុងការផ្តល់សំណងក៏ដោយ។[៤៣៤] វាគួរតែមិនខុសគ្នាដែរសម្រាប់ប្រទេសកម្ពុជាដែលគួរតែទទួលខុសត្រូវក្នុងការផ្តល់ជំនួយដល់តុលាការ ក្នុងការធានាថា ជនរងគ្រោះដោយរបបខ្មែរក្រហម ទទួលបានសំណងសមរម្យចំពោះការឈឺចាប់របស់ពួកគេ ដែលមានទាំងសំណងរូប និង សំណងផ្លូវចិត្ត ដែលពួកគេមានសិទ្ធិទទួលបាន។[៤៣៥]

១២៣. វាពិតជាមានសារសំខាន់ណាស់ដែលថា តុលាការនេះទទួលបានជោគជ័យក្នុងការផ្តល់សំណងជម្ងឺចិត្តសមរម្យចំពោះដើមបណ្តឹងរដ្ឋប្បវេណី ព្រោះថាការបរាជ័យក្នុងកិច្ចការនេះនឹងធ្វើឱ្យប៉ះពាល់ដល់

---

[៤៣៣] ប្រទេសជាច្រើនបានបង្ហាញការធ្វើរបៀបនេះ ដោយអនុម័តកម្មវិធីរដ្ឋបាលដើម្បីផ្តល់សំណងជម្ងឺចិត្ត តាមរយៈរបៀបផ្សេងៗ សម្រាប់ការប្រព្រឹត្តបទល្មើសទៅលើជនរងគ្រោះ។ សុំមើល សំណុំរឿងនៅប្រទេសអាហ្សង់ទីន ដែលច្បាប់ខុសៗគ្នាត្រូវបានអនុម័តដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះ។ ប្រទេសប៉េរូ ដែលរដ្ឋាភិបាលបានបង្កើតកម្មវិធីសំណងជម្ងឺចិត្តមានលក្ខណៈទូលំទូលាយមួយ ដែលត្រូវបានគេយល់ស្របឱ្យបង្កើតឡើងនៅចុងខែកក្កដា ឆ្នាំ២០០៥ សម្រាប់ជនរងគ្រោះក្នុងជម្លោះក្នុងស្រុកកើតឡើងចាប់ពីឆ្នាំ១៩៨០ រហូតដល់ឆ្នាំ២០០០។ ប្រទេសហ្គាតេម៉ាឡា (Guatemala) បានបង្កើតកម្មវិធី *Programa Nacional de Resarcimiento* នៅក្នុងឆ្នាំ២០០៣ សម្រាប់ជនរងគ្រោះដោយជម្លោះក្នុងស្រុកកើតឡើងចាប់ពីឆ្នាំ១៩៦០ រហូតដល់ ឆ្នាំ១៩៩៦ ហើយប្រទេសអាល្លឺម៉ង់បានបង្កើតកម្មវិធីសំណងជម្ងឺចិត្តដើម្បីសងដល់ជនរងគ្រោះដោយការបង្ខំឱ្យធ្វើការធ្ងន់ធ្ងរ នៅក្នុងសង្គ្រាមលោកលើកទី២។

[៤៣៤] សុំមើល តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គូស្លាវី និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា (រដ្ឋាភិបាលរបស់ប្រទេសរ៉ាន់ដា អនុញ្ញាតឱ្យតុលាការក្នុងស្រុក និងតុលាការ Gacaca ដោះស្រាយពីបញ្ហាសំណងជម្ងឺចិត្ត និងបង្កើត *Fonds d'Assistance aux Rescapés du Génocide* នៅក្នុងឆ្នាំ១៩៩៨) និង SCSL (កម្មវិធីសំណងជំងឺចិត្តរបស់ប្រទេសសេរ៉ាឡេអូនត្រូវបានចែងនៅក្នុងច្បាប់មួយដោយឡែក។)។

[៤៣៥] ជាក់ស្តែង កម្ពុជាបានជាសមាជិកលើអនុសញ្ញាប្រឆាំងនិងសកម្មភាពព្រៃផ្សៃ អមនុស្សធម៌ឬការ ប្រព្រឹត្តមិនសមរម្យ ឬការដាក់ទណ្ឌកម្ម ( Convention against Torture and Other Cruel, Inhuman or Degrading Treatment or Punishment) កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ដែលបានតម្រូវឱ្យរដ្ឋហត្ថលេខីផ្តល់ជាសំណងជម្ងឺចិត្តដល់ជនរងគ្រោះដោយការធ្វើទារុណកម្ម។ (សុំមើល មាត្រាទី១៤។ វាច្បាស់ណាស់ថា ជនរងគ្រោះនៅមន្ទីរស-២១ត្រូវបានគេធ្វើទារុណកម្ម និង សម្លាប់។

ភាពស្របច្បាប់នៃដំណើការនីតិវិធី និងតុលាការទាំងមូលផងដែរ។ មានគំរូមួយចំនួនទាក់ទងទៅនឹងការផ្តល់សំណងជំងឺចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកម្រិតអន្តរជាតិ យើងអាចក្រឡេកមើលសំណុំរឿងមួយចំនួននៅប្រទេសបារាំងជាគំរូ។ នៅក្នុងសំណុំរឿង ប៉ូល ទូវីយ៉េ និង ក្លូស បាប៊ី (*Paul Touvier and Klaus Barbie*) តុលាការក្នុងស្រុកបារាំងបានផ្តល់អោយជនរងគ្រោះដោយឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាសំណងនិមិត្តរូបដែលដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទទួលបានប្រាក់មួយហ្វ្រង់។[៤៣៦] ទោះជាយ៉ាងណាក៏ដោយ រឿងក្តីទាំងពីរខាងលើនេះខុសប្លែកពីរឿងក្តីបច្ចុប្បន្ននៅក្នុងអ.វ.ត.ក ដែលដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្នើសុំតែសំណងនិមិត្តរូបទេ។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងបានស្នើសុំសំណងជម្ងឺចិត្តជារូមយ៉ាងពិតប្រាកដ ហើយដែលស្ថិតនៅក្រោមអណត្តិរបស់តុលាការនេះ ដែលរួមមានសំណងជម្ងឺចិត្តរួមលម្អិតដែលតម្រូវឱ្យមានមូលនិធិ។ ផ្ទុយទៅនឹងសំណុំរឿងទាំងពីរដែលមានតែសំណងនិមិត្តរូបត្រូវបានគេផ្តល់ឱ្យជនរងគ្រោះ] តុលាការក្នុងស្រុកបារាំងមួយនៅក្នុងសំណុំរឿងម៉ូរីស ប៉ាប៉ុង (Maurice Papont) បានចេញដីកាឱ្យប៉ាប៉ុងបង់ប្រាក់ចំនួន៤.៦លានហ្វ្រង់ (ដែលត្រូវជា៨១៧,000ដុល្លា) សម្រាប់ការខូចខាតរបស់ជនរងគ្រោះនិងប្រាក់ចំណាយរបស់តុលាការ។ បើទោះបីជាគាត់ព្យាយាមបង្ហាញថា គាត់គ្មានប្រាក់ក៏ដោយ ការប្តឹងប្តល់គ្នាអស់ជាច្រើនឆ្នាំបន្ទាប់ពីរកឃើញថាមានទោស ជាចុងបញ្ចប់ មិនអនុញ្ញាតឱ្យគាត់ផ្ទេរទ្រព្យសម្បត្តិឱ្យទៅកូនចៅដែលនេះបានត្រួសត្រាយផ្លូវក្នុងការដោះស្រាយជាមួយជនរងគ្រោះ។ ស្ថានការណ៍ដូចដែលបានរៀបរាប់ខាងលើនេះ ដែលការពន្យាពេលដោយការប្តឹងប្តល់គ្នា ការលាក់ទ្រព្យសម្បត្តិ ឬ ភាពស្ទាក់ស្ទើររបស់តុលាការ ដែលអាចរារាំងដល់ទម្រង់សំណងជម្ងឺចិត្តមានអត្ថន័យដល់ជនរងគ្រោះ គួរតែត្រូវចៀសវាងនៅក្នុងករណីបច្ចុប្បន្ននេះ។

---

[៤៣៦] ប៉ូល ទូវីយ៉េ (Paul Tourvier) ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធធានាគារអស់មួយជីវិត ហើយគាត់ស្លាប់នៅទីនោះនៅក្នុងឆ្នាំ១៩៩៦ ហើយសំណងនិមិត្តរូបដែលស្នើសុំឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេផ្តល់ឱ្យ (សាលក្រម នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៣ Cour d'Appel de Versailles (1er); affm'd Cour de Cassation, សាលក្រមនៅថ្ងៃទី២៨ ខែវិច្ឆិការ ១៩៩៤)។ ដូចគ្នានេះដែរ នៅក្នុងសវនាការ ក្លូស បាប៊ី (Klaus Barbie) តុលាការបានចេញក្រមឱ្យមេធាវីការពារក្តីរៀបចំការចំណាយជានិមិត្តរូបមួយ ដោយផ្តល់ប្រាក់មួយហ្វ្រង់ទៅឱ្យជនរងគ្រោះម្នាក់ៗចំនួន៦២នាក់ និង ទៅឱ្យអង្គការតស៊ូជ្វីប និងបារាំង ដែលតំណាងឱ្យជនរងគ្រោះរបស់មេគុកនៅក្រុងលីយ៉ុងនេះ។ (រឿងរបស់ Barbie, Gaz.Pal. Jur. ១៧0(Cass Crim. ថ្ងៃទី0៦ ខែតុលា ឆ្នាំ១៩៨៣) សាលក្រមនៅថ្ងៃទី0៥ ខែតុលា ឆ្នាំ១៩៨៣. Cass. Crim ១៩៨៤ D.S.Jur. ១១៣, Gaz. Pal. Nos.352-54 (ថ្ងៃទី១៨-២០ ខែធ្នូ)។

E159/7

១២៤. ដើម្បីបន្តតម្លាភាពរបស់សវនាការ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ស្នើសុំឱ្យអង្គជំនុំជម្រះបញ្ជាក់ឱ្យកាន់តែច្បាស់ពីគម្រោងសម្រាប់អនុវត្តការផ្តល់សំណងជម្ងឺ បើទោះបីជាក្នុងរូបភាពជានិមិត្តរូបក្តី ឬ ជាលុយកាក់ក្តី នៅក្នុងរបៀបច្បាស់លាស់មួយដែលអាចធ្វើបាន។ លើសពីនេះទៅទៀត ដើម្បីជួយសម្រួលដល់ការផ្តល់ជូន និងការអនុវត្តសំណងជម្ងឺចិត្តយ៉ាងមានប្រសិទ្ធភាព មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ស្នើសុំឱ្យតុលាការអនុញ្ញាតឱ្យអង្គភាពជនរងគ្រោះទទួលបាននូវអាណត្តិអាចប្រឹក្សាយោបល់ទូលំទូលាយ (ក្រៅពីការពិភាក្សាជាមួយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី) ទាក់ទងនឹងរបៀបក្នុងការអនុវត្តសំណងជម្ងឺចិត្តនៅក្នុងបរិបទនេះ។

00400065

E159/7

## VII. សេចក្តីសន្និដ្ឋាន

១២៥. ការបញ្ចប់សំណុំរឿងនេះគឺជាព្រឹត្តការណ៍ប្រវត្តិសាស្ត្រមួយសម្រាប់អ.វ.ត.ក និងជាពិសេសសម្រាប់ប្រទេសកម្ពុជាទាំងមូល។ នេះគឺជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្ររបស់តុលាការអន្តរជាតិ និងតុលាការអាដហុក ដែលជនរងគ្រោះដោយអំពើសាហាវយង់ឃ្នង់អាចចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ស្នើសុំដោយក្តីគោរពថា ការចូលរួមរបស់ជនរងគ្រោះនៅទួលស្លែង ពិតជាបានផ្តល់ឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការកាត់ក្តី មិនត្រឹមតែជាការលើកកម្ពស់ជនរងគ្រោះ និងផ្សះផ្សាររបួសជនរងគ្រោះទេ ថែមទាំងបានជួយអង្គជំនុំជម្រះនៃសាលាដំបូងក្នុងការស្វែងរកការពិតទៀត។

១២៦. អង្គជំនុំជម្រះមានភស្តុតាងជាឯកសាររាប់ពាន់សន្លឹក សក្ខីកម្មរបស់សាក្សី កំណត់ហេតុរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មដែលផ្តល់ដោយជនជាប់ចោទផ្ទាល់។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍បំផុតដែលកើតឡើងនៅពេលការផ្តល់សក្ខីកម្មនៅក្នុងសវនាការ គឺចុងចោទផ្ទាល់មិនបានបកស្រាយការពិតទាំងស្រុងទៅឱ្យអង្គជំនុំជម្រះទេ នៅពេលដែលគាត់សុំឱ្យអត់អោនទោស។ ជាងនេះទៅទៀត មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំលើកឡើងដោយក្តីគោរពថា ចុងចោទនិយាយកុហកម្តងហើយម្តងទៀត ពីការទទួលខុសត្រូវទាំងស្រុងរបស់គាត់ នៅពេលដែលគាត់កាន់តំណែងជាប្រធានស-២១។ ដូចបានបញ្ជាក់នៅក្នុងសារណាសន្និដ្ឋានចុងក្រោយនេះ ភស្តុតាងបានបញ្ជាក់ដោយឥតស្រពេចស្រពិលថា ចុងចោទ បានរៀបចំឱ្យទទួលបានឋានៈជាប្រធាននៅស-២១ និង រៀបចំមន្ទីរឃុំឃាំងផ្ទាល់តែម្តងដោយសំអាងទៅលើអត្តចរិក បំណងប្រាថ្នាផ្ទាល់ខ្លួន និងបទពិសោធពីមុនមករបស់គាត់។ គាត់ទទួលបានជោគជ័យក្នុងការធ្វើឱ្យស-២១ក្លាយជាកន្លែងសម្លាប់មនុស្សមានប្រសិទ្ធភាពបំផុត គ្មានភាពអាណិតអាសូរ ឬមនុស្សធម៌អ្វីឡើយ។ ការសម្លាប់រង្គាលដោយគ្មានក្តីមេត្តានៅពេលនោះគឺជារឿងធម្មតា។

១២៧. បើទោះបីជាមានការសម្តែងពីទុក្ខសោកនិងវិប្បដិសារីក៏ដោយ ភស្តុតាងបង្ហាញថា ទោះបីជានៅជិតពេលបិទសវនាការក៏ដោយ ក៏ចុងចោទនៅតែព្យាយាមគេចវេះពីការទទួលខុសត្រូវរបស់គាត់ ដោយបង្វែរបន្ទុកនៃដំណើរការផ្សះផ្សាទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីវិញ។ អង្គជំនុំជម្រះនៃសាលាដំបូងនៅចងចាំថា នៅពេលសវនាការ ចុងចោទបានងាកទៅនិយាយដាក់ដើមបណ្តឹងរដ្ឋប្បវេណីថា ពួកគេអាចទៅជួបគាត់នៅក្នុងបន្ទប់ឃុំឃាំងដើម្បីទទួលចម្លើយពីគាត់ ដើម្បីជួយពួកគេជាសះស្បើយឡើងវិញ

ប្រសិនបើពួកគេចង់ធ្វើដូច្នោះ។[៨៣៧] បើតាមដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ ពាក្យសំដីចុងក្រោយរបស់ជនជាប់ចោទនេះស្មើនឹងការប៉ុនប៉ងមិនស្មោះត្រង់មួយ ដើម្បីឱ្យធ្វើឱ្យគេមើលឃើញថាទូរវិប្បដិសារី ការដឹងខុស ការយកចិត្តទុកដាក់ និង ការព្រួយបារម្ភ ដោយទន្ទឹមនឹងនោះបន្តបង្វែរចំណាប់អារម្មណ៍ចេញពីការពិត។

១២៨. នៅក្នុងរយៈពេល៦ខែចុងក្រោយនេះ ដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមាននៅចំពោះមុខចុងចោទនៅក្នុងតុលាការ និងទាមទារចម្លើយស្មោះត្រង់ពីចុងចោទ។ តែវាជារឿងមួយគួរឱ្យសោកស្ដាយមួយដែលចុងចោទមានចេតនា និយាយប្រាប់ចម្លើយពិតនៅចុងបញ្ចប់សវនាការ ក្រោយពេលដែលប្រព័ន្ធផ្សព្វផ្សាយលែងសូវមានចំណាប់អារម្មណ៍ និង នៅពេលដែលអង្គជំនុំជម្រះអាចនឹងមិនមានវត្តមានសម្រាប់កត់ត្រាសំដីរបស់គាត់នោះទៀត។ ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានការពិត ហើយដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ ពិតជាមានទំនុកចិត្តថា អង្គជំនុំជម្រះនៃសាលាដំបូងនឹងខិតខំប្រឹងប្រែងដើម្បីសម្រេចគោលបំណងនេះដូចដែលយើងបានរៀបរាប់រួចហើយ និងពិនិត្យមើលភស្តុតាង និងចម្លើយរបស់ជនជាប់ចោទ ដោយមានចង្វល់យ៉ាងសមហេតុសមផល និងការប្រុងប្រយ័ត្នសមរម្យ។

## សំណើរ

១២៩. ជាមួយនឹងហេតុផលជាច្រើនដែលលើកឡើងខាងលើ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ ស្នើសុំដោយក្ដីគោរពឱ្យអង្គជំនុំជម្រះនៃសាលាដំបូងៈ

**អះអាងបញ្ជាក់ម្ដងទៀត** ពីគោលបំណងដំបូងរបស់អ្នកតាក់តែងវិធានផ្ទៃក្នុង ដែលបានផ្ដល់សិទ្ធិយ៉ាងទូលំទូលាយដល់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

**សម្រេច**ថា ឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ ត្រូវបានផ្ដល់ជូនហើយ និងមិនអាចត្រូវបានដកយកវិញទេ។

**ពិចារណា**អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ដូចដែលមានពិភាក្សានៅក្នុងសារណានេះ ដើម្បីគោលបំណងនៃការចេញសាលក្រម និង ផ្ដល់សំណងជម្ងឺចិត្ត។

**ទទួលស្គាល់**សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានសំណងជម្ងឺចិត្ត។

[៨៣៧] ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ទំព័រទី៩១។

00400067

E159/7

**ផ្តល់ឱ្យ**ដើមបណ្តឹងរដ្ឋប្បវេណីនូវសំណងជម្ងឺចិត្តតាមអ្វីដែលពួកបានធ្វើការស្នើសុំ ។

ដោយក្តីគោរពពីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១

ចុះហត្ថលេខានៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩

ទី ស្រ៊ីនណា ការីម ខាន អាឡាំង វ៉ែនណឺ ប្រ៊ីអាន់ មិកហ្គូរនីហ្គល